**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# នីតិវិធី និងការអនុវត្តការប្រកាសពន្ធ

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **ក្រុមហ៊ុនខេមវីល គ្លូប៊ល ឯ.ក**

តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ឈុន ស្រីនាថ**

**ពៅ សុវណ្ណនាងលក្ខិណា**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ឡុង ម៉ាមីឌី**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ឈុន ស្រីនាថ និង ពៅ សុវណ្ណនាងលក្ខិណា ជានិស្សិតថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១០ ក្រុម$B_4B_1$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានកិត្តិយសក្នុងការរៀបចំចងក្រងនូវរបាយការណ៍កម្មសិក្សាក្រោមប្រធានបទ "នីតិវិធី និងការអនុវត្តការប្រកាសពន្ធ" របស់ក្រុមហ៊ុន ខេមរីល គ្លូប៊ល បានយ៉ាងជោគជ័យ ដូចនេះអាស្រ័យដោយមានការជួយជ្រោមជ្រែង និងផ្តល់កម្លាំងចិត្តពីសំណាក់បុគ្គលសំខាន់ៗមួយចំនួន។

## សូមសម្តែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ

- មាតាបិតាទាំងទ្វេភាគី ដែលជាអ្នកមានគុណធំធេងរកអ្វីប្រៀបផ្ទឹមពុំបាន ដោយលោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា និងអប់រំ ទូន្មាន ប្រៀនប្រដៅកូន ប្រកបដោយព្រហ្មវិហារធម៌ដ៏ខ្ពង់ខ្ពស់ជាទីបំផុត ព្រមទាំងជាអ្នកឧបត្ថម្ភ ទំនុកបម្រុងកូនគ្រប់បែបយ៉ាងទាំងផ្នែកស្មារតី និងសម្ភារៈ តាំងពីតូចរហូតដល់ធំដឹងក្តី។ មិនតែប៉ុណ្ណោះ លោកទាំងពីរ បានជំនះនូវរាល់ឧបសគ្គនានា ដែលចូលមកយាយីក្នុងឆាកជីវិត ដើម្បីរកថវិកាឲ្យកូនមានឱកាសបានសិក្សា នៅសាកលវិទ្យាល័យដ៏ល្បីឈ្មោះមួយ ក្នុងទីក្រុងភ្នំពេញ អស់រយៈពេល៤ឆ្នាំ ប្រកបដោយភាពជោគជ័យជាស្ថាពរ ដោយមានរបាយការណ៍កម្មសិក្សា មួយច្បាប់នេះជាភស្តុតាង។
- ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ ជាពិសេស **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខថ្នាក់ដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់ក្នុងការអភិវឌ្ឍន៍ និងស្តារខឿនសេដ្ឋកិច្ចជាតិ តាំងពីចំនុចសូន្យ រហូតដល់រីកចំរើនដូចសព្វថ្ងៃ។ ជាពិសេស គឺវិស័យអប់រំផ្ទាល់តែម្តង តាមរយៈការរីកស្គុសស្គាយនៃសាលារៀន និងសាកលវិទ្យាល័យ នៅគ្រប់ ខេត្ត ក្រុង ដែលបង្កជាលក្ខណៈងាយស្រួលច្រើនយ៉ាងដល់កុលបុត្រ កុលធីតាខ្មែរក្នុងការក្រេបជញ្ជក់យកចំនេះដឹង។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកប្រធាន និងអនុប្រធានការិយាល័យស្រាវជ្រាវ លោក-លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលបានចំនាយកម្លាំងកាយ និងពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្ហាញគ្រប់មុខវិជ្ជាដែលពាក់ព័ន្ធ តាមជំនាញ និងបទពិសោធន៍ជាក់ស្តែងដែលលោកមានដល់យើងខ្ញុំជានិស្សិតទាំងអស់គ្នា។ លើសពីនេះទៀត លោកបានផ្តល់ឱកាសដ៏មហាសាលបំផុតសម្រាប់យើងខ្ញុំទាំងពីរនាក់ ក្នុងការស្រាវជ្រាវរបាយការណ៍

មួយច្បាប់នេះ ទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយ និងជាបទពិសោធន៍ដ៏មានតម្លៃបំផុតក្នុងឆាកជីវិត។

- លោកស្រីសាស្ត្រាចារ្យ **ឡុង ម៉ាមីឌី** ដែលជាសាស្ត្រាចារ្យដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់ក្នុងការរិះរកនូវគំនិតល្អៗ និង គន្លឹះសំខាន់ៗមួយចំនួន ដើម្បីទ្រទ្រង់ខ្លឹមសារកិច្ចការនេះ ព្រមទាំងផ្តល់ជាយោបល់ល្អៗក្នុងការកែលម្អនូវចំនុចខ្វះខាតរបស់យើងខ្ញុំ។ អ្នកគ្រូបានចំនាយទាំងកម្លាំងកាយ និងចិត្ត រួមទាំងពេលវេលាផ្ទាល់ខ្លួន ក្នុងការដឹកនាំ និងតម្រង់ទិសការស្រាវជ្រាវកិច្ចការមួយច្បាប់នេះប្រកបដោយភាពរលូន។

- លោកអគ្គនាយកក្រុមហ៊ុន ខេមរីល គ្លូប៊ល ខូអិលធីឌី ព្រមទាំងបុគ្គលិកទាំងអស់ ដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងចំនាយពេលវេលាក្នុងការបង្ហាត់បង្ហាញ ចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗដល់យើងខ្ញុំ ជាពិសេសលោកបានផ្តល់ឱកាសឲ្យយើងខ្ញុំបានចុះកម្មសិក្សានៅក្រុមហ៊ុនលោក ថែមទាំងបានផ្តល់ឯកសារពាក់ព័ន្ធមួយចំនួនសម្រាប់ចងក្រងសៀវភៅនេះ។

- បណ្តាមិត្តរួមសាកលវិទ្យាល័យទាំងអស់ ជាពិសេសមិត្តភក្តិរួមជំនាន់ទី ១០ ក្រុម $B_4B_1$ ដែលបានលើកទឹកចិត្ត និងចូលរួមផ្តល់ជាយោបល់ល្អៗដល់ក្រុមយើងខ្ញុំ ក្នុងការស្រាវជ្រាវលើប្រធានបទនេះ។

ជាថ្មីម្តងទៀត យើងខ្ញុំសូមសម្តែងនូវអំណរគុណ និងការដឹងគុណជាអនេកកប្បការចំពោះលោកអ្នកមានគុណទាំងអស់ និងសូមប្រសិទ្ធពរជ័យ ដល់ពួកគាត់ទាំងអស់គ្នាឲ្យជួបប្រទះតែសេចក្តីសុខ សំណាងល្អ ទទួលបានជ័យជំនះគ្រប់ភារកិច្ច ពោលគឺពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

រយៈពេល៤ឆ្នាំកន្លងមក នៃការសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានឆ្លងកាត់ការបណ្តុះបណ្តាលជាច្រើនពាក់ព័ន្ធនឹងមុខវិជ្ជាគោល ដូចជាសេចក្តីផ្តើមអំពីធនាគារ និងហិរញ្ញវត្ថុបុគ្គលជាដើម ហើយក៏មានមុខវិជ្ជាសំខាន់ៗដទៃទៀតដែលផ្តល់អត្ថប្រយោជន៍ច្រើនក្នុងទីផ្សារការងារជាក់ស្តែងដូចជា គណនេយ្យ និង ពន្ធដារ ជាដើម។ ក្នុងចំនោមមុខវិជ្ជាដែលបានសិក្សាទាំងអស់ យើងខ្ញុំមានការចាប់អារម្មណ៍ខ្លាំងទៅលើ ពន្ធដារកម្ពុជា ដែលជាប្រភពចំនូលធំរបស់ប្រទេស និងជាវិស័យមួយដែលកំពុងមានការរីកចំរើន និងទទួលបានការចាប់អារម្មណ៍ខ្លាំងពីសំណាក់សាធារណៈជន ព្រោះអ្នកណាក៏មានកាតព្វកិច្ចបង់ពន្ធដែរ។

ការប្រកាសពន្ធគឺជាកាតព្វកិច្ចចាំបាច់របស់ម្ចាស់ក្រុមហ៊ុន សហគ្រាស ឬបុគ្គលទាំងអស់ ដូចនេះទាមទារអោយគណនេយ្យករ ភ្នាក់ងារសេវាកម្មពន្ធដារ ក៏ដូចជាភាគីពាក់ព័ន្ធទាំងអស់ត្រូវចូលរួមយល់ដឹង និងសហប្រតិបត្តិការអោយបានខ្ជាប់ខ្ជួនទាំងអស់គ្នា។ ជាពិសេសបទបញ្ញត្តិ ក៏ដូចជានីតិវិធីផ្សេងៗរបស់ពន្ធដារ មានការផ្លាស់ប្តូរ និងអភិវឌ្ឍន៍ថ្មីៗ អោយស្របតាមការអភិវឌ្ឍន៍របស់ប្រទេសជាតិ។ ហេតុនេះហើយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសយុវសិស្សជំនាន់ក្រោយត្រូវចាប់ផ្តើមយកចិត្តទុកដាក់ ក្នុងការទទួលយកព័ត៌មានថ្មីៗ និងប្រតិបត្តិតាមទៅតាមការគួរ។ យើងខ្ញុំពិតជាមានក្តីសោមនស្សរីករាយណាស់ ដែលបានលើកយកប្រធានបទជាចំនុចក្តៅក្នុងសង្គមសព្វថ្ងៃ ថែមទាំងជាក្តីពេញចិត្តផ្ទាល់ខ្លួនទៀត។ កិច្ចការស្រាវជ្រាវនេះនឹងនាំអារម្មណ៍មិត្តអ្នកអានទៅជួបជាមួយចំនីអារម្មណ៍ប្លែកដែលនឹងបកស្រាយពី នីតិវិធីក្នុងការប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងបានលើកឡើងពន្យល់បន្ថែមពីលើនីតិវិធីមានស្រាប់ គឺដំណើរការការប្រកាសពន្ធផ្ទាល់ របស់ក្រុមហ៊ុនឯកជនមួយកន្លែង ដែលជាអ្នកជាប់ពន្ធមធ្យម។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចការស្រាវជ្រាវមួយក្បាលនេះ នឹងជួយរំលែកនូវភាពស្មុគ្រស្មាញទាំងឡាយដែលអ្នកអានជួបប្រទះ ហើយយើងខ្ញុំសូមទទួលស្គាល់ថា កិច្ចការនេះមិនទាន់មានភាពល្អប្រសើរគ្រប់ជ្រុងជ្រោយនៅឡើយទេ ដូចនេះយើងខ្ញុំសូមសំដែងនូវក្តីសាទរជានិច្ច ចំពោះពាក្យពេចន៍សរសើរទាំងឡាយ ក៏ដូចជាមតិរិះគន់ ដើម្បីអភិវឌ្ឍន៍រាល់ចំនុចខ្វះខាតទាំងអស់តាមដែលអាចធ្វើបាន។

# មាតិកា


បញ្ជីអក្សរកាត់ ........ v
បញ្ជីតារាង ........ vi
បញ្ជីរូបភាព ........ vii
បញ្ជីដ្យាក្រាម ........ viii
បញ្ជីឧបសម្ព័ន្ធ ........ ix


## សេចក្ដីផ្ដើម


១.លំនាំបញ្ហា ........ ១
២.ចំណោទបញ្ហា ........ ២
៣.គោលបំណងនៃការស្រាវជ្រាវ ........ ២
៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣
៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៦.វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៤
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦


## ជំពូកទី ១
## គោលការណ៍ទូទៅ និងប្រភេទពន្ធស្វ័យប្រកាស


១.១ គោលការណ៍ទូទៅនៃពន្ធដារ ........ ៧
១.១.១ និយមន័យ ........ ៧
១.១.២ បុព្វហេតុនៃការប្រមូលពន្ធ ........ ៧
១.១.៣ ប្រព័ន្ធកំណត់ពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា ........ ៨
១.២ នីតិវិធីក្នុងការប្រកាសពន្ធ ........ ៩
១.២.១ ការចុះបញ្ជីពន្ធដារ ........ ៩
១.២.១.១ ការស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានក្រុមហ៊ុនដែលបានចុះបញ្ជី ........ ១០
១.២.១.២ តំណាងអ្នកជាប់ពន្ធ ........ ១០
១.២.២ ដំណើរការដាក់លិខិតប្រកាសពន្ធ ........ ១១
១.២.៣ កាលបរិច្ឆេទនៃការបង់ពន្ធ ........ ១១
១.២.៤ ពន្ធបន្ថែម និងទោសទណ្ឌ ........ ១២

១.២.៤.១ ពន្ធបន្ថែមចំពោះការបង់ពន្ធខ្វះ ........ ១២
១.២.៤.២ ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធ ........ ១៣
១.២.៤.៣ ពន្ធបន្ថែមចំពោះអំពើរាំងស្ទះការអនុវត្តន៍បទបញ្ញត្តិស្តីពីពន្ធដារ ........ ១៣
១.២.៤.៤ ទោសទណ្ឌ ........ ១៣
១.៣ ប្រភេទពន្ធប្រកាសប្រចាំខែ ........ ១៤
១.៣.១ ពន្ធលើប្រាក់បៀវត្ស (Tax on Salary) ........ ១៤
១.៣.១.១ និយមន័យ ........ ១៤
១.៣.១.២ មូលដ្ឋានគិតពន្ធប្រាក់បៀវត្ស ........ ១៤
១.៣.១.៣ របៀបគណនាពន្ធលើប្រាក់បៀវត្ស ........ ១៦
១.៣.១.៤ ពន្ធលើអត្ថប្រយោជន៍បន្ថែម (Fringe Benefit Tax) ........ ១៦
១.៣.២ ពន្ធកាត់ទុក (Withholding Tax) ........ ១៧
១.៣.២.១ ពន្ធកាត់ទុកលើការទូទាត់ឲ្យនិវាសនជន ........ ១៨
១.៣.២.២ ការទូទាត់ដែលទទួលបានការលើកលែងពន្ធកាត់ទុក ........ ១៨
១.៣.២.៣ ពន្ធកាត់ទុកលើការទូទាត់ឲ្យអនិវាសជន ........ ១៩
១.៣.៣ អាករលើតម្លៃបន្ថែម( Value Added Tax ) ........ ១៩
១.៣.៣.១ ការផ្គត់ផ្គង់ជាប់អាករ ........ ១៩
១.៣.៣.២ ការផ្គត់ផ្គង់មិនជាប់អាករ ........ ១៩
១.៣.៣.៣ អត្រាអាករលើតម្លៃបន្ថែម ........ ២០
១.៣.៣.៤ ការគណនាប្រាក់អាករត្រូវបង់ ........ ២០
១.៣.៣.៥ អាករលើធាតុចូលដែលមិនអាចកាត់កងបាន ........ ២០
១.៣.៣.៦ សំណើសុំឥណទានអាករលើធាតុចូល ........ ២១
១.៣.៤ អាករពិសេស (Specific Tax) ........ ២១
១.៣.៥ អាករបំភ្លឺសាធារណៈ ( Tax on Public Lighting ) ........ ២៣
១.៣.៦ អាករលើការស្នាក់នៅ (Accommodation Tax) ........ ២៤
១.៣.៧ ពន្ធប្រាក់រំដោះ( Prepayment of Profit Tax ) ........ ២៥
១.៤ ប្រភេទពន្ធប្រកាសប្រចាំឆ្នាំ ........ ២៧
១.៤.១ ពន្ធប៉ាតង់ (Patent Tax) ........ ២៧

១.៤.១.១ និយមន័យ ............................................................................................................ ២៧
១.៤.១.២ ការលើកលែងពន្ធប៉ាតង់ .................................................................................... ២៧
១.៤.១.៣ កាលបរិច្ឆេទ និងទីកន្លែងបង់ពន្ធ ........................................................................ ២៨
១.៤.១.៤ កម្រិតប្រាក់ពន្ធប៉ាតង់ ......................................................................................... ២៨
១.៤.១.៥ ការផ្លាស់ប្តូរ .......................................................................................................... ២៩
១.៤.២ ពន្ធលើប្រាក់ចំណេញ (Tax on Profit) ........................................................................ ២៩
១.៤.២.១ និយមន័យ ............................................................................................................ ២៩
១.៤.២.២ អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ .................................................................... ២៩
១.៤.២.៣ ប្រាក់ចំណេញជាប់ពន្ធ ........................................................................................ ៣០
១.៤.២.៤ ចំណាយអាជីវកម្ម ................................................................................................. ៣១
១.៤.២.៥ របាយការណ៍លទ្ធផល និងតារាងតុល្យការ ........................................................... ៣២
១.៤.២.៦ វិភាគទានសប្បុរសធម៌ ........................................................................................ ៣៣
១.៤.២.៧ ចំណាយការប្រាក់ ................................................................................................. ៣៣
១.៤.២.៨ ឥណទានខាតយោងទៅមុខ .................................................................................. ៣៤
១.៤.២.៩ រំលស់តាមច្បាប់សារពើពន្ធ ................................................................................. ៣៤
១.៤.២.១០ សំវិធានធន ........................................................................................................ ៣៥
១.៤.២.១១ បំណុលពន្ធលើប្រាក់ចំនេញត្រូវបង់ ..................................................................... ៣៦
១.៤.២.១២ ពន្ធលើប្រាក់ចំណេញត្រូវបង់ ឬត្រូវយោងទៅឆ្នាំបន្ទាប់ ..................................... ៣៦
១.៤.២.១៣ ការគណនាពន្ធលើប្រាក់ចំណេញ .......................................................................... ៣៧

## ជំពូកទី ២

## ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ខេមវីល គ្លូបិល ខូអិលធីឌី

២.១ ប្រវត្តិរបស់ក្រុមហ៊ុន .......................................................................................................... ៣៩
២.២ ទីតាំង ស្លាកសញ្ញា និងការចុះបញ្ជីអាជីវកម្ម ........................................................................ ៣៩
២.៣ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ ..................................................................................... ៤០
២.៤ ដៃគូពាណិជ្ជកម្ម ................................................................................................................... ៤១
២.៥ សកម្មភាពរបស់ក្រុមហ៊ុន ....................................................................................................... ៤២
២.៦ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ..................................................................................................... ៤៤

## ជំពូកទី ៣

## លទ្ធផលនៃការស្រាវជ្រាវ

៣.១ ការចុះបញ្ជីពន្ធដាររបស់ក្រុមហ៊ុន ........................................ ៤៥
៣.២ ដំណើរការការប្រកាសពន្ធប្រចាំខែ ........................................ ៤៥
៣.២.១ ការប្រមូលឯកសារ ........................................ ៤៦
៣.២.២ ការរៀបចំឯកសារ ........................................ ៤៧
៣.២.៣ ការបំពេញលិខិតប្រកាសពន្ធ ........................................ ៥៤
៣.២.៤ ការបង់ប្រាក់នៅធនាគារ ........................................ ៥៩
៣.២.៥ ការដាក់លិខិតប្រកាសពន្ធនៅសាខាពន្ធដារ ........................................ ៦០
៣.៣ ដំណើរការការប្រកាសពន្ធប្រចាំឆ្នាំ ........................................ ៦១
៣.៣.១ ពន្ធប៉ាតង់ ........................................ ៦១
៣.៣.២ ពន្ធលើប្រាក់ចំណេញ ........................................ ៦៣
៣.៤ របាយការណ៍ចំណាយបង់ពន្ធសរុប ........................................ ៧៣
៣.៤.១ ចំណាយបង់ពន្ធប្រចាំខែសរុប ........................................ ៧៣
៣.៤.២ ចំណាយបង់ពន្ធប្រចាំឆ្នាំសរុប ........................................ ៧៥

## ជំពូកទី ៤

## ការវិភាគ SWOT

៤.១ ចំនុចខ្លាំង ........................................ ៧៦
៤.២ ចំនុចខ្សោយ ........................................ ៧៦
៤.៣ បញ្ហាប្រឈម ........................................ ៧៧
៤.៥ ឱកាស ........................................ ៧៧

## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ........................................ ៧៨
២. អនុសាសន៍ ........................................ ៧៩
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- ចសព : ច្បាប់សារពើពន្ធកម្ពុជា
- បវ : បៀវត្ស
- ពបវ : ពន្ធលើប្រាក់បៀវត្ស
- ពបច : ពន្ធលើប្រាក់ចំណេញ
- អតប : អាករលើតម្លៃបន្ថែម
- AT : Accommodation Tax
- CWG : Camwill Global Co.,LTD
- MMT : Minimum Tax
- Non QIP : Non-Qualified Investment Project (គម្រោងវិនិយោគមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)
- PPT : Prepayment of Profit Tax
- QIP : Qualified Investment Project (គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)
- TOP : Tax on Profit
- TPL : Tax on Public Lighting
- VAT : Value Add Tax
- WHT : Withholding Tax

# បញ្ជីតារាង


តារាងទី ១៖ ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ........................................................................ ១៤
តារាងទី ២៖ ការគណនាពន្ធលើប្រាក់បៀវត្សរបស់និវាសនជនកម្ពុជា .................................. ១៦
តារាងទី ៣៖ ការគណនាពន្ធលើប្រាក់បៀវត្សរបស់អនិវាសនជនកម្ពុជា ................................ ១៦
តារាងទី ៤៖ ការគណនាពន្ធអត្ថប្រយោជន៍បន្ថែមនៃនិវាសនជន និងអនិវាសជនកម្ពុជា .......... ១៧
តារាងទី ៥៖ អត្រាពន្ធកាត់ទុកលើការទូទាត់ឲ្យនិវាសនជន ................................................... ១៨
តារាងទី ៦៖ មូលដ្ឋានគិតពន្ធប៉ាតង់ ........................................................................................ ២៨
តារាងទី ៧៖ តារាងប្រភេទ និងអត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ..................................... ៣០
តារាងទី ៨៖ ទំនាក់ទំនងនៃរបាយការណ៍លទ្ធផល និងតារាងគណនាពន្ធលើប្រាក់ចំណេញ .. ៣០
តារាងទី៩៖ គណនាពន្ធលើប្រាក់ចំណេញ ....................................................................... ៣៧
តារាងទី១០៖ របាយការណ៍លទ្ធផលប្រចាំឆ្នាំ (CWG) ........................................................... ៦៥
តារាងទី១១៖ តារាងតុល្យការ (ផ្នែកទ្រព្យសកម្ម) ................................................................ ៦៦
តារាងទី១២៖ តារាងតុល្យការ (ផ្នែកមូលនិធិ/ទុនម្ចាស់ទ្រព្យ និងបំណុល) .............................. ៦៧
តារាងទី១៣៖ តារាងគណនាពន្ធលើប្រាក់ចំណេញ (CWG) .................................................. ៧០
តារាងទី១៤៖ តារាងរបាយការណ៍សរុបនៃការបង់ពន្ធប្រចាំខែ(ឆ្នាំ២០១៦)គិតជារៀល ........... ៧៣
តារាងទី១៥៖ របាយការណ៍សរុបនៃការបង់ពន្ធប្រចាំខែ(ឆ្នាំ២០១៧)គិតជារៀល .................... ៧៣

# បញ្ជីរូបភាព


រូបភាពទី១៖ ស្លាកសញ្ញារបស់ក្រុមហ៊ុនខេមរីល គ្លូប៊ល ........................ ៤០
រូបភាពទី២៖ គំរូបញ្ជីប្រាក់បៀវត្សបុគ្គលិក ........................ ៤៧
រូបភាពទី៣៖ អត្រាប្តូរប្រាក់សម្រាប់ប្រាក់បៀវត្ស ........................ ៤៨
រូបភាពទី៤៖ គំរូតារាងគណនាពន្ធលើប្រាក់បៀវត្សនិវាសនជន ........................ ៥០
រូបភាពទី៥៖ គំរូសៀវភៅទិន្នានុប្បវត្តិទិញ ........................ ៥១
រូបភាពទី៦៖ គំរូសៀវភៅទិន្នានុប្បវត្តិលក់ ........................ ៥៣
រូបភាពទី៧៖ ព័ត៌មានសហគ្រាសក្នុងលិខិតប្រកាសប្រចាំខែ ........................ ៥៤
រូបភាពទី៨៖ បំពេញលិខិតប្រកាសប្រាក់រំដោះលើប្រាក់ចំណេញ ........................ ៥៥
រូបភាពទី៩៖ បំពេញលិខិតប្រកាសប្រាក់រំដោះលើប្រាក់ចំណេញផ្នែកខាងក្រោយ ........................ ៥៦
រូបភាពទី១០៖ បំពេញលិខិតប្រកាសពន្ធលើប្រាក់បៀវត្ស ........................ ៥៧
រូបភាពទី១១៖ បំពេញលិខិតប្រកាសអាករលើតម្លៃបន្ថែម ........................ ៥៨
រូបភាពទី១២៖ បំពេញលិខិតប្រកាសពន្ធកាត់ទុក ........................ ៥៩
រូបភាពទី១៣៖ តារាងលម្អិតអំពីពន្ធកាត់ទុកនិវាសនជន ........................ ៥៩
រូបភាពទី១៤៖ បំពេញព័ត៌មានទូទៅរបស់សហគ្រាស ........................ ៦៤
រូបភាពទី១៥៖ រំលស់ទ្រព្យរូបីថ្នាក់២ ដល់ថ្នាក់៤ ........................ ៦៩
រូបភាពទី១៦៖ តារាងតាមដានលទ្ធផលខាតយោងទៅមុខ ........................ ៧០
រូបភាពទី១៧៖ បំពេញឥណទានពន្ធយោងទៅមុខ ........................ ៧៣

# បញ្ជីដ្យាក្រាម

ដ្យាក្រាមសរសេរដេកទី១៖ប្រៀបធៀបចំនាយបង់ពន្ធពីខែមិថុនា ២០១៦ ដល់ខែមីនា២០១៧ ..៧៤

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១៖  បទបញ្ញត្តិផ្សេងៗស្តីពីពន្ធស្វ័យប្រកាស

ឧបសម្ព័ន្ធទី២៖  ព័ត៌មានក្នុងលិខិតប្រកាសពបច

ឧបសម្ព័ន្ធទី៣៖  វិញ្ញាបនបត្រចុះបញ្ជី និងបណ្ណប៉ាតង់

ឧបសម្ព័ន្ធទី៤៖  ឯកសារប្រកាសពន្ធប្រចាំខែមីនា ២០១៧

ឧបសម្ព័ន្ធទី៥៖  ឯកសារប្រកាសពបចប្រចាំឆ្នាំ ២០១៦

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

រាល់ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ជាតិមួយ គឺតែងតែមានការចូលរួមចំណែកគ្នាពីបណ្តាក្រសួងស្ថាប័ន ក្របខ័ណ្ឌ និងវិស័យនានាក្នុងការស្តារ និងធ្វើឲ្យមានការវិវត្តន៍ទៅរកភាពជឿនលឿន រីកចម្រើនដែលអាស្រ័យទៅលើគោលនយោបាយ និងចក្ខុវិស័យរបស់បណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធទាំងនោះ។ យ៉ាងណាមិញនៅក្នុងវិស័យសេដ្ឋកិច្ចនេះផងដែរ យើងសង្កេតឃើញមានផ្នែកមួយដែលជាផ្នែកសំខាន់ក្នុងការពន្លឿននូវកំណើនចំណូលជាតិនោះ គឺប្រព័ន្ធពន្ធដារ។ ជាការពិតណាស់ គ្រប់បណ្តាប្រទេសនានា រួមទាំងប្រទេសកម្ពុជាយើងផងដែរ ប្រព័ន្ធពន្ធដារ គឺត្រូវបានយកមកអនុវត្ត និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ស្ទើរតែគ្រប់សម័យកាលមកហើយ។

បើយើងក្រឡេកមើលពីស្ថានភាពសេដ្ឋកិច្ច ដោយផ្តោតទៅលើវិស័យសំខាន់មួយក្នុងចំណោមវិស័យផ្សេងៗទៀត ដែលយើងហៅថាវិស័យពន្ធដារនេះវិញ គឺអាចនិយាយបានថាប្រទេសកម្ពុជាយើងសព្វថ្ងៃ បាននឹងកំពុងបន្តអនុវត្តជាអចិន្ត្រៃយ៍យ៉ាងសកម្ម នូវរបបមួយដែលមានឈ្មោះថា របបពិត ឬរបបស្វ័យប្រកាសមួយប៉ុណ្ណោះ ដែលកាលពីមុនប្រព័ន្ធពន្ធដារក្នុងប្រទេសកម្ពុជាមានដល់ទៅពីររបប គឺរបបពិត និងរបបមៅការ។ ហេតុដូច្នេះហើយមិនថាអ្នកធុរកិច្ច អ្នកសេដ្ឋកិច្ច អ្នកហិរញ្ញវត្ថុ គណនេយ្យករ និងអ្នកជាប់ពាក់ព័ន្ធដទៃទៀតដែលជាអ្នកជាប់កាតព្វកិច្ចពន្ធ ដាច់ខាតត្រូវតែមានចំនេះដឹងអំពីប្រព័ន្ធពន្ធដារ។ ដោយមើលឃើញពីការយល់ដឹងនូវដំណើរការប្រកាសពន្ធនៅមានកម្រិត និងការធ្វើបច្ចុប្បន្នភាពព័ត៌មានជារឿយៗរបស់អគ្គនាយកដ្ឋានពន្ធដារ ទើបយើងខ្ញុំជានិស្សិតធ្វើការសិក្សារកចំនុចល្អៗមកបំពេញចំនុចខ្វះខាតមួយចំនួន ដែលជាចម្ងល់របស់មិត្តអ្នកអានទាំងអស់គ្នាទាក់ទងនឹងប្រព័ន្ធពន្ធដារកម្ពុជានេះ។ មិនតែប៉ុណ្ណោះ យើងខ្ញុំបានធ្វើការសិក្សាបន្ថែមលើខ្លឹមសារមួយចំនួនដែលជាព័ត៌មានថ្មីៗចេញផ្សាយដោយអគ្គនាយកដ្ឋានពន្ធដារ មកធ្វើការអធិប្បាយ ដើម្បីអោយមិត្តអ្នកអានទាំងអស់គ្នា តាមទាន់នូវការវិវត្តន៍ការអនុវត្តប្រព័ន្ធពន្ធដារ និងកាន់តែមានទំនុកចិត្តលើរបាយការណ៍មួយក្បាលនេះ។ ជាពិសេស ក្រុមយើងខ្ញុំ នឹងលើកយកការអនុវត្តការប្រកាសពន្ធជាក់ស្តែងរបស់ក្រុមហ៊ុនឯកជនមួយកន្លែង ដើម្បីធ្វើការបកស្រាយពន្យល់ អោយកាន់តែច្បាស់បន្ថែមពីលើនីតិវិធី ដែលមានស្រាប់។

ដោយសារតែ របបស្វ័យប្រកាសជារបបដែលមានលក្ខណៈស្មុគ្រស្មាញច្រើន ហើយកាន់តែមានភាពលំបាកពេលដែលត្រូវបង់ពន្ធជូនរដ្ឋម្តងៗ។ ជាពិសេសអ្នកដែលប្រឈមមុខជាមួយបញ្ហា

ទាំងអស់នេះ គឺអ្នកទាំងឡាយណាដែលទទួលភារៈជាអ្នកបង់ពន្ធ ដូចជា ភ្នាក់ងារសេវាបង់ពន្ធ និងគណនេយ្យករ បម្រើការក្នុងក្រុមហ៊ុន ឬសហគ្រាសជាដើម។ ដូចនេះហើយ ដើម្បីឲ្យកាន់តែបានយល់ដឹងពីការអនុវត្តជាក់ស្តែង និងកាត់បន្ថយការលំបាក ក៏ដូចជាជួយសម្រាលភារៈរបស់អ្នកទាំងនោះ និងផ្តល់ជាចំនេះដឹងបន្ថែមដល់មិត្តអ្នកអានទាំងឡាយ ព្រមទាំងបង្រួមនូវគម្លាតភ័ន្តច្រលំ ហើយបន្ថែមចំនេះដឹងឲ្យកាន់តែច្បាស់នូវរាល់ចំនុចដែលទាក់ទងនឹងនីតិវិធី និងការអនុវត្តការប្រកាសពន្ធ ដើម្បីធានាឲ្យការប្រកាសពន្ធប្រព្រឹត្តទៅដោយរលូនរវាងមន្ត្រីពន្ធដារ និងអ្នកមានភារៈត្រូវបង់ពន្ធប្រកបដោយភាពវិជ្ជមាន។ ក្រុមយើងខ្ញុំដែលជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រហិរញ្ញវត្ថុ និងធនាគារ បានធ្វើការចុះកម្មសិក្សា ស្រាវជ្រាវ និងរៀបចំចងក្រងផ្តោតសំខាន់លើប្រធានបទមួយស្តីពី «នីតិវិធី និងការអនុវត្តការប្រកាសពន្ធរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ល ខូអិលធីឌី»។

## ២.ចំណោទបញ្ហា

ក្នុងកិច្ចការស្រាវជ្រាវនេះ នឹងពន្យល់ណែនាំយ៉ាងលម្អិតអំពី នីតិវិធី និងការអនុវត្តការប្រកាសពន្ធរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ល ខូអិលធីឌី ដូចនេះដើម្បីបំផុសជាគំនិតខ្លះៗ និងបង្កភាពកាន់តែងាយស្រួលដល់មិត្តអ្នកអានក្នុងការតាមដានខ្លឹមសាររបាយការណ៍មួយនេះ យើងខ្ញុំបានរៀបចំចងក្រងជាសំនួរគន្លឹះៗមួយចំនួនដូចជា៖

- តើនីតិវិធីក្នុងការប្រកាសពន្ធស្វ័យប្រកាសមានលក្ខណៈដូចម្តេច?
- តើដំណើរការក្នុងការប្រកាសពន្ធរបស់ក្រុមហ៊ុនមានលក្ខណៈដូចម្តេច?
- តើការចំណាយក្នុងការបង់ពន្ធប្រចាំខែរបស់ក្រុមហ៊ុន ពី ១ខែ ទៅ ១ខែ មានការប្រែប្រួលដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺដើម្បីស្វែងយល់អោយកាន់តែច្បាស់ពី៖

- នីតិវិធីនៃការប្រកាសពន្ធស្វ័យប្រកាសស្របតាមច្បាប់សារពើពន្ធនៃកម្ពុជា
- យល់ដឹងពីកាតព្វកិច្ចអ្នកជាប់ពន្ធ
- និយមន័យ និងលក្ខណៈទូទៅនៃប្រភេទពន្ធស្វ័យប្រកាសនីមួយៗ
- ស្ថានភាពទូទៅនៃក្រុមហ៊ុនខេមរីល គ្លូប៊ល ខូអិលធីឌី
- ដំណើរការជាក់ស្តែងនៃការប្រកាសពន្ធស្វ័យប្រកាសរបស់ក្រុមហ៊ុន

- ស្វែងយល់ពីចំនុចវិជ្ជមានមួយចំនួនដែលធ្វើឲ្យក្រុមហ៊ុនប្រកាសពន្ធកន្លងមកបានរលូន

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងកិច្ចការស្រាវជ្រាវនេះ នឹងធ្វើការលើកយកប្រភេទពន្ធស្វ័យប្រកាសសំខាន់ៗចំនួន ៩ មកធ្វើការសិក្សា និងនីតិវិធីនៃការប្រកាសពន្ធដែលអ្នកជាប់ពន្ធទាំងឡាយត្រូវបំពេញរួមមាន ការចុះបញ្ជីពន្ធដារ ការប្រកាសពន្ធ និងបំណុលពន្ធ ដែលបានចែងក្នុងច្បាប់សារពើពន្ធ និងបច្ចុប្បន្នភាពព័ត៌មានថ្មីៗ ពិសេសគឺការលើកយកនូវការអនុវត្តការប្រកាសពន្ធស្វ័យប្រកាសជាក់ស្តែងរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ល ខូអិលធីឌី ដែលជាអ្នកជាប់ពន្ធមធ្យមមកបង្ហាញពីការប្រកាសពន្ធក្នុងកំលុងរយៈពេល៩ខែ គិតចាប់ពីខែមិថុនា ឆ្នាំ ២០១៦ រហូតដល់ខែមីនា ឆ្នាំ២០១៧ មកធ្វើការបង្ហាញ បកស្រាយ ពន្យល់ និងវិភាគ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះ នឹងផ្តល់នូវសារៈសំខាន់មួយចំនួនដូចខាងក្រោម៖

❖ សម្រាប់ខ្លួនយើងផ្ទាល់

- ទទួលបានបទពិសោធន៍ជាក់ស្តែង សម្រាប់ជាប្រយោជន៍ក្នុងការស្វែងរកការងារធ្វើនាពេលអនាគត
- ទទួលបានចំនេះដឹងផ្នែកប្រកាសពន្ធថែមមួយកម្រិតទៀត
- បង្កើតទំនាក់ទំនងក្នុងមជ្ឈដ្ឋានការងារពិត
- បណ្តុះអោយមានគំនិតស្វ័យសិក្សា
- យល់ដឹងពីបញ្ហាដែលអាចជួបប្រទះ និងវិធីក្នុងការដោះស្រាយ

❖ សម្រាប់ក្រុមហ៊ុនផ្ទាល់

- ដឹងពីសុខុមាលភាពនៃដំណើរការការប្រកាសពន្ធរបស់ខ្លួន
- ស្វែងយល់ពីចំនុចខ្លាំង និងចំនុចខ្សោយ
- ទទួលបានមតិយោបល់ពីអ្នកសិក្សាជំនាន់ក្រោយ

❖ សម្រាប់សង្គមជាតិ

- សំបូរឯកសារ និងអ្នកជំនាញផ្នែកពន្ធដារ
- កាត់បន្ថយនូវការលួចកិបកេងប្រាក់ក្នុងការបង់ពន្ធ
- ជំរុញអោយគ្រប់ក្រុមហ៊ុនទាំងអស់ព្យាយាមអនុវត្តការប្រកាសពន្ធបានត្រឹមត្រូវ
- លើកកំពស់ប្រាក់ចំនូលរបស់រដ្ឋ។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ដើម្បីឲ្យការស្រាវជ្រាវមួយនេះ ទទួលបានការជោគជ័យ និងបានបញ្ចប់ដោយរលូន ព្រមទាំងជារបាយការណ៍ដែលទុកគួរជាទីទុកចិត្តបាន យើងត្រូវយល់ច្បាស់ពីប្រធានបទដែលកំពុងសិក្សាតម្រូវឲ្យមានទិន្នន័យអ្វីខ្លះ ហើយត្រូវប្រមូលទិន្នន័យនោះដោយរបៀបណា ពិសេសពេលបានទទួលទិន្នន័យនោះគ្រប់គ្រាន់ហើយ តើត្រូវប្រើវិធីសាស្ត្រអ្វីមកធ្វើការពន្យល់ បង្ហាញ និងវិភាគទិន្នន័យទាំងនោះ។

❖ តម្រូវការទិន្នន័យ

ទិន្នន័យដែលប្រើប្រាស់សម្រាប់ធ្វើការបង្ហាញ បកស្រាយ ពន្យល់ និងវិភាគ ព្រមទាំងសម្រាប់ទ្រទ្រង់របាយការណ៍កម្មសិក្សានេះ មានពីរប្រភេទគឺ ទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ៖

- ទិន្នន័យចម្បង (Primary Data)៖ ជាទិន្នន័យដែលបានមកពីការសម្ភាសន៍តាមរយៈការចុះសាកសួរបុគ្គលជាប់ដែលមានជំនាញពាក់ព័ន្ធនឹងប្រធានបទ ពីមតិយោបល់ គំនិតផ្ទាល់ខ្លួន និងតាមរយៈការអង្កេត ស្វែងយល់ពីទិន្នន័យថ្មីដែលមិនទាន់បានស្រាវជ្រាវ និងវិភាគពីមុនមក។
- ទិន្នន័យបន្ទាប់បន្សំ (Secondary Data)៖ គឺជាប្រភេទទិន្នន័យដែលមានស្រាប់ទាក់ទងនឹងសៀវភៅរបស់អ្នកនិពន្ធនានា ច្បាប់ ប្រកាស និងឯកសារព័ត៌មានពីស្ថាប័នដែលទាក់ទង ឬឯកសារនានាពីអ៊ីនធឺណេត ដែលមានគ្រប់គ្រាន់ សម្រាប់ធ្វើការទ្រទ្រង់របាយការណ៍នេះបាន។

❖ ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ ត្រូវបានធ្វើឡើងខុសគ្នាអាស្រ័យតាមប្រភេទនៃទិន្នន័យពីរខាងក្រោម៖

- ទិន្នន័យចម្បង៖ ដើម្បីទទួលបានទិន្នន័យចម្បងនេះ យើងបានប្រមូលព័ត៌មានដោយការចុះអនុវត្តផ្ទាល់ សង្កេត និងរៀបចំកម្រងសំនួរចុះសម្ភាសបុគ្គល ក្នុងអង្គភាពចុះកម្មសិក្សាផ្ទាល់ដូចជាអ្នកតំណាងអ្នកជាប់ពន្ធ គណនេយ្យករ ប្រធានផ្នែកហិរញ្ញវត្ថុ និងនាយកគ្រប់គ្រងទូទៅ អំពីមតិយោបល់ គំនិត និងដំណោះស្រាយផ្ទាល់ខ្លួនអំពីប្រធានបទ។ បន្ថែមពីនោះ យើងក៏បានសាកសួរពីបុគ្គលខាងក្រៅដែលមានចំណេះដឹងទាក់ទងនឹងប្រធានបទផងដែរ។

- ទិន្នន័យបន្ទាប់បន្សំ៖ ចំពោះទិន្នន័យប្រភេទនេះ របាយការណ៍កម្មសិក្សានេះបានប្រមូលពី៖
  - ការពន្យល់ និងបកស្រាយ ពីបុគ្គលក្នុង និងក្រៅស្ថាប័ន ដែលចុះកម្មសិក្សាពីទិន្នន័យដែលទទួលបាន
  - ដកស្រង់ចេញពីច្បាប់ ប្រកាស សេចក្តីណែនាំ សៀវភៅ មេរៀន និងឯកសារនានា
  - ឯកសារពាក់ព័ន្ធដែលបានពីស្ថាប័នចុះកម្មសិក្សា
  - ទិន្នន័យព័ត៌មានពីប្រព័ន្ធអ៊ីនធឺណេត

❖ ការបកស្រាយ ពន្យល់ និងវិភាគទិន្នន័យ

ទិន្នន័យទាំងអស់ដែលទទួលបាន នឹងត្រូវយកមកបង្ហាញ បកស្រាយ ពន្យល់ និងវិភាគតាមវិធីសាស្ត្រពីរប្រភេទដូចជា

- វិធីសាស្ត្របង្ហាញ និងពន្យល់ពីដំណាក់កាល និងដំណើរការនីមួយៗ
- វិធីសាស្ត្រវិភាគ ដោយបង្ហាញពី
  - គណនាតាមកម្មវិធី Microsoft Excel ដែលមានការប្រើប្រាស់រូបមន្ត Sum, Sumif, If, Round...
  - តារាងដ្យាក្រាមដេកវិភាគរបាយការណ៍ដែលទទួលបាន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**សេចក្តីផ្តើម**

**ជំពូកទី ១**

**គោលការណ៍ទូទៅ**

+គោលការណ៍ទូទៅនៃពន្ធដារ

-និយមន័យ

-បុព្វហេតុនៃការប្រកាសពន្ធ

-ប្រព័ន្ធកំណត់ពន្ធដារកម្ពុជា

+នីតិវិធីក្នុងការប្រកាសពន្ធ

-ចុះបញ្ជីសារពើពន្ធ

-ដំណើរការដាក់លិខិតប្រកាស

-ពន្ធបន្ថែម និងទោសទណ្ឌ

+ប្រភេទពន្ធប្រកាសប្រចាំខែ

+ប្រភេទពន្ធប្រកាសប្រចាំឆ្នាំ

**ជំពូកទី ២**

**ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ខេមឌីល គ្លូប៊ល ខូអិល ធីឌី**

-ប្រវត្តិរបស់ក្រុមហ៊ុន

-ទីតាំង ស្លាកសញ្ញា និងការចុះបញ្ជីពាណិជ្ជកម្ម

-ចក្ខុវិស័យ បេសកកម្ម គោលដៅ និងទិសដៅ

-រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន

-សេវាកម្មចំបង និងដៃគូពាណិជ្ជកម្ម

**ជំពូកទី ៣**

**ដំណើរការប្រកាសពន្ធស្វ័យប្រកាសរបស់ក្រុមហ៊ុន**

-ការចុះបញ្ជីពន្ធដាររបស់ក្រុមហ៊ុន

-ដំណើរការប្រកាសពន្ធប្រចាំខែ

-ដំណើរការប្រកាសពន្ធប្រចាំឆ្នាំ

-របាយការណ៍ចំណាយប្រកាសពន្ធសរុប(រយៈពេល ៩ខែដំបូង)

**ជំពូកទី ៤**

**វិភាគSWOT**

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

# ជំពូកទី ១

# គោលការណ៍ទូទៅ និង

# ប្រភេទពន្ធស្វ័យប្រកាស

# ជំពូកទី ១

# គោលការណ៍ទូទៅ និងប្រភេទពន្ធស្វ័យប្រកាស

## ១.១ គោលការណ៍ទូទៅនៃពន្ធដារ

### ១.១.១. និយមន័យ[1]

ពាក្យថាពន្ធដារត្រូវបានកំណត់អត្ថន័យច្រើនយ៉ាងដូចខាងក្រោម៖

- តាមវចនានុក្រមខ្មែរ៖ ពន្ធមានន័យថា អាករដែលប្រជានិករត្រូវបង់តាមការកំណត់។ ពន្ធដារ គឺពន្ធគ្រប់មុខ។
- ពន្ធដារគឺជាកាតព្វកិច្ចរបស់រូបវន្តបុគ្គល និងនីតិបុគ្គលទាំងអស់ដែលមានក្នុងច្បាប់ត្រូវតែចូលរួមបង់នូវវិភាគទានជូនរដ្ឋក្រោមរូបភាពមួយជាប្រភពនៃការប្រមូលចំណូលជាតិ ដើម្បីអោយរដ្ឋាភិបាលធ្វើការបែងចែកចំណូលឡើងវិញសម្រាប់ផលប្រយោជន៍សង្គមជាតិទាំងមូល។
- ពន្ធដារត្រូវកំណត់ដោយលក្ខណៈ ៦យ៉ាងដូចខាងក្រោម៖
  - ពន្ធដារត្រូវបង់ជាប្រាក់
  - ពន្ធដារត្រូវយកពីរូបវន្តបុគ្គល និងនីតិបុគ្គល
  - ពន្ធដារត្រូវរដ្ឋយកដោយប្រើអំណាចបង្ខំ
  - ពន្ធដារត្រូវបង់ជូនរដ្ឋដោយខានមិនបាន
  - ពន្ធដារត្រូវមានលក្ខណៈឯកតោភាគី
  - ពន្ធដារត្រូវតែបង់ហើយមិនសងត្រលប់ដោយផ្ទាល់ទេ។

### ១.១.២. បុព្វហេតុនៃការប្រមូលពន្ធ

ផ្អែកលើប្រព័ន្ធសេដ្ឋកិច្ចជាតិ ចំណូលរបស់រាជរដ្ឋាភិបាលធំជាងគេបង្អស់ គឺការប្រមូលពន្ធ។ យ៉ាងណាមិញ ហេតុផលដែលតម្រូវអោយរាជរដ្ឋាភិបាលនៅទូទាំងពិភពលោកធ្វើការប្រមូលពន្ធពីប្រជាជន អាជីវកម្ម និងសហគ្រាសមានដូចជា៖

- ដើម្បីជាចំណូលជាតិ សម្រាប់ធ្វើការចំណាយរបស់រាជរដ្ឋាភិបាល
- ជាមធ្យោបាយក្នុងការជួយប្រជាពលរដ្ឋក្រីក្រ ឧទាហរណ៍ ការផ្តល់មកវិញនូវសេវាសាធារណៈជាដើម

[1] ស្តើង ដឿន, *ពន្ធដារកម្ពុជាឆ្នាំ ២០១៦*, ទំព័រទី២

- ទិសដៅអភិវឌ្ឍលក្ខខណ្ឌសេដ្ឋកិច្ចជាតិ និងឧស្សាហកម្មក្នុងស្រុក
- ដើម្បីទិសដៅសុខុមាលភាពសង្គម និងសេដ្ឋកិច្ច
- ការការពារសុខភាព និងសុខុមាលភាពរបស់ប្រជាជន ឧទាហរណ៍៖ ការយកពន្ធធ្ងន់ធ្ងរលើ ស្រា បារី...
- សម្របសម្រួលចំណូលរបស់ប្រជាពលរដ្ឋក្នុងសង្គម
- កាត់បន្ថយភាពខ្វះខាតរបស់ប្រជាជន។

### ១.១.៣. ប្រព័ន្ធកំណត់ពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា

❖ របបស្វ័យប្រកាស[2]

របបកំណត់ពន្ធនៃព្រះរាជាណាចក្រកម្ពុជាជារបបស្វ័យប្រកាស ដែលតម្រូវឲ្យអ្នកជាប់ពន្ធធ្វើការគណនាប្រាក់ពន្ធ និងដាក់លិខិតប្រកាសពន្ធដោយខ្លួនឯង។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបែងចែកជា ៣ ប្រភេទគឺ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ។

១. អ្នកជាប់ពន្ធតូចគឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិដែល៖

- មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ៧០០លានរៀល
- មានផលរបរក្នុងរយៈពេល ៣ខែ ជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី៦០ លានរៀលឡើងទៅ
- រំពឹងថាមានផលរបរក្នុងរយៈពេល ៣ខែជាប់គ្នាខាងមុខ ចាប់ពី ៦០លានរៀលឡើងទៅ
- ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្ទង់ថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា រួមទាំងភាស៊ី។

២. អ្នកជាប់ពន្ធមធ្យមគឺជា៖

- សហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៧០០លានរៀល ដល់២០០០លានរៀល
- សហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល
- ស្ថាប័នរដ្ឋថ្នាក់ក្រោមជាតិ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

៣. អ្នកជាប់ពន្ធធំគឺជា៖

- សហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ២០០០លានរៀល

[2] ប្រកាសស្តីពីការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធ, លេខ១៨១៩សហវ.ប្រក, ២៥ ធ្នូ ឆ្នាំ ២០១៦, ប្រការ៤

- សាខាក្រុមហ៊ុនបរទេស
- សហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- ស្ថាប័នរដ្ឋ បេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

## ១.២ នីតិវិធីក្នុងការប្រកាសពន្ធ

តាមរបបស្វ័យប្រកាស អ្នកជាប់ពន្ធទាំងឡាយ ត្រូវអនុវត្តតាមនីតិវិធីមួយចំនួនដើម្បីឈានដល់ការប្រកាសពន្ធបានជោគជ័យ ដូចជា៖

### ១.២.១ ការចុះបញ្ជីពន្ធដារ[3]

មុនពេលដែលក្រុមហ៊ុនអាចចុះបញ្ជីសារពើពន្ធបាន ក្រុមហ៊ុនត្រូវទៅចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ក្នុងកំឡុងពេល ១៥ ថ្ងៃ បន្ទាប់ពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។ បន្ទាប់មកក្រសួងពាណិជ្ជកម្ម នឹងចេញវិញ្ញាបនប័ត្របញ្ជាក់ពីការចុះបញ្ជី (Certificate of Incorporation); លក្ខន្តិកៈក្រុមហ៊ុន (Memorandum Article of Association); និងសម្រង់ព័ត៌មានក្រុមហ៊ុន (Company Extract) ជូនក្រុមហ៊ុន។ បន្ទាប់មកក្រុមហ៊ុនត្រូវបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់ ១០១) ដើម្បីចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារក្នុងកំឡុងពេល ១៥ ថ្ងៃធ្វើការបន្ទាប់ពីចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម។ ដូចនេះដំណើរការនៃការចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារមានដូចតទៅ៖

1. ក្រុមហ៊ុនត្រូវយកពាក្យស្នើសុំចុះបញ្ជីពន្ធដារ[4] (ទម្រង់ ១០១); ឯកសារចេញពីក្រសួងពាណិជ្ជកម្ម; និងឯកសារភ្ជាប់[5]មួយចំនួនទៀតទៅបញ្ចូលព័ត៌មានបឋមនៅ counter 1 នៃការិយាល័យចុះបញ្ជីស្ថិតនៅជាន់ទី ៦ នៃសាលាជាតិពន្ធដារ
2. ក្រុមហ៊ុនត្រូវធ្វើការបង់ប្រាក់នៅ counter 7 និង 8 នៃទីតាំងខាងលើ ដែលការបង់ប្រាក់នេះគឺជាការចំណាយទៅលើ៖ ពន្ធប៉ាតង់; សេវាចុះបញ្ជី និងពន្ធប្រថាប់ត្រា
3. នាយកក្រុមហ៊ុន (Chairman) តំរូវឲ្យធ្វើការថតរូប និងស្កេនស្រាមដៃនៅ counter 5 និង 6 នៃទីតាំងខាងលើដោយភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។

[3] សូមមើលឧបសម្ព័ន្ធទី ១៖ ប្រកាសស្តីពីការចុះបញ្ជីពន្ធដារ

[4] សូមមើលឧបសម្ព័ន្ធទី ១៖ ពាក្យស្នើសុំចុះបញ្ជីពន្ធដារ

[5] សូមមើលឧបសម្ព័ន្ធទី ១៖ ទំព័រទី ៥នៃពាក្យស្នើសុំចុះបញ្ជីពន្ធដារ

4. ក្រុមហ៊ុនត្រូវយកពាក្យស្នើសុំចុះបញ្ជីពន្ធដារតាមទម្រង់ ១០១ ដែលបានបំពេញចប់រួចរាល់ (ក្នុងករណីដែលក្រុមហ៊ុនខ្វះខាតព័ត៌មាននៅដំណាក់កាលបញ្ចូលព័ត៌មានបឋម) ទៅដាក់នៅ counter 2 និង 4 នៃទីតាំងខាងលើ
5. ក្នុងរយៈពេល ពី ៧ ទៅ ១០ថ្ងៃ ពន្ធដារនឹងចេញឯកសារជាផ្លូវការ[6]បញ្ជាក់ពីការចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសជូនក្រុមហ៊ុន។

**១.២.១.១ ការស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់ក្រុមហ៊ុនដែលបានចុះបញ្ជី**[7]

- អនុលោមតាមមាត្រា១០១ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដាររួចហើយត្រូវតំរូវអោយធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាស ក្នុងករណីដែលព័ត៌មានណាមួយក្នុងបណ្តាព័ត៌មានទាំងនេះត្រូវបានផ្លាស់ប្តូរៈ នាមករណ៍សហគ្រាស, អាស័យដ្ឋានទីចាត់ការ, កន្លែងប្រកបអាជីវកម្មជាគោលដើម, អាស័យដ្ឋានម្ចាស់សហគ្រាស, ទ្រង់ទ្រាយគតិយុត្តិរបស់សហគ្រាស, កម្មវត្ថុអាជីវកម្ម, ការផ្ទេរ ឬបញ្ឈប់អាជីវកម្ម, សមាសភាពអ្នកគ្រប់គ្រង, អ្នកទទួលបន្ទុកកិច្ចការពន្ធ, លេខគណនីធនាគារសហគ្រាស និងលេខទំនាក់ទំនង។

- អ្នកជាប់ពន្ធត្រូវស្នើសុំមករដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃនៃថ្ងៃធ្វើការ បើសិនជាមានការផ្លាស់ប្តូរព័ត៌មានណាមួយកើតឡើង ដើម្បីធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ

- ចំពោះសហគ្រាសណាដែលបានធ្វើការផ្លាស់ប្តូរអាស័យដ្ឋានទីចាត់ការសហគ្រាសត្រូវធ្វើការស្នើសុំផ្លាស់ប្តូរអង្គភាពទៅតាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ។

- ចំពោះអ្នកជាប់ពន្ធដែលបានធ្វើការចុះបញ្ជីមុនថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ត្រូវមកធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ។

**១.២.១.២ តំណាងអ្នកជាប់ពន្ធ**[8]

បុគ្គលដែលជាតំណាងអ្នកជាប់ពន្ធត្រូវមានសិទ្ធជំនួសមុខឲ្យអ្នកជាប់ពន្ធដើម្បីៈ

- ដាក់លិខិតប្រកាសសារពើពន្ធ
- បង្ហាញរបាយការណ៍ ឬលិខិតស្នាមផ្សេងៗ
- បង់ពន្ធអាករទាំងឡាយដែលកំណត់ដោយបទបញ្ញត្តិស្តីពីពន្ធដារ
- ធ្វើបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍

[6] សូមមើលឧបសម្ព័ន្ធទី ១ៈ ទំព័រទី ៨នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ

[7] ប្រកាសស្តីពីការចុះបញ្ជីពន្ធដារ, លេខ៥៥៦សហវ, ០៦ មេសា ឆ្នាំ ២០១៦, ប្រការ៨

[8] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ១០៦

- បំពេញកាតព្វកិច្ចដែលអ្នកជាប់ពន្ធត្រូវទទួលខុសត្រូវចំពោះមុខបទបញ្ញត្តិស្តីពីពន្ធដារ។

អ្នកជាប់ពន្ធអាចធ្វើការផ្ទេរសិទ្ធិ និងកំណត់ព្រំដែនសិទ្ធិអំណាចនៃការផ្ទេរសិទ្ធិនេះ ជាលាយលក្ខណ៍អក្សរទៅឲ្យបុគ្គលម្នាក់ទៀត ឲ្យធ្វើសកម្មភាពជំនួសមុខខ្លួនក្នុងបញ្ហាពន្ធដារ។ លើសពីនេះទៀត អ្នកជាប់ពន្ធត្រូវទទួលខុសត្រូវរាល់សកម្មភាពរបស់បុគ្គលដែលជាតំណាងរបស់ខ្លួន រហូតទាល់តែអ្នកជាប់ពន្ធធ្វើសេចក្តីជាលាយលក្ខណ៍អក្សរបញ្ជាក់ពីការលុបចោលនូវការផ្ទេរសិទ្ធិនេះ។ បុគ្គលដែលជាតំណាងអ្នកជាប់ពន្ធ ត្រូវចុះបញ្ជីនូវទំនាក់ទំនងរបស់ខ្លួននៅរដ្ឋបាលសារពើពន្ធក្នុងកំឡុងពេល ១៥ថ្ងៃក្រោយពេលទំនាក់ទំនងនោះបានកើតឡើង ដោយភ្ជាប់មកជាមួយនូវៈ តារាងបៀវត្សដែលទទួលស្គាល់ពីប្រធានក្រុមហ៊ុន (បោះត្រាក្រុមហ៊ុន), ថតចំលងអត្តសញ្ញាណបណ្ណ, ថតចំលងប័ណ្ណប៉ាតង់, និងវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម។

### ១.២.២ ដំណើរការដាក់លិខិតប្រកាសពន្ធ

- ជំហានទី ១៖ អ្នកជាប់ពន្ធ មានកាតព្វកិច្ចរៀបចំបញ្ជីការគណនេយ្យរបស់ខ្លួន ហើយបំពេញចូលលិខិតប្រកាសពន្ធ ដែលលិខិតប្រកាសនោះ អ្នកអាចទាញយកបានពី អ៊ីនធើណេត (www.tax.gov.kh) ឬពីការិយាល័យបំណុល។
- ជំហានទី ២៖ បន្ទាប់ពីរៀបចំលិខិតប្រកាសពន្ធហើយ អ្នកជាប់ពន្ធត្រូវគណនាសរុបទឹកប្រាក់ពន្ធ ហើយបំពេញក្នុងទម្រង់បង់ប្រាក់ពន្ធ[9] (Form P101) រួចបង់នៅបណ្តាធនាគារតាមលេខគណនីសាខាពន្ធដារខេត្ត/ខណ្ឌ ដែលសហគ្រាសតាំងនៅ ដើម្បីទទួលបានបង្កាន់ដៃធនាគារ។
- ជំហានទី ៣៖ បន្ទាប់ពីបង់ប្រាក់ហើយ អ្នកជាប់ពន្ធត្រូវយកលិខិតនោះដោយភ្ជាប់ជាមួយនឹងបង្កាន់ដៃធនាគារទៅជូនមន្ត្រីទទួល ឲ្យគាត់ត្រួតពិនិត្យ។
- ជំហានទី ៤៖ បន្ទាប់ពីមន្ត្រីពិនិត្យមើលត្រឹមត្រូវហើយ ក៏បញ្ជូនទៅឲ្យបេឡា រួចបេឡានឹងចេញលិខិតបញ្ជាក់ការបង់ប្រាក់ជូនអ្នកជាប់ពន្ធវិញ។

### ១.២.៣ កាលបរិច្ឆេទនៃការបង់ពន្ធ

ប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់នៅក្នុងរយៈពេលដែលបទបញ្ញត្តិស្តីពីពន្ធដារបានតម្រូវឲ្យធ្វើការដាក់លិខិតប្រកាសសារពើពន្ធ៖

- ពន្ធលើប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែម

[9] សូមមើលឧបសម្ព័ន្ធទី១៖ ទម្រង់បង់ប្រាក់ពន្ធ

- ពន្ធកាត់ទុក
- ពន្ធប្រាក់រំដោះ
- អាករលើតម្លៃបន្ថែម
- អាករបំភ្លឺសាធារណៈ
- អាករពិសេស
- អាករស្នាក់នៅ

⇨ ប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់យ៉ាងយឺតបំផុតថ្ងៃទី ២០នៃខែបន្ទាប់ពីខែដែលមានប្រតិបត្តិការទូទាត់កើតឡើង។

❖ ពន្ធប៉ាតង់៖

▪ សហគ្រាសចាស់៖ ពន្ធប៉ាតង់ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី ៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

▪ សហគ្រាសថ្មី៖ ពន្ធប៉ាតង់ត្រូវបង់លើកដំបូងមានរយៈពេល ១៥ថ្ងៃ បន្ទាប់ពីមានសកម្មភាពសេដ្ឋកិច្ចបឋម ឬកាលបរិច្ឆេទនៃការចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម។

❖ ពន្ធលើប្រាក់ចំណេញ៖

▪ ចំពោះសហគ្រាសអនុវត្តឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិន៖ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែមីនា នៃឆ្នាំបន្ទាប់។

▪ ចំពោះសហគ្រាសដែលស្នើសុំប្តូរឆ្នាំជាប់ពន្ធថ្មី៖ ក្នុងរយៈពេលបីខែក្រោយដំណាច់ឆ្នាំជាប់ពន្ធថ្មី។

### **១.២.៤ ពន្ធបន្ថែម និងទោសទណ្ឌ**[10]

#### **១.២.៤.១ ពន្ធបន្ថែមចំពោះការបង់ពន្ធខ្វះ**

- ករណីធ្វេសប្រហែស៖
  - ប្រាក់ពន្ធបន្ថែម ១០% បូកនឹងការប្រាក់យឺតយ៉ាវ ២% ចាប់គិតពីថ្ងៃទី ១ នៃខែបន្ទាប់ដែលបង់ពន្ធខ្វះ
- ករណីធ្វេសប្រហែសធ្ងន់ធ្ងរ៖

[10] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ១៣០; ១៣១; ១៣២; ១៣៣; ១៣៥ និង១៣៦

- ប្រាក់ពន្ធបន្ថែម ២៥% បូកនឹងការប្រាក់យឺតយ៉ាវ ២% ចាប់គិតពីថ្ងៃទី ១ នៃខែបន្ទាប់ដែលបង់ពន្ធខ្វះ

• ករណីកំណត់ពន្ធជាឯកតោភាគី៖

- ប្រាក់ពន្ធបន្ថែម ៤០% បូកនឹងការប្រាក់យឺតយ៉ាវ ២% ចាប់គិតពីថ្ងៃទី ១ នៃខែបន្ទាប់ដែលបង់ពន្ធខ្វះ

**១.២.៤.២ ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធ**

• ករណីមិនបានបង់ពន្ធតាមកាលកំណត់៖

- ប្រាក់ពន្ធបន្ថែម ១០% បូកនឹងការប្រាក់យឺតយ៉ាវ ២% ចាប់គិតពីថ្ងៃទី ១ នៃខែបន្ទាប់ដែលបង់ពន្ធខ្វះ

• ករណីមិនបានបង់ពន្ធក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីបានទទួលលិខិតរំលឹកទារបំណុលពន្ធ៖

- ប្រាក់ពន្ធបន្ថែម ៤០% បូកនឹងការប្រាក់យឺតយ៉ាវ ២% ចាប់គិតពីថ្ងៃបន្ទាប់ពីថ្ងៃដែលផុតរយៈពេល ១៥ ថ្ងៃនៃលិខិតរំលឹកទារបំណុលពន្ធ

• ករណីកំណត់ពន្ធជាឯកតោភាគីសម្រាប់ការមិនដាក់លិខិតប្រកាស៖

- ប្រាក់ពន្ធបន្ថែម ៤០%បូកនឹងការប្រាក់យឺតយ៉ាវ ២% ចាប់គិតពីថ្ងៃទី ១ នៃខែបន្ទាប់ដែលបង់ពន្ធខ្វះ

• ចំពោះពន្ធលើប្រាក់ចំនូល ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ១នៃខែបន្ទាប់ ដែលជាខែផុតរយៈពេលកំណត់សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ។

**១.២.៤.៣ ពន្ធបន្ថែមចំពោះអំពើរាំងស្ទះការអនុវត្តបទបញ្ញត្តិស្ដីពីពន្ធដារ**

- ២,០០០,០០០៛ (២លានរៀល) ចំពោះបុគ្គលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកក្រោមរបបស្វ័យប្រកាស ឬមន្ត្រីរាជការ។

**១.២.៤.៤ ទោសទណ្ឌ**

បទល្មើសព្រហ្មទណ្ឌចំពោះ៖

- ការគេចវេសពន្ធ៖ ពិន័យជាប្រាក់ពី ១០,០០០,០០០៛ (ដប់លានរៀល) ដល់ ២០,០០០,០០០៛ (ម្ភៃលានរៀល) ឬជាប់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ឬទោសទាំង ២ នេះ។

- ការរាំងស្ទះការអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ៖ ពិន័យជាប្រាក់ពី ៥,០០០,០០០៛ (ប្រាំលានរៀល) ដល់ ១០,០០០,០០០៛ (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ។

## ១.៣ ប្រភេទពន្ធប្រកាសប្រចាំខែ

### ១.៣.១ ពន្ធលើប្រាក់បៀវត្ស ( Tax on Salary )

#### ១.៣.១.១ និយមន័យ[11]

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែដែលត្រូវកាត់ទុកដោយនិយោជក ពីប្រាក់បៀវត្សរបស់និយោជិកដែលបំពេញការងារ។

- អ្នកជាប់ពន្ធនិវាសនជន៖ ពន្ធត្រូវកាត់ទុកពីប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស។
- អ្នកជាប់ពន្ធអនិវាសនជន៖ ពន្ធត្រូវកាត់ទុកពីប្រាក់បៀវត្សប្រភពកម្ពុជា។

* អ្នកជាប់ពន្ធនិវាសនជន៖ គឺជាបុគ្គលដែលមានលំនៅដ្ឋាន កន្លែងស្នាក់នៅជាគោលដើម ឬមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃ ក្នុងរយៈពេល ១២ខែ នៃការបញ្ចប់ឆ្នាំជាប់ពន្ធចរន្ត។

* អ្នកជាប់ពន្ធអនិវាសនជន៖ គឺជាបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន និងទទួលបានប្រាក់បៀវត្សប្រភពកម្ពុជា។

#### ១.៣.១.២ មូលដ្ឋានគិតពន្ធប្រាក់បៀវត្ស[12]

- **ប្រាក់បៀវត្សជាប់ពន្ធ៖** សំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ដល់និយោជិត ឬដែលបានទូទាត់ជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិតចំពោះការបំពេញសកម្មភាពបម្រើការងារ។

*តារាងទី១៖ ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ*

| | ប្រាក់បៀវត្ស (salary) |
|---|---|
| + | ប្រាក់បៀវត្ស (salary) |
| + | បុព្វលាភ (bonus) |
| + | ប្រាក់ម៉ោងបន្ថែម (overtime) |

[11] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ៤១ និង៤២ថ្មី

[12] ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស, លេខ១១៧៣សហវ.ពដ.ប្រក, ៣១ ធ្នូ ឆ្នាំ២០០៣, ផ្នែកទី ២.១

| | |
|---|---|
| + | ប្រាក់ប៉ះប៉ូវនានា (compensation) |
| + | ប្រាក់ខែបើកមុន (advanced salary) |
| - | ប្រាក់កម្ចីពីនិយោជក (loan obtained from employee) |
| = | ប្រាក់បៀវត្សប្រចាំខែ (monthly salary) |
| - | ការអនុគ្រោះពន្ធសម្រាប់កូន/សហព័ទ្ធ (tax rebate for children and wife) |
| = | ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ (monthly taxable salary) |

(ប្រកាសស្តីពីពបវ, លេខ១១៧៣,ថ្ងៃទី ៣១ ធ្នូ ២០០៣, ផ្នែកទី ២.១)

- **ប្រាក់បៀវត្សមិនជាប់ពន្ធ៖**
  - ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់ និងសម្រាប់ជាផលប្រយោជន៍នៃនិយោជក។
  - ប្រាក់សំណងសម្រាប់ការបញ្ឈប់ការងារ ស្របតាមក្របខណ្ឌនៃច្បាប់ស្តីពីការងារ។
  - ចំណាយបន្ថែមស្របតាមលក្ខណៈសង្គម ដែលមានចែងក្នុងច្បាប់ការងារ។
  - ឯកសណ្ឋានពិសេស ឬសម្ភារៈវិជ្ជាជីវៈដែលមិនគិតថ្លៃ ឬមានតម្លៃទាប។
  - ប្រាក់ឧបត្ថម្ភថេរសម្រាប់បេសកកម្ម និងចំណាយលើការធ្វើដំណើរជំនួសការទូទាត់ជាក់ស្តែង។
  - ប្រាក់បៀវត្សរបស់មន្ត្រី និងបុគ្គលិក នៃបេសកកម្មកុងស៊ុល និងការទូតរបស់រដ្ឋាភិបាលក្រៅប្រទេសដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់រដ្ឋាភិបាលក្រៅប្រទេសដែលបានទទួលសិទ្ធបំពេញមុខងារជាផ្លូវការរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។
  - ប្រាក់បៀវត្សរបស់តំណាងមន្ត្រី និងបុគ្គលិករបស់អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀតដែលបានទទួលសិទ្ធិបំពេញមុខងារជាផ្លូវការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។
  - ប្រាក់បៀវត្សរបស់សមាជិកព្រឹទ្ធសភា និងរដ្ឋសភាជាតិ។
- **ការអនុគ្រោះពន្ធ៖**
  - ការកាត់កងទឹកប្រាក់ចំនួន ១៥០,០០០ រៀល សម្រាប់កូននៅក្នុងបន្ទុករបស់និយោជិតជានិវាសនជន។ កូននៅក្នុងបន្ទុកត្រូវមានអាយុមិនលើសពី ១៤ ឆ្នាំ លើកលែងតែសិស្ស ឬនិស្សិតដែលរៀនពេញម៉ោង និងមានអាយុមិនលើសពី២៥ឆ្នាំ។ មានតែឪពុក ឬម្តាយម្នាក់គត់ដែលមានសិទ្ធទទួលបានការកាត់កងទាំងនោះ។

- ការកាត់កងចេញនូវចំនួនទឹកប្រាក់ ១៥០,០០០ រៀល សម្រាប់តែសហព័ទ្ធ (ស្ត្រី) ដែលធ្វើតែជាមេផ្ទះប៉ុណ្ណោះ ក្នុងករណីដែលប្តីជានិយោជិតនិវាសជន។

**១.៣.១.៣ របៀបគណនាពន្ធលើប្រាក់បៀវត្ស**

*** និវាសនជនកម្ពុជា**

*តារាងទី២៖ ការគណនាពន្ធលើប្រាក់បៀវត្សរបស់និវាសនជនកម្ពុជា*

| ប្រាក់បៀវត្សប្រចាំខែ (៛) | អត្រាពន្ធ | វិធីគណនាប្រាក់ពន្ធ |
|---|---|---|
| 0-១,000,000 | 0% | 0 |
| ១,000,00១-១,៥00,000 | ៥% | (មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស X ៥%) - ៥0,000 |
| ១,៥00,00១-៨,៥00,000 | ១0% | (មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស X ១0%) - ១២៥,000 |
| ៨,៥00,00១-១២១២,៥00,000 | ១៥% | (មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស X ១៥%) - ៥៥0,000 |
| លើសពី ១២,៥00,000 | ២0% | (មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស X ២0%) - ១,១៧៥,000 |

(សេចក្តីណែនាំស្តីពីការអនុវត្តអត្រាពបថ្មី, លេខ០១៧, ២៧ ធ្នូ ឆ្នាំ ២០១៦)

***អនិវាសជនកម្ពុជា**

*តារាង៣៖ ការគណនាពន្ធលើប្រាក់បៀវត្សរបស់អនិវាសនជនកម្ពុជា*

| ប្រាក់បៀវត្សប្រចាំខែ (៛) | អត្រាពន្ធ | វិធីគណនាប្រាក់ពន្ធ |
|---|---|---|
| 0 ឡើងទៅ | ២0% | ២0% X ប្រាក់បៀវត្ស |

(ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/0៣0៣/0១0, ៣១ មីនា ២00៣, មាត្រា៩៩ថ្មី)

**១.៣.១.៤ ពន្ធលើអត្ថប្រយោជន៍បន្ថែម**[13] ( Fringe Benefit Tax )

តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់នៃអត្ថប្រយោជន៍បន្ថែមដែលបានផ្តល់អោយ។

[13] ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស, លេខ១១៧៣សហវ.ពដ.ប្រក, ៣១ ធ្នូ ឆ្នាំ២០០៣, ផ្នែកទី ៣.១, ៣.២, ៣.៣។

*តារាង៤៖ ការគណនាពន្ធអត្ថប្រយោជន៍បន្ថែមនៃនិវាសនជន និងអនិវាសជនកម្ពុជា*

| ប្រាក់បៀវត្សប្រចាំខែ(រ) | អត្រាពន្ធ | វិធីគណនាពន្ធ |
|---|---|---|
| ០ ឡើងទៅ | ២០% | ២០% X ប្រាក់បៀវត្ស |

(ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣, មាត្រា៥៥ថ្មី)

❖ អត្ថប្រយោជន៍បន្ថែមរួមមាន៖

- ការប្រើប្រាស់យានយន្ត បើនិយោជិតអាចយកយានយន្តនោះមកផ្ទះនៅពេលយប់ និងប្រើប្រាស់សម្រាប់គោលបំណងផ្ទាល់ខ្លួន។
- ចំណីអាហារដែលផ្តល់អោយនិយោជិតទទួលទាន។
- ផ្ទះសម្បែងដែលផ្តល់អោយនិយោជិតស្នាក់នៅ (រាប់បញ្ចូលទាំងការចំនាយលើសេវាសាធារណៈ និងអ្នកបម្រើតាមផ្ទះ)។
- ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបជាងអត្រាលើទីផ្សារ។
- អប្បហាលើការលក់ទំនិញ និងសេវា។
- ជំនួយផ្នែកអប់រំសម្រាប់និយោជិតដែលមិនមែនជាចំណែកណាមួយនៃកម្មវិធីបណ្តុះបណ្តាលទាក់ទិនផ្ទាល់ទៅនឹងការបំពេញការងាររបស់និយោជិតនោះ។
- ជំនួយផ្នែកអប់រំសម្រាប់កូននិយោជិត។
- ការបង់បុព្វលាភធានារ៉ាប់រងលើសុខភាព ឬធានារ៉ាប់រងលើអាយុជីវិត លើកលែងតែនិយោជិតទាំងអស់ទទួលបាននូវអត្ថប្រយោជន៍ដូចៗគ្នា ដោយគ្មានបែងចែកតាមតួនាទីឬមុខងារ។
- ការឧបត្ថម្ភលើចំណាយដែលមិនសមហេតុផល និងមិនចាំបាច់សម្រាប់អាជីវកម្មរបស់និយោជក។
- ការរួមវិភាគទានមូលនិធិសុខុមាលភាពសង្គមដែលលើសពីចំនួនដែលតម្រូវដោយច្បាប់
- ការរួមវិភាគទានប្រាក់សោធននិវត្តន៍ដែលលើសពី ១០% នៃប្រាក់បៀវត្ស (ដោយមិនរួមបញ្ចូលទាំងអត្ថប្រយោជន៍បន្ថែម)។
- ការចំណាយលើវិស្សមកាល ឬការកំសាន្តដែលមិនពាក់ពន្ធនឹងសកម្មភាពការងារ។

### ១.៣.២ ពន្ធកាត់ទុក ( Witholding Tax )

ពន្ធកាត់ទុក គឺជាពន្ធដែលត្រូវបានកាត់ទុកដោយអ្នកជាប់ពន្ធនិវាសជនលើការទូទាត់មួយចំនួនដែលធ្វើឡើងជាសាច់ប្រាក់ ឬជាវត្ថុឲ្យទៅអ្នកជាប់ពន្ធនិវាសជន និងអនិវាសនជន។

### ១.៣.២.១ ពន្ធកាត់ទុកលើការទូទាត់ឲ្យនិវាសនជន[14]

*តារាង៥៖ អត្រាពន្ធកាត់ទុកលើការទូទាត់ឲ្យនិវាសនជន*

| ការទូទាត់ | អត្រាពន្ធ |
|---|---|
| - សេវាកម្ម៖ ប្រាក់ចំណូលដែលរូបវន្តបុគ្គលទទួលបានពីការបំពេញសេវានានា។ | ១៥% |
| - សួយសារពីទ្រព្យសកម្មរូបី និងពីភាគកម្មក្នុងធនធានរ៉ែ | ១៥% |
| - ការប្រាក់៖ ដែលអ្នកជាប់ពន្ធនិវាសជនទូទាត់ឲ្យរូបវន្តបុគ្គល ឬសហគ្រាស | ១៥% |
| - ថ្លៃឈ្នួល៖ ប្រាក់ចំណូលដែលបានទទួលពីការជួលចលនទ្រព្យ និងអចលនទ្រព្យ | ១០% |
| - ការប្រាក់៖ ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ទៅឲ្យអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់។ | ៦% |
| - ការប្រាក់៖ ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឲ្យរូបវន្តបុគ្គលនិវាសជនដែលមានប្រាក់បញ្ញើក្នុងគណនីសន្សំគ្មានកាលកំណត់។ | ៤% |

(ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣, មាត្រា២៥ថ្មី)

### ១.៣.២.២ ការទូទាត់ដែលទទួលបានការលើកលែងពន្ធកាត់ទុក

- ការប្រាក់ដែលបង់ទៅឲ្យធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក។
- ការទូទាត់នូវប្រាក់ចំណូលពីការបំពេញសេវានានារួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែលរបស់សហគ្រាសនីតិបុគ្គលដែលបានចុះបញ្ជីជាសហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស។
- ការទូទាត់ទៅឲ្យរដ្ឋាភិបាល ឬស្ថាប័ននៃរាជរដ្ឋាភិបាលនូវសួយសារ ឬប្រាក់ថ្លៃឈ្នួលលើចលនទ្រព្យ ឬអចលនទ្រព្យ (ក្នុងនោះមានរួមបញ្ចូលផងដែរនូវប្រាក់ទូទាត់លើការធ្វើអាជីវកម្មកំពង់ផែ ដីសម្បទានសេដ្ឋកិច្ច និងទីផ្សារ)។
- ការទូទាត់នូវប្រាក់ចំណូលដែលពន្ធលើប្រាក់បៀវត្ស ឬពន្ធលើអត្ថប្រយោជន៍បន្ថែមបានកាត់ទុករួចរាល់។
- ការទូទាត់នូវការប្រាក់ដោយរាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាលទៅឲ្យបុគ្គលអនិវាសនជនចំពោះប្រាក់កម្ចីដែលរាជរដ្ឋាភិបាលកម្ពុជា ឬរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទទួលស្គាល់ និងយល់ព្រម។

[14] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣, មាត្រា២៥ថ្មី

**១.៣.២.៣ ពន្ធកាត់ទុកលើការទូទាត់ឲ្យអនិវាសជន**[15]

អ្នកជាប់ពន្ធនិវាសជនដែលប្រកបអាជីវកម្ម រួមទាំងគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជន ដែលធ្វើការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាឲ្យទៅអ្នកជាប់ពន្ធអនិវាសនជនត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធតាម**អត្រា ១៤%** នៃទឹកប្រាក់ត្រូវបើក។ ពន្ធកាត់ទុកនេះមិនត្រូវបានអនុវត្តចំពោះបុព្វលាភធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅក្នុងប្រទេសកម្ពុជាទេ។

**១.៣.៣ អាករលើតម្លៃបន្ថែម** ( Value Added Tax )[16]

អាករលើតម្លៃបន្ថែម គឺជាអាករលើការប្រើប្រាស់ទំនិញ និងសេវាកម្មក្នុងស្រុក និងការនាំចូលទំនិញ។ ទំនិញ សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លីនិងប្រាក់កាស រីឯសេវា សំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃ ក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។

**១.៣.៣.១ ការផ្គត់ផ្គង់ជាប់អាករ**

- ការផ្គត់ផ្គង់ទំនិញឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ។
- ការផ្តល់ជាអំណោយឬការផ្គត់ផ្គង់ក្រោមតម្លៃពិត នូវទំនិញឬសេវាដោយបុគ្គលជាប់អាករ។
- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា។

**១.៣.៣.២ ការផ្គត់ផ្គង់មិនជាប់អាករ**

ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅៈ

- សេវាប្រៃសណីយ៍សាធារណៈ
- សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រដែលទាក់ទិននិងការបំពេញសេវាទាំងនេះ។
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ។
- សេវាធានារ៉ាប់រង។

---

[15] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា២៦ថ្មី

[16] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ៥៦; ៦០; ៥៧; ៦៤; ៦៥; និង ៦៩

- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- សេវាសិក្សាអប់រំ
- ថាមពលអគ្គិសនី និងទឹកស្អាត
- ផលិតផលកសិកម្មមិនទាន់កែច្នៃ
- សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ។

**១.៣.៣.៣ អត្រាអាករលើតម្លៃបន្ថែម**

- ១០% សម្រាប់ការនាំចូល ឬការផ្គត់ផ្គង់ទំនិញ ឬសេវាក្នុងប្រទេសកម្ពុជា
- 0% សម្រាប់ការនាំចេញ។

**១.៣.៣.៤ ការគណនាប្រាក់អាករត្រូវបង់**

- ប្រាក់អាករដែលបានបង់នៅពេលនាំចូលទំនិញ ឬប្រាក់អាករដែលបានបង់លើការទិញទំនិញ ឬសេវា សម្រាប់ ប្រកបអាជីវកម្ម ហៅថា "**អាករលើធាតុចូល**"។
- ប្រាក់អាករដែលបានគិតយកពីអតិថិជនពីការផ្គត់ផ្គង់ទំនិញ ឬសេវាហៅថា "**អាករលើធាតុចេញ**"

☞ **ប្រាក់អាករត្រូវបង់ = អាករលើធាតុចេញ - អាករលើធាតុចូល**

**១.៣.៣.៥ អាករលើធាតុចូលដែលមិនអាចកាត់កងបាន**

អាករលើធាតុចូលដែលមិនអាចកាត់កងបានរួមមានប្រាក់អាករដែលបានបង់លើ៖

- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ។
- ការទិញឬការនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត។
- ការទិញឬការនាំចូលផលិតផលតេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ ផលិតផលតេលសិលាទាំងនោះ។

**១.៣.៣.៦ សំណើសុំឥណទានអាករលើធាតុចូល**

រាល់ការស្នើសុំឥណទានអាករលើធាតុចូល អ្នកទិញត្រូវភ្ជាប់មកជាមួយនូវៈ

- វិក័យប័ត្រ[17]ដែលចេញដោយអ្នកលក់ (អ្នកផ្គត់ផ្គង់) តាមទម្រង់ និងសេចក្តីណែនាំ ពីអគ្គនាយកដ្ឋានពន្ធដារ។
- ប្រតិវេទន៍គយសម្រាប់ការនាំចូលដែលអាជ្ញាធរគយបានបញ្ជាក់ត្រឹមត្រូវ។ ប្រតិវេទន៍នោះត្រូវមានជាប់ឈ្មោះបុគ្គលជាប់អាករ ដែលជាអ្នកទទួលទំនិញ ឬជាអ្នកនាំចូល និងចំនួនប្រាក់ពន្ធអាករដែលបានបង់នៅពេលនាំចូល។

❖ សម្គាល់៖ ចំពោះសហគ្រាសទាំងឡាយណាដែលមិនទាន់បានធ្វើបច្ចុប្បន្នភាពព័ត៌មាន អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើការផ្អាកជាបណ្តោះអាសន្ន មិនអនុញ្ញាតចំពោះការស្នើសុំឥណទានអាករលើធាតុចូល មិនអនុញ្ញាតឲ្យបង្វិលសងអតប រហូតទាល់តែសហគ្រាសទាំងនោះបានធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់ខ្លួនតាមប្រព័ន្ធចុះបញ្ជីថ្មីបានរួចរាល់ ទើបផ្តល់ឥណទានអាករលើធាតុចូល និងបង្វិលសងអតបជូនសាជាថ្មី។

**១.៣.៤ អាករពិសេស**[18] ( Specific Tax )

អាករពិសេសលើទំនិញ និងសេវាមួយចំនួន គឺជាប្រភេទពន្ធប្រយោលត្រូវបានយកទៅលើទំនិញ និងសេវាមួយចំនួន ដូចជាបារី សុរាមេរ៉ៃ ប្រេងសាំង ប្រេងរំអិល ស្រាបៀ រថយន្តភេសជ្ជៈ ។ល។ ពន្ធនេះត្រូវបានបូកបញ្ចូលក្នុងថ្លៃលក់ ហើយអ្នកប្រើប្រាស់ជាអ្នករងពន្ធនៅពេលទិញទំនិញ ប៉ុន្តែត្រូវបានប្រមូលតាមរយៈអង្គភាពអាជីវកម្ម ឬបុគ្គលដែលផលិត ឬនាំចូលប្រភេទទំនិញ និងសេវាកម្ម។

❖ **មូលដ្ឋានគិតអាករពិសេស**

- អាករពិសេសលើទំនិញ និងសេវាមួយចំនួន ត្រូវបានអនុវត្តលើមុខទំនិញទាំងឡាយដែលផលិតក្នុងស្រុកនិងនាំចូល។
- អ្នកជាប់ពន្ធគឺជាស្ថាប័ន ឬបុគ្គលដែលចំណុះគ្រប់សមាសភាពសេដ្ឋកិច្ច។
- រាល់ប្រភេទទំនិញដែលជាប់អាករពិសេស គឺត្រូវបង់ពន្ធតែមួយលើក នៅអង្គភាពផលិតកម្ម។ នៅពេលធ្វើចរាចរ មិនត្រូវជាប់អាករពិសេសជាលើកទី ២ទេ។

[17] សេចក្តីណែនាំស្តីពីការប្រើប្រាស់វិក័យប័ត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស, លេខ១១២៧អពដ, ២៦ មករា ឆ្នាំ ២០១៦

[18] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា៨៥

- អង្គភាពផលិតផ្ទាល់ ដែលផលិតទំនិញជាប់អាករពិសេសត្រូវបង់អាករពិសេសនៅពេលលក់ផលិតផលព្រមជាមួយផលរបរ។
- មូលដ្ឋានបង់អាករពិសេសត្រូវបានដកចេញនូវប្រាក់អាករពិសេស ដែលចំណុះនៅក្នុងវត្ថុធាតុដើម ហើយបានបង់នៅផ្នែកមុខដោយមានឯកសារគ្រប់គ្រាន់បញ្ជាក់ថា៖
  - ក-វត្ថុធាតុដើមនោះបានបង់អាករពិសេសរួចហើយ
  - ខ-វត្ថុធាតុដើមនោះត្រូវបានប្រើប្រាស់ដើម្បីផលិត ឬកែច្នៃប្រភេទផលិតផលថ្មីដែលស្ថិតនៅក្នុងប្រភេទទំនិញជាប់អាករពិសេស។

❖ **អត្រាអាករពិសេស**

- ស្រាបៀ ៣០%
- ស្រា ៣៥%
- បារី ២០%
- សេវាលំហែកំសាន្ត និងការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ១០%
- សេវាទូរស័ព្ទ ៣%។

❖ **ការលើកលែងពន្ធ**

- ទំនិញដែលផលិតសម្រាប់នាំចេញមិនត្រូវបង់អាករពិសេស
- បុគ្គលដែលគ្មានកាតព្វកិច្ចចុះបញ្ជីជាបុគ្គលជាប់អាករពិសេសអាចនាំចូលដោយរួចអាករពិសេសនូវមុខទំនិញមួយចំនួន។
- អាករពិសេសមិនត្រូវបានអនុវត្តចំពោះករណីដែលអង្គភាពផលិតកម្មផលិតទំនិញដែលជាប់អាករពិសេសជួបការលំបាកដោយសារគ្រោះថ្នាក់ធម្មជាតិ គ្រោះអាសន្ន គ្រោះមហន្តរាយ ដោយចៃដន្យដែលជះឥទ្ធិពលដល់សកម្មភាពផលិតកម្ម អាជីវកម្ម។
- ការលើកលែងអាករពិសេសត្រូវបានគិតតាមអត្រានៃគ្រោះមហន្តរាយ ដោយធ្វើការប្រៀបធៀបទៅនឹងផលរបរដែលជាប់ពន្ធ។
- ប្រេងសាំងធម្មតា សាំងស៊ុបពែ និងប្រេងរំអិលដែលមានក្នុងរថយន្តនាំចូល ឬនាំចេញត្រូវកំណត់៖
  - ក. ប្រេងសាំងស៊ុបពែ ឬប្រេងសាំងធម្មតាចំនួន ៣០លីត្រនៅក្នុងរថយន្ត។
  - ខ. ប្រេងរំអិលដែលមាននៅក្នុងរថយន្តនាំចូល ឬនាំចេញចំនួន ៥លីត្រ។
- ថ្លៃទូរស័ព្ទឆ្លងកាត់ប្រព័ន្ធនៅក្នុងប្រទេសរបស់ក្រុមហ៊ុនទូរស័ព្ទពីមួយទៅមួយទៀត។

- ទំនិញនាំចេញទៅក្រៅប្រទេសនូវផលិតផលមួយចំនួនដូចជា៖ ស្រាបៀ ស្រា ឬសុរាមេរ៉យ និងបារីថ្នាំជក់។

❖ **វិធីសាស្ត្រគណនាអាករពិសេស**

- ចំពោះទំនិញក្នុងស្រុក
  - **អាករពិសេស = បរិមាណទំនិញលក់ចេញ x ថ្លៃឯកតាទំនិញដែលត្រូវគិតពន្ធ x អត្រាពន្ធ**

*ករណីដែលបានបង់ពន្ធរួចទៅលើវត្ថុធាតុដើម អាករពិសេសត្រូវបង់នៅផ្នែកផលិតផលត្រូវបានគណនាតាមរូបមន្ត៖

  - **អាករពិសេសផ្នែកផលិតកម្ម = (អាករពិសេស - អាករពិសេសដែលបានបង់នៅលើវត្ថុធាតុដើម) x អត្រាពន្ធ**

- ចំពោះទំនិញនាំចូល

ការគណនាអាករពិសេសចំពោះទំនិញនាំចូលគឺត្រូវគណនារកពន្ធគយជាមុនសិន៖

  - **ពន្ធនាំចូល = តម្លៃគិតពន្ធគយ x អត្រាពន្ធនាំចូល**
  - **អាករពិសេស = (តម្លៃគិតពន្ធគយ + ពន្ធនាំចូល) x អត្រាអាករពិសេស**

➢ **ឧទាហរណ៍**៖ ក្រុមហ៊ុន ABC នាំចូលស្រាបៀចំនួន ២០កេសដែលមានតម្លៃគិតពន្ធគយស្មើ ៤លានរៀល។ ចូរគណនាអាករពិសេសដែលក្រុមហ៊ុនត្រូវបង់។

☞**ដំណោះស្រាយ៖**

- ពន្ធនាំចូល = ៤,០០០,០០០ x 0.៣៥ = ១,៤០០,០០០៛
- អាករពិសេស = (៤,០០០,០០០+ ១,៤០០,០០០) x 0.៣០ = ១,៦២០,០០០៛

ដូចនេះអាករពិសេសដែលក្រុមហ៊ុនត្រូវបង់ គឺ ១,៦២០,០០០៛។

### ១.៣.៥ អាករបំភ្លឺសាធារណៈ[19] ( Tax on Public Lighting )

អាករបំភ្លឺសាធារណៈ ត្រូវបានកំណត់ទៅលើគ្រប់ផលិតផលដែលមានជាតិសុរាមេរ៉យ និងបារី ដែលផលិតក្នុងស្រុក និងនាំចូលពីបរទេស។ រាល់ការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវសុរាមេរ៉យ (ស្រាបៀ ស្រាទំពាំងបាយជូរ លើកលែងតែទឹកត្នោតជូរ និងស្រាស) និងបារី ឬការដកយក

[19] ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រង និងប្រមូលអាករបំភ្លឺសាធារណៈរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ១៧៥សហវ.ពដ.ប្រក, ២២ មករា ឆ្នាំ ២០០២, ប្រការ ១និង២

ផលិតផលទាំងនេះមកប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន ត្រូវជាប់អាករបំភ្លឺសាធារណៈ តាមអត្រា ៣%។

- **មូលដ្ឋានគិតអាករ**នេះ គឺជាថ្លៃផ្គត់ផ្គង់កត់ត្រាក្នុងវិក័យប័ត្រឲ្យទៅអតិថិជនដោយមិនរួមបញ្ចូល៖
  - អាករលើតម្លៃបន្ថែម និងអាករបំភ្លឺសាធារណៈខ្លួនឯងសម្រាប់អ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាស។
  - អាករលើផលរបរ និងអាករបំភ្លឺសាធារណៈខ្លួនឯងសម្រាប់អ្នកជាប់ពន្ធក្នុងរបបម៉ៅការ។
- **ដើម្បីគណនាប្រាក់អាករ**នេះ បុគ្គលជាប់អាករ ត្រូវធ្វើការបែងចែកឲ្យច្បាស់រវាងផលរបរបានពីសុរាមេរ័យ និងបារី និងផលរបរបានពីការផ្គត់ផ្គង់ទំនិញ និងសេវាដទៃទៀត។
- **ការគណនាអាករ៖**

- មូលដ្ឋានគិតអាករ៖ ថ្លៃផ្គត់ផ្គង់ / (១+0.0៣) (ករណីថ្លៃផ្គត់ផ្គង់រួមបញ្ចូលទាំងអាករផ្សេងៗ)
- ប្រាក់អាករត្រូវបង់៖ មូលដ្ឋានគិតអាករ x 0.0៣

**ឧទាហរណ៍៖** ប្រាក់ចំណូលបានពីការលក់សុរាមេរ័យ និងបារីរួមបញ្ចូលទាំងអាករផ្សេងៗ ប្រចាំខែមេសា ឆ្នាំ ២០១៧ គឺ ២,000,000 រ។

☞**ដំណោះស្រាយ៖**

- មូលដ្ឋានគិតអាករ: ២,000,000 / ១.១(VAT) = ១,៨១៨,១៨១.៨១៨រ
- មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ: ១,៨១៨,១៨១.៨១៨ / ១.0៣ (TPL) = ១,៧៦៥,២២៥.0៦៦រ
- ប្រាក់អាករបំភ្លឺសាធារណៈ: ១,៧៦៥,២២៥.0៦៦ x 0.0៣ = ៥២,៩៥៦.៧៥រ

☞ដូចនេះប្រាក់អាករត្រូវបង់គឺ៖ ៥២,៩៥៦.៧៥រ។

### ១.៣.៦ អាករលើការស្នាក់នៅ[20] ( Accommodation Tax )

[20] ប្រកាសស្ដីពីការអនុវត្តអាករលើការស្នាក់នៅ, លេខ ៣៨០សហវ.ពដ, ១៩ កក្កដា ឆ្នាំ ២០០៥, ប្រការ ២ និង៣

អាករលើការស្នាក់ត្រូវបានកំណត់តាមអត្រា ២% លើថ្លៃបន្ទប់ស្នាក់នៅក្នុងសណ្ឋាគារក្នុងប្រទេសកម្ពុជា ដោយរួមបញ្ចូលទាំងពន្ធអាករ និងបន្ទុកសេវាផ្សេងៗ។ ការស្នាក់នៅសំដៅដល់៖ សណ្ឋាគារ, អាផាតមិន; សណ្ឋាគារស្វីត; រីសត; ម៉ូតែល; ឡូដ; បឹងកាឡូ; ផ្ទះសំណាក់; កន្លែងបោះជំរុំទេសចរណ៍; កន្លែងផ្តល់សេវាស្នាក់នៅដទៃទៀត។ **ពាក្យសណ្ឋាគារនេះមិនរួមបញ្ចូល ផ្ទះជួល ផ្ទះល្វែងជួលរយៈពេលខ្លី ឬវែងទេ។**

- **មូលដ្ឋានគិតអាករ**នេះ គឺជាថ្លៃផ្គត់ផ្គង់កត់ត្រាក្នុងវិក័យប័ត្រឲ្យទៅអតិថិជនដោយមិនរួមបញ្ចូល៖
  - អាករលើតម្លៃបន្ថែម និងអាករស្នាក់នៅខ្លួនឯងសម្រាប់អ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាស។
  - អាករលើផលរបរ និងអាករស្នាក់នៅខ្លួនឯងសម្រាប់អ្នកជាប់ពន្ធក្នុងរបបមៅការ។

❖ **ការគណនាអាករលើការស្នាក់នៅ**

- មូលដ្ឋានគិតអាករលើការស្នាក់នៅ = ថ្លៃបន្ទប់ / (១+០.០២) (ករណីថ្លៃបន្ទប់រួមបញ្ចូលទាំងអាករ)
- ប្រាក់អាករលើការស្នាក់នៅ = មូលដ្ឋានគិតអាករ x ០.០២
  - **ឧទាហរណ៍៖** អ្នកមានបន្ទប់ជួលមួយកន្លែងមានតម្លៃ ២៥០$ រួមទាំងបន្ទុកផ្សេងៗ និង អតប។ ចូរគណនាប្រាក់អាករលើការស្នាក់នៅ។

    ☞**ដំណោះស្រាយ៖**
- មូលដ្ឋានគិតអាករ: ២៥០ / ១.១ (VAT) = ២២៧.២៧ $
- មូលដ្ឋានគិតអាករលើការស្នាក់នៅ: ២២៧.២៧ / ១.០២ (AT) = ២២២.៨២ $
- ប្រាក់អាករលើការស្នាក់នៅ: ២២២.៨២ x ០.០២ = ៤.៤៥៦៤$

  ☞ប្រាក់អាករលើការស្នាក់នៅត្រូវបង់គឺ ៤.៤៥៦៤$។

### ១.៣.៧ ពន្ធប្រាក់រំដោះលើប្រាក់ចំណេញ[21] ( Prepayment on Income Tax )

- សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបស្វ័យប្រកាស ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើ

[21] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ២៨ថ្មី

ប្រាក់ចំណេញតាមអត្រា ១% នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់វៀលែង តែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។

- ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។
- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ត្រូវបង់ប្រចាំខែ និងត្រូវបូកយោងជាបន្តបន្ទាប់។

❖ **មូលដ្ឋានគិតពន្ធ**

- ត្រូវកំណត់ទៅលើសកម្មភាពអាជីវកម្មគ្រប់ប្រភេទ លើកលែងតែចំពោះអង្គភាពអាជីវកម្មបង់ពន្ធតាមរបបម៉ៅការ និងករណីព្យួរប្រាក់រំដោះ។
- ត្រូវកំណត់ប្រាក់រំដោះលើប្រាក់ចំណេញ ក្រោយពីដកអាករលើតម្លៃបន្ថែម។
- ត្រូវកំណត់ឲ្យកាត់កងពន្ធលើប្រាក់ចំណូលនៅចុងការិយបរិច្ឆេទនៃឆ្នាំជាប់ពន្ធនិមួយៗ។

❖ **ការលើកលែងពន្ធ**

- ចំពោះសហគ្រាសវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចជាវិស័យកាត់ដេរ និងដេរស្បែកជើង ត្រូវបានព្យួរប្រាក់រំដោះពន្ធលើប្រាក់ចំណេញ រហូតដល់ឆ្នាំ ២០១៧។
- ចំពោះអ្នកដាំស្រូវ អ្នកប្រមូលផលស្រូវ និងអ្នកផលិតអង្ករ សម្រាប់ការនាំចេញជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងកំឡុងពេលលើកលែងពន្ធ។
- ចំពោះគ្រឹះស្ថានសិក្សាដែលទទួលបានការព្យួរទុកការបង់ពន្ធប្រាក់រំដោះរហូតដល់ដំណាច់ឆ្នាំ ២០១៨
- ក្នុងកំឡុងពេលលើកលែងពន្ធលើប្រាក់ចំណេញចំនួន ២ឆ្នាំ ចំពោះសហគ្រាសតូច និងមធ្យមដែលបានទៅចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងកំឡុងឆ្នាំ ២០១៧ ដល់ ២០១៨។

❖ **ការគណនាពន្ធប្រាក់រំដោះ**

ប្រាក់ពន្ធត្រូវបង់ = មូលដ្ឋានគិតអាករ x ១%

➢ **ឧទាហរណ៍៖** ការលក់ផលិតផលភេសជ្ជៈប្រចាំខែ មេសា ឆ្នាំ ២០១៧ គឺ ៥០០,០០០៛ (រួមបញ្ចូលទាំងអាករ)។

☞**ដំណោះស្រាយ៖**

- មូលដ្ឋានគិតពន្ធ : ៥០០,០០០ / ១.១ = ៣៦៣,៦៣៦.៣៦៛
- ប្រាក់រំដោះពន្ធ : ៣៦៣,៦៣៦.៣៦ x 0.0១ = ៣,៦៣៦.៣៦៛

☞ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណេញត្រូវបង់គឺ៖ ៣,៦៣៦.៣៦៛។

# ១.៤ ប្រភេទពន្ធប្រកាសប្រចាំឆ្នាំ

## ១.៤.១ ពន្ធប៉ាតង់

### ១.៤.១.១ និយមន័យ

ពន្ធប៉ាតង់ ឬពន្ធចុះបញ្ជីអាជីវកម្មប្រចាំឆ្នាំ ជាប្រភេទពន្ធប្រចាំឆ្នាំដែលតម្រូវឲ្យបង់លើសកម្មភាពអាជីវកម្ម អាស្រ័យទៅនឹងប្រភេទអ្នកជាប់ពន្ធ និងកម្រិតផលរបរនៃសហគ្រាស ឬក្រុមហ៊ុន។

ផ្អែកលើនិយមន័យខាងលើ ពន្ធប៉ាតង់ ត្រូវបានកំណត់ឲ្យបង់លើសកម្មភាពអាជីវកម្ម ដែលក្រុមហ៊ុនប្រកប។ ដូច្នេះ សហគ្រាស ឬក្រុមហ៊ុនដែលជាអ្នកជាប់ពន្ធ មានប្រកបអាជីវកម្មមួយ ឬច្រើន ត្រូវបង់ពន្ធប៉ាតង់តាមចំនួនសកម្មភាពអាជីវកម្មនីមួយៗ។

ម្យ៉ាងវិញទៀត អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយនៅក្នុងខេត្ត ឬក្រុងតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយប៉ុណ្ណោះ។ ដោយឡែកតែ ទីតាំងទាំងនោះស្ថិតនៅក្នុងខេត្ត ឬក្រុងផ្សេងគ្នា គឺត្រូវបង់ពន្ធប៉ាតង់ទៅតាមទីតាំងដែលអាជីវកម្មនៅស្ថិតនៅ។ សកម្មភាពជាឧបសម្ព័ន្ធ ចាត់ទុកជាសកម្មភាពអាជីវកម្មតែមួយ នោះត្រូវបង់ពន្ធប៉ាតង់តែមួយប៉ុណ្ណោះ។[22]

❖ គោលបំណង

ដើមហេតុដែល បង្កើតពន្ធប៉ាតង់នេះឡើង រដ្ឋាភិបាលមានគោលបំណង

- បង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងពាណិជ្ជកម្មជាតិ
- ដឹងពីចំនួន បែងចែកប្រភេទ ទំហំរបស់បណ្តាលអាជីវកម្មសហគ្រាសដើមឆ្នាំនៅគ្រប់ឆ្នាំទាំងអស់
- ងាយស្រួលកំណត់ និងណែនាំសហគ្រាសដែលមានក្នុងស្រុកឲ្យដើរស្របតាមទិសដៅរីកចម្រើនសេដ្ឋកិច្ចជាតិ
- ប្រមូលបាននូវចំណូលជាតិ ដើម្បីអភិវឌ្ឍន៍ប្រទេស។

### ១.៤.១.២ ការលើកលែងពន្ធប៉ាតង់

បើទោះបីជា ពន្ធប៉ាតង់ ត្រូវបានកំណត់លើគ្រប់អាជីវកម្មទាំងអស់ មិនថាអចល័ត និងចល័ត ក្នុងវិស័យផលិតឈើ អនុផលព្រៃឈើ នេសាទ សំណង់ គមនាគមន៍ដឹកជញ្ជូន ពាណិជ្ជកម្មសេវាកម្មក្រោមរូបភាពជា ក្រុមហ៊ុនរដ្ឋ ចម្រុះរូបវន្តបុគ្គល ឬសមាគមន៍ អង្គភាពរដ្ឋ ដែល

[22] ប្រកាសស្តីពីវិធានការ និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់, លេខ១៨២១ សហវ.ប្រក, ២៥ ធ្នូ ២០១៥

ប្រកបអាជីវកម្ម មិនអនុវត្តរបបស្ដីពីហិរញ្ញវត្ថុរដ្ឋក៏ដោយ ក៏ពន្ធប៉ាតង់នេះមានការលើកលែងផង ដែរលើ៖

- មុខរបរបន្ទាប់បន្សំសម្រាប់បន្ថែមឲ្យជីវភាពគ្រួសារ
- បណ្ដាសិប្បកម្មលក្ខណៈគ្រួសារសម្រាប់ប្រើប្រាស់ ឬលក់ដូរបន្តិចបន្តួច
- មន្ត្រីរាជការ បុគ្គលិករដ្ឋ និស្សិត សិស្សានុសិស្ស ដែលឆ្លៀតពេលទំនេរពីការងារ ឬការសិក្សា ទៅធ្វើការបន្ថែម....
- អង្គការ និងសមាគមន៍នានាដែលមានសកម្មភាពមិនស្វែងរកប្រាក់ចំនេញ....។

### ១.៤.១.៣ កាលបរិច្ឆេទ និងទីកន្លែងបង់ពន្ធ

❖ សហគ្រាសចាស់

ពន្ធប៉ាតង់ ត្រូវបង់ក្នុងអំឡុងពេលដើមឆ្នាំសម្រាប់ឆ្នាំនោះតែម្ដង គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនាជារៀងរាល់ឆ្នាំ។ ឧទាហរណ៍: ពន្ធប៉ាតង់២០១៧ ត្រូវបង់នៅកំលុងពេល ៣ ខែដើមឆ្នាំ២០១៧។

❖ សហគ្រាសថ្មី

សម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបង់ពន្ធប៉ាតង់ស្របពេលជាមួយការចុះបញ្ជីពន្ធដារដែលត្រូវធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃ ក្រោយមានសកម្មភាពសេដ្ឋកិច្ច ឬក្រោយកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម។ សហគ្រាសដែលចាប់ផ្ដើមប្រកបអាជីវកម្មនៅ ៦ខែដំបូងនៃឆ្នាំជាប់ពន្ធ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ពេញ។ ចំណែកឯសហគ្រាសដែលចាប់ផ្ដើមប្រកបអាជីវកម្មនៅ ៦ខែចុងក្រោយនៃឆ្នាំជាប់ពន្ធ ត្រូវបង់ពន្ធប៉ាតង់តែពាក់កណ្ដាលស្មើនឹងពាក់កណ្ដាល។

និយាយពីទីតាំងបង់ពន្ធវិញ គឺពន្ធប៉ាតង់ត្រូវបង់នៅរដ្ឋបាលសារពើពន្ធ (អគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារស្រុក-ខណ្ឌ) ដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបសកម្មភាពអាជីវកម្មពិតប្រាកដស្ថិតនៅ។

### ១.៤.១.៤ កម្រិតប្រាក់ពន្ធប៉ាតង់

*តារាង៦៖ មូលដ្ឋានគិតពន្ធប៉ាតង់*

| ប្រភេទ | ផលរបរប្រចាំឆ្នាំ | ប្រាក់ពន្ធប៉ាតង់ |
|---|---|---|
| អ្នកជាប់ពន្ធតូច | ២៥០លានរៀល ដល់ ៧០០លានរៀល | ៤០០,០០០រៀល |
| អ្នកជាប់ពន្ធមធ្យម | ៧០០លានរៀល ដល់ ២,០០០លានរៀល | ១,២០០,០០ រៀល |
| អ្នកជាប់ពន្ធធំ | ២,០០០លានរៀល ដល់ ១០,០០០លានរៀល | ៣,០០០,០០ រៀល |

| | | |
|---|---|---|
| | លើសពី១០,០០០លានរៀល | ៥,០០០,០០ រៀល |
| | សាខា រោងចក្រ ឃ្លាំងសម្រាប់សកម្មភាពអាជីវកម្មតែមួយ(ខេត្ត ក្រុងផ្សេងគ្នា) | ៣,០០០,០០ រៀល |

(សេចក្តីណែនាំស្តីពីការដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ២០១៧, លេខ១៨៩៧អពដ, ៣១ មករា ២០១៧)

#### ១.៤.១.៥ ការផ្លាស់ប្តូរ

- ទីតាំង ឬសកម្មភាពអាជីវកម្ម: រដ្ឋបាលសារពើពន្ធ នឹងចាត់ទុកថាទើបចាប់ផ្តើមអាជីវកម្ម ដោយត្រូវចុះបញ្ជីឡើងវិញ និងបង់ពន្ធប៉ាតង់ថ្មី។ ករណីលើកលែង ចំពោះគោលការណ៍ផ្លាស់ប្តូរជំរុញលើកទឹកចិត្តដែលទទួលស្គាល់ពីរដ្ឋបាលមូលដ្ឋាន ដោយមិនបាច់បង់ពន្ធប៉ាតង់ឡើងវិញទេ គ្រាន់តែទៅកែសម្រួលព័ត៌មានទីតាំងឬសកម្មភាពអាជីវកម្ម ហើយសុំប្តូរប័ណ្ណប៉ាតង់ប៉ុណ្ណោះ។
- ម្ចាស់សហគ្រាស: ម្ចាស់សហគ្រាសថ្មីត្រូវបង់ពន្ធប៉ាតង់ឡើងវិញ បើទោះជាម្ចាស់សហគ្រាសចាស់បង់ហើយក៏ដោយ។ ករណីលើកលែង ចំពោះម្ចាស់សហគ្រាសថ្មី ដែលឪពុក ឬម្តាយ ប្តីឬប្រពន្ធ កូនឬអ្នកស្នងស្របច្បាប់របស់ម្ចាស់ចាស់ មិនចាំបាច់បង់ពន្ធប៉ាតង់ឡើងវិញទេ គ្រាន់តែទៅកន្លែងសុំចុះបញ្ជីសារពើពន្ធ ផ្លាស់ប្តូរឈ្មោះ ព័ត៌មានពាក់ព័ន្ធ និងរូបថត ហើយព្រីនប៉ាតង់ថ្មីជាការស្រេច។

### ១.៤.២ ពន្ធលើប្រាក់ចំណេញ

#### ១៤.២.១ និយមន័យ

ក្នុងមាត្រា ២ នៃច្បាប់សារពើពន្ធឆ្នាំ២០០៣ ពន្ធលើប្រាក់ចំនេញ គឺជាបំណុលរបស់បុគ្គលនិវាសនជនចំពោះប្រភពប្រាក់ចំណូលប្រភពកម្ពុជា[23] និងប្រាក់ចំណូលប្រភពបរទេស[24] និងរបស់បុគ្គលអនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

ពន្ធលើប្រាក់ចំណេញ ជាប្រភេទពន្ធប្រចាំឆ្នាំដែលត្រូវបង់ដោយអ្នកជាប់ពន្ធរបបស្វ័យប្រកាស លើចំណូលជាប់ពន្ធប្រចាំឆ្នាំ ដែលត្រូវបានគណនាចេញពីលទ្ធផលនៃតុល្យការសម្រេចបានក្នុងឆ្នាំសារពើពន្ធកន្លងមក។ ចំពោះសហគ្រាសថ្មី ត្រូវគិតចាប់តាំងពីថ្ងៃដែលផ្តើមធ្វើប្រតិបត្តិការមកទល់នឹងថ្ងៃទី៣១ ធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ។

#### ១៤.២.២ អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

[23] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ៣៣ថ្មី

[24] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ៣៤ថ្មី

*តារាងទី៧៖ តារាងប្រភេទ និងអត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ*

| ប្រភេទ | អត្រា |
|---|---|
| នីតិបុគ្គលទូទៅ(អត្រាស្តង់ដា) | ២០% |
| អាជីវកម្មប្រេងកាត ឧស្ម័នធម្មជាតិ ធនធានធម្មជាតិ រ៉ែ | ៣០% |
| សហគ្រាសធានារ៉ាប់រង[25] (លើបុព្វលាភធានារ៉ាប់រងដុល) | ៥% |
| គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | 0% |
| សមាជិកក្រុមហ៊ុនសហកម្មសិទ្ធិមិនចាត់ទុកជានីតិបុគ្គល(តាមអត្រាកំណើនតាមថ្នាក់) | 0%ទៅ២០% |

(ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ២០ថ្មីមួយ)

**១៤.២.៣ ប្រាក់ចំណេញជាប់ពន្ធ**

ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទរួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបាន ក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្ម ការប្រាក់ ថ្លៃឈ្នួលនិងសួយសារ ព្រមទាំងប្រាក់ចំណេញពីទ្រព្យកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគ រាប់ទាំងអចលនទ្រព្យផង។ប្រាក់ចំណេញជាប់ពន្ធក៏រាប់បញ្ចូលផងដែរនូវចំណេញមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគដែលរូបវន្ត ឬនីតិបុគ្គល សម្រេចបានមកពីប្រតិបត្តិការនានា ក្រៅពីប្រតិបត្តិការអាជីវកម្ម។[26]

ប្រាក់ចំណេញជាប់ពន្ធ គឺប្រាក់ចំណេញបានកើតឡើងក្នុងឆ្នាំគិតពន្ធ ដែលត្រូវបានគណនាចេញពីប្រាក់ចំណេញ ឬខាតគណនេយ្យ និងក្រោយធ្វើការកែតម្រូវសម្រាប់ចំណាយកាត់កងមិនបាន និងប្រាក់ចំណេញមិនជាប់ពន្ធ។

*តារាងទី៨៖ ទំនាក់ទំនងនៃរបាយការណ៍លទ្ធផល និងតារាងគណនាពន្ធលើប្រាក់ចំណេញ*

| Profit & Loss Account | | Tax on Profit Computation | |
|---|---|---|---|
| Sale | xxx | Accounting profit before tax | xxx |
| CoGS | (xxx) | Add back: | |
| Gross Profit | xxx | Non-deductible expenses | xxx |
| Expenses | (xxx) | Deduct: | |

[25] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ២១ថ្មី

[26] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ៧ថ្មី

| | | | |
|---|---|---|---|
| Accounting profit before tax | xxx | Deductible expenses | (xxx) |
| Tax Expenses | (xxx) | Taxable profit | xxx |
| Net Profit | xxx | Tax on profit-20% | xxx |

(ទៀ វ៉ាន់ថា "Cambodia Taxation", មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុឆ្នាំទី៤)

➢ **ចំណូលជាប់ពន្ធ**

- ចំណូលចំបង ឬចំណូលប្រតិបត្តិការ សំដៅដល់ប្រាក់ចំណូលដែលរកបានពីការបំពេញសកម្មភាពអាជីវកម្មចម្បងជាក់ស្តែងរបស់អង្គភាពផលិតកម្ម ពាណិជ្ជកម្មអាជីវកម្ម សេវាកម្ម ក្នុងការិយបរិច្ឆេទ ទោះខ្លួនចំណូលនោះបានទូទាត់ ឬមិនទាន់បានទូទាត់ក្តី។
- ចំណូលបន្ទាប់បន្សំ គឺជាចំណូលដទៃផ្សេងទៀត ដែលមិនជាប់ទាក់ទងនឹងសកម្មភាពអាជីវកម្មចម្បងរបស់សហគ្រាស ប៉ុន្តែបានចូលរួមមួយផ្នែកក្នុងការបង្កើនចំណូល និងផ្តល់ផលប្រយោជន៍ដល់សហគ្រាស។

**១.២.៤.៤ ចំណាយអាជីវកម្ម**

ចំណាយអាជីវកម្ម គឺជាចំណាយទាំងឡាយណាដែលអ្នកជាប់ពន្ធបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធនីមួយៗ ហើយធ្វើឡើងដើម្បីប្រកបអាជីវកម្ម និងជាផលប្រយោជន៍អាជីវកម្ម។ ជាទូទៅ ចំណាយក្នុងអាជីវកម្មនីមួយៗ មានលក្ខណៈខុសគ្នាដាច់ដោយឡែកទៅតាមប្រភេទ និងទំហំនៃអាជីវកម្មនោះ។ ប៉ុន្តែក្នុងគោលដៅចសព ចំណាយទាំងនោះត្រូវបានបែងចែកជាពីរធំៗ ចំណាយកាត់កងបាន និងចំណាយមិនអាចកាត់កងបាន។

- **ចំណាយកាត់កងបាន** ជាចំណាយដែលនឹងត្រូវដកចេញពីប្រាក់ចំណេញមុនជាប់ពន្ធ។ ចំណាយកាត់កងបានត្រូវគោរពតាមលក្ខខណ្ឌ៣[27]យ៉ាង៖
  - o មានអំណះអំណាង៖ ជាចំណាយពិតជាក់ស្តែង ដែលមានបញ្ជាក់អះអាងដោយភស្តុតាងដែលអាចត្រួតពិនិត្យ និងទទួលស្គាល់ដោយរដ្ឋបាលពន្ធដារ ដូចជា វិក័យបត្រប្រតិវេទន៍គយ លិខិតឆ្លើយឆ្លងពាណិជ្ជកម្ម កិច្ចសន្យាខ្ចីប្រាក់។....
  - o ចេញជាលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ច៖ ជាចំណាយដែលបានកើតឡើង នៅពេលដែលទ្រព្យសកម្ម ឬសេវានោះត្រូវបានផ្គត់ផ្គង់ ទោះបានទូទាត់ ឬមិនទាន់បានទូទាត់ក្តី។ ឬនៅពេលដែលអ្នកជាប់ពន្ធខ្លួនឯង បានប្រើប្រាស់នូវទ្រព្យសកម្ម ឬសេវានោះ។ ឬនៅ

[27] "Diploma in Cambodia Tax" (CamEd Business School 2011) ទំព័រ ៤ និង៥

ពេលមានការទូទាត់សង នូវការប៉ះប៉ូវឲ្យកម្មករ សំណងជំងឺ ឬសំណងលើការបំពានកិច្ចសន្យា ការចុះថ្លៃ ឬការបង្វិលសងវិញ ប្រាក់រង្វាន់ផ្សេង សំណងលើការទទួលធានា ឬតាមកិច្ចព្រមព្រៀងផ្តល់សេវា និងប្រាក់ពន្ធនានា។

- o មានបញ្ជាក់ចំនួនច្បាស់លាស់៖ ជាចំនាយដែលមានកំណត់ និងបង្ហាញចំនួនទឹកប្រាក់ច្បាស់លាស់ ហើយត្រូវបានធ្វើគណនេយ្យកម្មក្នុងអំឡុងនៃការិយបរិច្ឆេទប្រកាសពន្ធ និងមានភស្តុតាងបញ្ជាក់ត្រឹមត្រូវ។

- លក្ខខណ្ឌបន្ថែមសម្រាប់ចំណាយកាត់កងបានមាន៖
  - o បំណុលពិតប្រាកដរបស់អ្នកជាប់ពន្ធ ដែលជាចំណាយមិនទាន់បានទូទាត់នៅដំណាច់ឆ្នាំជាប់ពន្ធ
  - o ប្រាក់បៀវត្សដែលមិនទាន់បានបើក ក្នុងករណីប្រាក់បៀវត្សនោះនឹងត្រូវបានបើកក្នុងអំឡុងពេល ៦០ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់។

- **ចំណាយមិនអាចកាត់កងបាន**[28] ជាចំណាយ ដែលនឹងបូកបញ្ចូលមកវិញជាមួយប្រាក់ចំណេញមុនជាប់ពន្ធ មុនពេលដកចេញចំនាយកាត់កងបាន។
  - o ចំណាយរំលស់គណនេយ្យ ឬសំវិធានធនដែលកត់ត្រាខុសគោលការណ៍ ឬកត់ត្រាលើស សហគ្រាសត្រូវបញ្ចូលមកវិញ
  - o ចំណាយលើសកម្មភាពនានាដែលចាត់ទុកថាជាការកំសាន្ត ការសម្រាកលំហែ ការទទួលភ្ញៀវ ឬការប្រើប្រាស់មធ្យោបាយណាមួយ ដែលជាប់ទាក់ទងនឹងសកម្មភាពទាំងនោះ
  - o ចំណាយលើការរស់នៅផ្ទាល់ខ្លួន ឬក្រុមគ្រួសារ
  - o ចំណាយលើពន្ធលើប្រាក់ចំណេញ រំដោះពន្ធលើប្រាក់ចំណេញ ពន្ធអប្បបរមា
  - o ការខាតបង់លើការលក់ ឬការដោះដូរទ្រព្យសម្បត្តិរវាងបុគ្គលជាប់ទាក់ទិន
  - o ចំណាយនានាផ្សេងទៀត។

**១.២.៤.៥ របាយការណ៍លទ្ធផល និងតារាងតុល្យការ**

ក្នុងរបាយការណ៍លទ្ធផលនេះ មានពីរផ្នែកធំៗ គឺចំណូល និងចំណាយ។ សម្រាប់ចំណូល មានចំណូលប្រតិបត្តិការដែលជាចំណូលចំបង និងចំណូលផ្សេងៗដែលជាចំណូល

[28] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ១៩

បន្ទាប់បន្សំ ហើនិងចំនាយប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់គណនាលទ្ធផលចំណេញខាតប្រចាំឆ្នាំ។ តារាងតុល្យការ គឺត្រូវបានរៀបចំឡើងដោយយោងទៅតាមតារាងតុល្យការគណនេយ្យដែលដាច់ខាតទ្រព្យសកម្ម ត្រូវស្មើនឹងមូលនិធិ/ទុនម្ចាស់ទ្រព្យ និងបំណុល។

**១.២.៤.៦ វិភាគទានសប្បុរសធម៌**

ការចំនាយសម្រាប់វិភាគទានសប្បុរសធមិទៅដល់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល ឬអង្គការដែលបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធមិ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬការអប់រំ ដោយមិនត្រូវបានបម្រើជាផលប្រយោជន៍ឯកជន។ ចំនាយវិភាគទានសប្បុរសធមិនេះ ត្រូវបានរដ្ឋបាលពន្ធដារទទួលស្គាល់ លុះត្រាសហគ្រាសបានធ្វើការស្នើសុំ និងបញ្ជាក់ពីភាពបាត់បង់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំនួនទឹកប្រាក់វិភាគទានសប្បុរសធមិ ដែលអាចធ្វើការកាត់កង មិនត្រូវលើសពី៥%នៃប្រាក់ចំណេញជាប់ពន្ធ មុនពេលធ្វើការកាត់កងវិភាគទានសប្បុរសធមិ[29]។

សម្រាប់ចំនួនលើសជាចំនួនមិនអាចកាត់កងបាន ហើយមិនអាចយោងទៅឆ្នាំមុខបានទេ ដូច្នោះចំនួនលើសនោះ និងត្រូវបូកបញ្ចូលក្នុងប្រាក់ចំនេញជាប់ពន្ធវិញ។

**១.២.៤.៧ ចំណាយការប្រាក់**[30]

ចំណាយការប្រាក់ ជាប្រភេទចំនាយដែលអាចកាត់កងបានក្នុងច្បាប់ពចប ប៉ុន្តែចំនួនទឹកប្រាក់ចំណាយលើការប្រាក់ត្រូវបានអនុញ្ញាតឲ្យកាត់កងបានស្ថិតក្នុងកម្រិតទឹកប្រាក់កំណត់មួយដែលត្រូវគោរពតាមពីករណីៈ

- មិនឲ្យលើសពីផលបូកនៃចំណូលការប្រាក់អ្នកជាប់ពន្ធ
- ៥០% នៃប្រាក់ចំណូលសុទ្ធគ្មានការប្រាក់

ចំណាយការប្រាក់ដែលនៅសល់ ឬមិនត្រូវបានអនុញ្ញាតឲ្យយកមកកាត់កង អាចយោងជាចំណាយការប្រាក់សម្រាប់ឆ្នាំបន្តបន្ទាប់ទៀត សម្រាប់ធ្វើការកាត់កងដោយគោរពតាមពីរករណីខាងលើរហូតចំណាយការប្រាក់នោះត្រូវបានកាត់កងអស់។

- ចំណាយការប្រាក់អាចត្រូវបានបូក ឬដកចេញពីប្រាក់ចំណេញជាប់ពន្ធៈ
  - បើសរុបចំណាយការប្រាក់អាចកាត់កងតូចជាងចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ នោះចំនួនលំអៀងត្រូវបូកបន្ថែមប្រាក់ចំនេញជាប់ពន្ធ

[29] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ១៦
[30] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ១២

- បើសរុបចំណាយការប្រាក់អាចកាត់កងធំជាងចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ នោះចំនួនលំអៀងត្រូវដកចេញពីប្រាក់ចំណេញជាប់ពន្ធ

- ចំណាយការប្រាក់នឹងត្រូវបានយោងទៅមុខ បើចំណាយការប្រាក់អតិបរមាអនុញ្ញាតឲ្យកាត់កងបានក្នុងការិយបរិច្ឆេទ តូចជាងសរុបនៃចំណាយការប្រាក់ក្នុងការិយបរិច្ឆេទ និងយោងពីឆ្នាំមុន។

### ១.២.៤.៨ ឥណទានខាតយោងទៅមុខ[31]

យោងតាមមាត្រា ១៧នៃច្បាប់ចសព ក្នុងករណីដែលមានការខាតបង់នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ការខាតបង់នោះត្រូវចាត់ទុកជាបន្ទុកសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយត្រូវកាត់ចេញពីប្រាក់ចំណេញសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះ។ បើប្រាក់ចំណេញនេះ មិនគ្រប់គ្រាន់សម្រាប់ទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ ដែលនៅសល់ ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥។

នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ មាត្រានេះត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយតាមលំដាប់ដែលការខាតបង់បានកើតឡើង។

### ១.២.៤.៩ រំលស់តាមច្បាប់សារពើពន្ធ[32]

រំលស់ទ្រព្យសកម្មរបស់សហគ្រាសនីមួយៗក្នុងរបបស្វ័យប្រកាស ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម ទើបអាចធ្វើការកាត់កងបាន៖

  - o រំលស់ត្រូវធ្វើតែលើអអចលនកម្មដែលកត់ត្រាទុកទ្រព្យសកម្មនៃតារាងតុល្យភាពរបស់សហគ្រាស
  - o រំលស់ត្រូវធ្វើតែលើអចលនកម្មដែលទទួលរងការសឹករេចរឹល
  - o រំលស់ត្រូវធ្វើនៅលើមូលដ្ឋាន និងដែនកំណត់នៃថ្លៃដើម
  - o រំលស់ត្រូវគណនាតាមវិធីរំលស់ស្មើភាគសម្រាប់ទ្រព្យសកម្មស្ថិតក្នុងថ្នាក់ទី១ ឬវិធីរំលស់ថយជាលំដាប់សម្រាប់ទ្រព្យសកម្មស្ថិតក្នុងថ្នាក់ទី ២ ថ្នាក់ទី៣ និងថ្នាក់ទី៤។
  - o រំលស់ត្រូវធ្វើយ៉ាងពិតប្រាកដដោយសហគ្រាស។

- ទ្រព្យអរូបី

[31] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ១៧

[32] "Diploma in Cambodia Tax" (CamEd Business School 2011) ទំព័រ ១០ និង១១

ទ្រព្យអរូបី មានដូចជាប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិចម្លង គំនូរប្លង់ គំរូនិងសិទ្ធិអាជីវកម្ម.... ដែលមានអាយុកាលមានកំណត់ អត្រារំលស់នីមួយៗ ត្រូវគណនាដោយផ្អែកលើអាយុកាលរបស់ឆ្នាំត្រូវទ្រព្យនោះតាមវិធីរំលស់ស្មើភាគ។ ប្រសិនបើជាអាយុកាលមិនអាចកំណត់បាន រំលស់ប្រចាំ ១០អនុវត្តតាមអត្រា ភាគរយលើតម្លៃទ្រព្យអរូបី។

សម្រាប់ទ្រព្យអរូបីហិរញ្ញវត្ថុ ដូចជាមូលប័ត្រ ភាគកម្ម និងទ្រព្យអរូបីហិរញ្ញវត្ថុផ្សេងទៀតមិនអាចរំលស់បានទេ ពីព្រោះវាមិនសឹករេចរិល ទៅតាមការប្រើប្រាស់ ឬពេលវេលាទេ។

- ទ្រព្យរូបី

តាមមាត្រា ១៣ ថ្មី ទ្រព្យរូបីទាំងអស់ ត្រូវបានបែងចែកជាថ្នាក់ដូចតទៅ៖

- ថ្នាក់ទី ១ (អត្រា៥%) អាគារ និងរចនាសម្ព័ន្ធ ព្រមទាំងសមាសភាគរបស់វា តាមវីធីរំលស់ស្មើភាគ។
- ថ្នាក់ទី ២ (អត្រា៥០%) កុំព្យូទ័រ ប្រព័ន្ធព័ត៌មានអេឡិចត្រូនិច សូហ្វវែរ និងបរិក្ខារទុកដាក់ទិន្នន័យ តាមវិធីរំលស់ថយជាលំដាប់។
- ថ្នាក់ទី ៣ (អត្រា២៥%) រថយន្ត រថយន្តដឹកទំនិញគ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ តាមវិធីរំលស់ថយជាលំដាប់។
- ថ្នាក់ទី ៤ (អត្រា២០%) ទ្រព្យរូបីឯទៀតទាំងអស់ តាមវិធីរំលស់ថយជាលំដាប់។

- រំលស់តាមវិធីសាស្ត្រស្មើភាគ ត្រូវកាត់បន្ថយដាក់ជាចំណាយនូវតម្លៃនៃទ្រព្យសកម្មរយៈពេលវែងក្នុងចំនួនស្មើនឹងអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មរយៈពេលវែងនោះ។ ឧទាហរណ៍៖ ប្រសិនបើ ទ្រព្យសកម្មរយៈពេលវែងមួយមានអាយុកាលប្រើប្រាស់រយៈពេល ៥ឆ្នាំ តម្លៃនៃទ្រព្យសកម្មរយៈពេលវែងនោះត្រូវកាត់បន្ថយដាក់ជាចំណាយក្នុងចំនួនសរុបស្មើរយៈពេល ៥ឆ្នាំ។ រំលស់ត្រូវគណនាដោយក "តម្លៃនៃទ្រព្យសកម្មរយៈពេលវែង" គុណនឹងអត្រារំលស់សម្រាប់ទ្រព្យសកម្មនោះ។[33]
- រំលស់តាមវិធីសាស្ត្រថយជាលំដាប់ ត្រូវគណនាដោយយក "តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម" គុណនឹងអត្រារំលស់សម្រាប់ទ្រព្យសកម្មនោះ។

**១.២.៤.១០ សំវិធានធន**

[33] សេចក្តីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០០៦

សម្រាប់តែធនាគារ និងស្ថាប័នសញ្ញ័យធនក្នុងស្រុក ត្រូវភ្ជាប់មកជាមួយតារាងលំអិត។ សំវិធានធនលើហានិភ័យជាក់ស្តែង ជាចំណាយអាចកាត់កងបាន។

**១.២.៤.១១ បំណុលពន្ធលើប្រាក់ចំណេញត្រូវបង់**[34]

បំណុលពន្ធលើប្រាក់ចំណេញត្រូវបង់ គឺជាលទ្ធផលនៃការប្រៀបធៀបរវាង បំណុលពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា។

❖ **បំណុលពន្ធលើប្រាក់ចំណេញ**[35]

ការគណនាបំណុលពន្ធលើប្រាក់ចំនេញសរុប ដោយគណនាប្រាក់ពន្ធលើប្រាក់ចំណេញទៅតាមអត្រាដែលអ្នកជាប់ពន្ធជាប់ ហើយដកឥណទានបរទេស និងឥណទានពន្ធបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ(ប្រសិនបើមាន)។

❖ **ពន្ធអប្បបរមា**

យោងតាមមាត្រា ២៨ថ្មី(ពីរ) នៃវិសោធនម្មលើច្បាប់សារពើពន្ធកម្ពុជាឆ្នាំ២០១៣ ពន្ធអប្បបរមា ត្រូវបានកំណត់ស្មើនឹង ១ភាគរយនៃផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតែអាករលើតម្លៃបន្ថែម។ ពន្ធអប្បបរមាគត្រូវបង់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលដែលបានបង់ជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធនោះ។ ពន្ធអប្បបរមាគត្រូវបង់ នៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណេញ។

- ករណីបំណុលពន្ធលើប្រាក់ចំណេញ ធំជាងពន្ធអប្បបរមា៖
  - ប្រាក់បំណុលពន្ធលើប្រាក់ចំណេញ ជាប្រាក់ពន្ធដែលអ្នកជាប់ពន្ធត្រូវទូទាត់
- ករណីបំណុលពន្ធលើប្រាក់ចំណេញ តូចជាងពន្ធអប្បបរមា៖
  - ប្រាក់ពន្ធអប្បបរមាដែលត្រូវបានកាត់បន្ថយ ជាប្រាក់ពន្ធដែលត្រូវបង់

**១.២.៤.១២ ពន្ធលើប្រាក់ចំណេញត្រូវបង់ ឬត្រូវយោងទៅឆ្នាំបន្ទាប់**[36]

ពន្ធលើប្រាក់ចំណេញអាចត្រូវបង់នៅក្នុងឆ្នាំជាប់ពន្ធ ហើយក៏អាចត្រូវយោងទៅឆ្នាំបន្ទាប់ អាស្រ័យទៅនឹងផលធៀបនៃបំណុលពន្ធលើប្រាក់ចំណេញត្រូវបង់ នឹងផលបូកសរុបនៃចំនួនប្រាក់ពន្ធកាត់ទុក(WHT) និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញ(PPT)៖

- ករណីបំណុលពន្ធលើប្រាក់ចំណេញត្រូវបង់ ធំជាងផលបូក WHT និងPPT៖

[34] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ៣៩

[35] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ៣៧

[36] ច្បាប់សារពើពន្ធកម្ពុជា, លេខ នស/រកម/០៣០៣/០១០, ថ្ងៃទី ៣១ មីនា ២០០៣, មាត្រា ៣៨

- ចំនួនដែលលំអៀង ជាចំនួនប្រាក់ពន្ធដែលអ្នកជាប់ពន្ធត្រូវបង់បន្ថែម

➢ ករណីបំណុលពន្ធលើប្រាក់ចំណេញត្រូវបង់ តូចជាងផលបូក WHT និងPPT៖

- ចំនួនដែលលំអៀង ជាចំនួនប្រាក់ពន្ធអាចសុំបង្វិលសង ឬយោងទៅឆ្នាំបន្ទាប់

**១៤.២.១៣ ការគណនាពន្ធលើប្រាក់ចំណេញ**

ពន្ធលើប្រាក់ចំណេញត្រូវបានឆ្លងកាត់ការគណនាលំអិតបន្តបន្ទាប់។ សម្រាប់ព័ត៌មាននៃធាតុនីមួយក្នុងលិខិតប្រាក់ពន្ធលើប្រាក់ចំណេញអាចមើលនៅក្នុងឧបសម្ព័ន្ធទី២។ ខាងក្រោមនេះជាតារាងសង្ខេបការគណនាពន្ធលើប្រាក់ចំណេញ៖

*តារាងទី៩៖ គណនាពន្ធលើប្រាក់ចំណេញ*[37]

| | | |
|---|---|---|
| **ប្រាក់ចំណេញមុនបង់ពន្ធ** | | **XXX** |
| បូក៖ ចំណាយមិនអាចកាត់កងបាន | XXX | |
| បូក៖ ចំណូលជាប់ពន្ធមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ | XXX | |
| ដក៖ ចំណាយមិនកត់ត្រាក្នុងបញ្ជីគណនេយ្យតែអាចកាត់កងបាន | (XXX) | |
| ដក៖ ចំណូលមិនជាប់ពន្ធកត់ក្នុងបញ្ជីគណនេយ្យ | (XXX) | |
| **ប្រាក់ចំណេញ/ខាតក្រោយនិយ័តកម្ម** | | **XXX** |
| បូក៖ វិភាគទានសប្បុរសធម៌មិនឲ្យកាត់កង | | XXX |
| **ប្រាក់ចំណេញ/ខាតមុននិយ័តកម្មលើការប្រាក់** | | **XXX** |
| បូក/ដក៖ និយ័តកម្មលើការប្រាក់ | | XXX/(XXX) |
| **ប្រាក់ចំណេញ/ខាតក្នុងការិយបរិច្ឆេទ** | | **XXX** |
| ដក៖ ខាតយោងពីឆ្នាំមុនអនុញ្ញាត | | (XXX) |
| **ប្រាក់ចំណេញ/ខាតជាប់ពន្ធសម្រាប់គណនាពន្ធលើប្រាក់ចំណេញ** | | **XXX** |
| ពន្ធលើប្រាក់ចំណេញតាមអត្រា (%) ឧ. ២០% | | XXX |
| ដក៖ ឥណទានពន្ធបរទេស | | (XXX) |
| ដក៖ ឥណទានពន្ធបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ | | (XXX) |
| **បំណុលពន្ធលើប្រាក់ចំណេញ** | | **XXX** |
| *ពន្ធអប្បបរមា* | | *XXX* |

[37] "Diploma in Cambodia Tax" (CamEd Business School 2011) ទំព័រ ៧ និង៨

| | | |
|---|---|---|
| **បំណុលពន្ធលើប្រាក់ចំណេញត្រូវបង់**(TOP &MMT Which is higher?) | | |
| *សម្រាប់គម្រោង QIP | | XXX |
| *សម្រាប់គម្រោង None QIP | | XXX |
| ដកៈ ឥណទានពន្ធកាត់ទុកបានបង់ក្នុងឆ្នាំ | | (XXX) |
| ដកៈ ឥណទានពន្ធលើប្រាក់ចំណេញយោងពីឆ្នាំមុន | | (XXX) |
| **ពន្ធលើប្រាក់ចំណេញត្រូវបង់/ត្រូវយោងទៅឆ្នាំបន្ទាប់** | | |
| *សម្រាប់គម្រោង QIP | | XXX |
| *សម្រាប់គម្រោង None QIP | | XXX |

(“Diploma in Cambodia Tax” (CamEd Business School 2011) ទំព័រ ៧ និង៨)

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់

# ក្រុមហ៊ុន ខេមវីល គ្លូបិល

# ខូអិលធីឌី

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ខេមវីល គ្លូបិល

## ២.១ ប្រវត្តិរបស់ក្រុមហ៊ុន

ក្រុមហ៊ុន ខេមវីល គ្លូបិល ខូអិលធីឌី ជាប្រភេទក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦ ដោយកំណត់យក «សេវាកម្រេជើងសារលើការដឹកជញ្ជូនទំនិញ» ជាសកម្មភាពអាជីវកម្មចំបងដោយមានការទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ។ ក្រុមហ៊ុននេះជាប្រភេទក្រុមហ៊ុនដែលផ្តល់សេវាកម្មដឹកជញ្ជូន ដែលមានអាយុកាលក្មេងខ្ចីជាងគេបន្តិច ព្រោះក្រុមហ៊ុនទើបតែចាប់ផ្តើមសកម្មភាពអាជីវកម្មរបស់ខ្លួន ចាប់តាំងពី ខែ មិថុនា ឆ្នាំ ២០១៦ រហូតមកដល់បច្ចុប្បន្ន។ ក្រុមហ៊ុននេះត្រូវបានបង្កើតឡើងដោយពាណិជ្ជករជាជនជាតិខ្មែរ និងមានដំណើរការយ៉ាងរលូនមកទល់សព្វថ្ងៃ ក្រោមការដឹកនាំដ៏ប៉ិនប្រសប់របស់អគ្គនាយកក្រុមហ៊ុន។ នៅដំណាក់កាលចាប់ផ្តើមអាជីវកម្មដំបូង ក្រុមហ៊ុនជួបប្រទះភាពស្មុគ្រស្មាញខ្លះៗដែរ ដោយសារការឈានជើងចូលទីផ្សារដំបូងមានភាពពិបាកក្នុងការស្វែងរក អតិថិជន ក៏ដូចជាដៃគូពាណិជ្ជកម្ម ដូច្នេះទាមទារឲ្យក្រុមហ៊ុនត្រូវចេះប្រើយុទ្ធសាស្ត្រទីផ្សារឲ្យបានត្រឹមត្រូវ។ រហូតមកដល់ពេលនេះ ក្រុមហ៊ុនមានដំណើរការល្អប្រសើរ ដែលជាមោទនភាពមួយរបស់ម្ចាស់ក្រុមហ៊ុន ក៏ដូចជាបុគ្គលិកទាំងអស់ លើសពីនេះទៀតក្រុមហ៊ុនបានចូលប្រឡូកក្នុងទីផ្សារកម្ពុជាយ៉ាងជោគជ័យ និងបានពង្រីកវិសាលភាពកាន់តែធំ តាមរយៈកំនើនបុគ្គលិក និងអតិថិជនជាលំដាប់។

## ២.២ ទីតាំង ស្លាកសញ្ញា និងការចុះបញ្ជីអាជីវកម្ម

- **ទីតាំង**

  ក្រុមហ៊ុនខេមវីល គ្លូបិល មានទីស្នាក់ការកណ្តាលស្ថិតនៅ៖

  - អាស័យដ្ឋាន៖ ផ្ទះលេខ 2J ផ្លូវលេខ ១៩៨០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។
  - អ៊ីមេល៖ info@camwillglobal.com
  - វេបសាយ៖ www.camwillglobal.com
  - ទូរស័ព្ទ៖ (+៨៥៥) ២៣ ២៣១ ៧២៦ / (+៨៥៥) ១៧ ៩១៨ ៨៨០ / (+៨៥៥) ៨៧ ៥០៨ ០៨៨

- **ស្លាកសញ្ញា**

ស្លាកសញ្ញា (Logo) របស់ក្រុមហ៊ុនជា អក្សរកាត់ជាភាសាអង់គ្លេសបីតួអក្សរ ពីឈ្មោះពេញរបស់ក្រុមហ៊ុន ជាភាសាអង់គ្លេស Camwill Global Co.,Ltd ឬ (CWG)

*រូបភាពទី១៖ ស្លាកសញ្ញារបស់ក្រុមហ៊ុន*

- **ការចុះបញ្ជីអាជីវកម្ម**

ក្រុមហ៊ុនខេមវីល គ្លូប៊ល បានចុះបញ្ជីពាណិជ្ជកម្មជាមួយក្រសួងពាណិជ្ជកម្ម (វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម)[38] នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦ ដោយមាននាមករណ៍ «ខេមវីល គ្លូប៊ល ឯ.ក» (Camwill Global Co.,LTD) និងត្រូវបានទទួលស្គាល់ថាជា ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។ បន្ទាប់មកក្រុមហ៊ុន បានចុះបញ្ជីជាមួយពន្ធដារ (វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ)[39] ដោយមានលេខអត្តសញ្ញាណកម្មសារពើពន្ធ K009-901637190 មានសកម្មភាពអាជីវកម្មចម្បងកម្រៃជើងសារលើការដឹកជញ្ជូនទំនិញ និងស្ថិតក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខណ្ឌសែនសុខ ដែលការចុះបញ្ជីនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០១៦ តទៅ។

## ២.៣ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

- **ចក្ខុវិស័យ**

ក្រុមហ៊ុនខេមវីល គ្លូប៊លមានចក្ខុវិស័យចង់ក្លាយជាអ្នកផ្តល់សេវាកម្មដឹកជញ្ជូនដ៏មានវិជ្ជាជីវៈ និងមានសមត្ថភាព ប្រកបដោយលក្ខណៈស្តង់ដារអន្តរជាតិតាមរយៈការបំពេញបេសកកម្មអោយបានសំរេចដូចខាងក្រោម។

[38] សូមមើលឧបសម្ព័ន្ធទី៣

[39] សូមមើលឧបសម្ព័ន្ធទី៣

- **បេសកកម្ម**

បេសកកម្មរបស់ក្រុមហ៊ុនខេមវីល គ្លូប៊ល គឺធ្វើយ៉ាងណាដើម្បីក្លាយជាអ្នកផ្តល់សេវាកម្មដឹកជញ្ជូនឈានមុខគេក្នុងស្រុក និងមានការទទួលស្គាល់ពីសំណាក់អតិថិជន និងវិនិយោគិន តាមរយៈការផ្តល់ភាពសំខាន់ជូនតំរូវការអតិថិជនជាលំដាប់ទី១ ដោយប្តេជ្ញាមុតមាំថានឹងផ្តល់ជូនអតិថិជននូវ៖

- បំពេញរាល់តំរូវការរបស់អតិថិជន
- ផ្តល់ជូននូវសេវាដឹកជញ្ជូនឆាប់រហ័ស មានប្រសិទ្ធភាព និងតម្លៃសមរម្យ
- បន្តអភិវឌ្ឍរាល់ប្រតិបត្តិការសេវាកម្មទាំងអស់ ដើម្បីការរីកចំរើននៃអាជីវកម្ម។

- **គុណតម្លៃ**

គុណតម្លៃរបស់ក្រុមហ៊ុនជាគឺជាក្រមសីលធម៌ ឬជាគោលការណ៍ សម្រាប់ជាមគ្គុទេសន៍ដល់និយោជិតគ្រប់គ្នាប្រតិបត្តិតាមក្នុងពេលបំពេញការងារ៖

- បុគ្គលិក និងការបំពេញការងាររបស់ពួកគេពិតជាមានសារៈសំខាន់ណាស់ចំពោះក្រុមហ៊ុន
- កិត្តិយស និងកេរ្តិ៍ឈ្មោះល្អជារបស់មានតម្លៃបំផុត
- ភាពយុត្តិធម៌ និងភាពស្មោះត្រង់ជាតម្លៃរបស់ក្រុមហ៊ុន
- អតិថិជន និងអ្នកផ្គត់ផ្គង់ទាំងអស់របស់ក្រុមហ៊ុនសុទ្ធតែជាដៃគូជំនួញល្អៗ
- ភាពជោគជ័យក្នុងការបំពេញការងារជាអ្វីដែលម្ចាស់ភាគហ៊ុនរំពឹងទុក។

## ២.៤ ដៃគូពាណិជ្ជកម្ម

ក្រុមហ៊ុន CWG បានក្លាយជាសមាជិកម្នាក់ក្នុង សមាគមភ្នាក់ងារបញ្ជូនទំនិញកម្ពុជា (Cambodia Freight Forwarders Association) និង សមាគមដឹកជញ្ជូនទំនិញកម្ពុជា (Cambodia Trucking Association)តាំងពីចាប់ផ្តើមអាជីវកម្មម្ល៉េះដោយសារការខិតខំប្រឹងប្រែងរបស់ នាយកក្រុមហ៊ុន។ ការបានចូលជាសមាជិកក្នុងសមាគមទាំងពីរនេះ បានផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាងណាស់ដល់ក្រុមហ៊ុនផ្ទាល់ ដូចជាការបានទទួលនូវចំនេះដឹងថ្មីៗ តាមរយៈការចូលរួមសិក្ខាសាលា និងបានស្វែងរកនូវដៃគូពាណិជ្ជកម្មថ្មីៗបន្ថែម ក៏ដូចជាពង្រីកមុខមាត់ក្រុមហ៊ុនក្នុងទីផ្សារលើសពីនេះទៀត ដៃគូពាណិជ្ជកម្មរបស់ក្រុមហ៊ុនគឺ៖

- LogAsia SCM Co., Ltd៖ ជាក្រុមហ៊ុនដឹកជញ្ជូនដ៏ល្បីឈ្មោះមួយរបស់ប្រទេសវៀតណាម។

## ២.៥ សកម្មភាពរបស់ក្រុមហ៊ុន

សេវាកម្មដែលក្រុមហ៊ុនផ្តល់ឲ្យអតិថិជនរួមមាន៖

១. ឯកសារពន្ធគយ (Service of Shipping Documents & Customs Clearance)

- វិភាគរបាយការណ៍ដែលចាំបាច់ ហើយគណនាប្រាក់ពន្ធ
- ប្រកាសពន្ធគយ
- ជួយស្នើសុំលិខិតអនុញ្ញាតពី គយ និង កាំកុងត្រូល
- ផ្ទៀងផ្ទាត់តម្លៃក្នុងវិក័យប័ត្រជាមួយទំនិញជាក់ស្តែង

២. បញ្ជូនទំនិញបន្តតាមផ្លូវអាកាស សមុទ្រ និងគោក (Freight Forwarding Service-Air, Sea & Land)

- បញ្ជូនទំនិញបន្តខ្នាតអន្តរជាតិ
- ការនាំចេញ-ចូល ទំនិញតាមផ្លូវអាកាស
- ការនាំចេញ-ចូល ទំនិញតាមផ្លូវសមុទ្រ
- ការផ្ទេរទំនិញពីនាវាមួយ ទៅនាវាមួយទៀត។

៣. ដេប៉ូកុងតេន័រ (Container Depot Service)

- លើកដាក់ទំនិញពីកុងតេន័រ
- កន្លែងផ្ញើកុងតេន័រ
- លាង និងសំអាតកុងតេន័រ
- ជួសជុល និងថែរក្សាកុងតេន័រ

៤. ឃ្លាំង និងការចែកចាយ (Warehouse & Distribution)

- គ្រប់គ្រងស្តុកទំនិញ
- ត្រួតពិនិត្យគុណភាព លេខបារកូដ វេចខ្ចប់ឡើងវិញ និងបិទស្លាកសញ្ញា
- អ្នកយាមឃ្លាំង
- អ្នកលក់ ឬអ្នកដឹកជញ្ជូនឥវ៉ាន់
- ចែកចាយទៅហាងលក់រាយ

៥. ការដឹកទំនិញក្នុងស្រុក និងក្រៅស្រុក (Transportation Inland & Cross Border)

- ទំនិញពេញកុងតេន័រ (Full Container Loading)
- ទំនិញមិនពេញកុងតេន័រ (Less Container Loading)

- បន្ទុកទំនិញធ្ងន់ៗ (Heavy Cargo)
- ឡានដឹកទំនិញឆ្លងប្រទេស (Cross Border Trucking)

៦. លើកដាក់ទំនិញ (Project Cargos)

- បញ្ចូលទំនិញក្នុងកុងតេន័រ ទោះបីជាទំនិញនោះមានទំហំធំហួសខ្នាតកុងតេន័រក៏ក្រុមហ៊ុនមានដំណោះស្រាយជូនដែរ
- សេវាកម្មលើកទំនិញដែលធ្ងន់ដើម្បីដឹកជញ្ជូនតាមផ្លូវថ្នល់។

## ២.៦ រចនាសម្ព័ន្ធក្រុមហ៊ុន



# ជំពូកទី ៣

# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូក ៣

# លទ្ធផលនៃការស្រាវជ្រាវ

## ៣.៣ ការចុះបញ្ជីពន្ធដាររបស់ក្រុមហ៊ុន

ដើម្បីបើកដំណើរការក្រុមហ៊ុនស្របតាមច្បាប់ ក្រុមហ៊ុនខេមរីលគ្លូប៊ិល ឆ្លងកាត់ដំណាក់កាលជាច្រើន ក្នុងកិច្ចការស្រាវជ្រាវនេះ សុំធ្វើការលើកឡើងត្រឹម ការចុះបញ្ជីពន្ធដារ មកធ្វើការរៀបរាប់។

បន្ទាប់ពីទទួលបានលិខិតទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនខេមរីលគ្លូប៊ិលបានទៅសាលាជាតិពន្ធដារ ដើម្បីធ្វើការបំពេញពាក្យសុំធ្វើការចុះបញ្ជីពន្ធដារ និងភ្ជាប់ឯកសារតម្រូវសំខាន់ៗ បន្ទាប់មកធ្វើការបង់ប្រាក់ និងបង់ប្រាក់ពន្ធប៉ាតង់ជាមួយគ្នាតែម្តង។

ក្រោយពីចុះបញ្ជីរួចក្នុងចន្លោះ៧ ទៅ១០ថ្ងៃ មន្ត្រីពន្ធដារក៏បានមកដល់ក្រុមហ៊ុនក្នុងគោលបំណងពីរគឺ យកឯកសារដូចជា វិញ្ញាបនប័ត្រចុះបញ្ជីពន្ធដារ ឬអាករលើតម្លៃបន្ថែម; ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ; ប័ណ្ណប៉ាតង់ និងលិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ មកដល់ក្រុមហ៊ុន និងដើម្បីត្រួតពិនិត្យថា ក្រុមហ៊ុន ពិតជាបានបង្កើតសកម្មភាពអាជីវកម្ម និងព័ត៌មានដែលបំពេញក្នុងពាក្យសុំចុះបញ្ជីនោះ ដូចជាអាស័យដ្ឋានក្រុមហ៊ុនជាដើម ពិតជាត្រឹមត្រូវគ្មានការក្លែងបន្លំ ដោយបានសាកសួរ បញ្ជាក់បន្ថែម និងថតទីតាំងសកម្មភាព ក្នុងក្រុមហ៊ុនផងដែរ។ ក្រោយពីត្រួតពិនិត្យសព្វគ្រប់ រួចមកមន្ត្រីពន្ធដារមិនបានរកឃើញចំណុចខុសឆ្គងអ្វីឡើយ រួចក៏ឲ្យតំណាងក្រុមហ៊ុនម្នាក់ចុះហត្ថលេខាបានទទួលឯកសារជាការស្រេច ហើយរាល់ឯកសារទាំងនោះ ក្រុមហ៊ុនអាចប្រើប្រាស់ទៅតាមការគួរគ្រប់សកម្មភាពដែលត្រូវការ។ បន្ថែមពីនោះ ចាប់ពីថ្ងៃខែឆ្នាំដែលបានដាក់ក្នុងវិញ្ញាបនប័ត្រអាករលើតម្លៃបន្ថែមដែលទទួលបាននោះ សរបញ្ជាក់ថាក្រុមហ៊ុនត្រូវជាប់ភារៈបង់ពន្ធប្រចាំ ខែ និងប្រចាំឆ្នាំ ចាប់ពីខែនោះតទៅ។ ដោយក្រុមហ៊ុនខេមរីល គ្លូប៊ិលចុះបញ្ជី នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០១៦ ដូចនេះក្រុមហ៊ុន បានជាប់ភារៈបង់ពន្ធប្រចាំខែ និងប្រចាំឆ្នាំចាប់ពីខែមិថុនា ឆ្នាំ ២០១៦តទៅ។

## ៣.២ ដំណើរការការប្រកាសពន្ធប្រចាំខែ

ជាការពិតអគ្គនាយកដ្ឋានពន្ធដារបានជូនដំណឹង និងបង្ហាញពីដំណើរការលក្ខណៈទូទៅមួយ ដើម្បីបង្កភាពងាយស្រួលដល់អ្នកជាប់ភារៈបង់ពន្ធក្នុងការបង់ពន្ធជូនរដ្ឋឲ្យបានទាន់ពេលវេលា និងត្រឹមត្រូវក៏ដោយ។ ប៉ុន្តែរដ្ឋបាលពន្ធដារក៏មិនបានចង្អុលបង្ហាញគ្រប់ចន្លោះនៃការប្រ

កាសពន្ធដូចជាការប្រមូលឯកសារ ការរៀបចំឯកសារដើម្បីប្រកាសពន្ធឡើយ។ ហេតុដូចនេះគ្រប់ក្រុមហ៊ុន ក៏ដូចជាភ្នាក់ងារសេវាពន្ធដារ ឬគណនេយ្យករ មានវិធីសាស្ត្រ និងរបៀបរៀបចំឯកសារខុសៗគ្នា។ បើក្រឡេកមើលក្រុមហ៊ុនខេមរីល គ្លូប៊ិលគឺមានវិធីសាស្ត្រ និងដំណាក់កាលក្នុងការរៀបចំប្រកាសពន្ធរបស់ខ្លួនផងដែរ។ ជារៀងរាល់ខែ ក្រុមហ៊ុនខេមរីល គ្លូប៊ិលប្រើប្រាស់វិធីសាស្ត្រតែមួយក្នុងដំណើរការប្រកាសពន្ធរបស់ខ្លួន។

ខាងក្រោមនេះគឺជាដំណើរការនៃការប្រកាសពន្ធប្រចាំខែ ដែលភ្ជាប់ជាមួយ ឯកសារ និងលិខិតប្រកាសពន្ធខែមីនាជាឧទាហរណ៍ដូចតទៅ៖

### ៣.២.១ ការប្រមូលឯកសារ

ដំណាក់កាលដំបូងក្នុងការប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ិល គឺការប្រមូលឯកសារសំខាន់ៗពាក់ព័ន្ធនិងចាំបាច់ដែលត្រូវប្រកាសពន្ធដូចជា៖

❖ តារាងអត្រាការប្រាក់ប្រចាំខែ

តារាងអត្រាការប្រាក់ប្រចាំខែនេះ គណនេយ្យករបានទាញយកយ៉ាងងាយស្រួលពីវេបសាយរបស់អគ្គនាយកដ្ឋានពន្ធដារកម្ពុជា (http://www.tax.gov.kh/) ដោយមានទម្រង់ដូចក្នុងឧបសម្ព័ន្ធទី ៥។

❖ តារាងចំណូលប្រចាំខែ

គណនេយ្យករត្រូវទាញយកឯកសាររបាយការណ៍ចំណូលប្រចាំខែមុន ដែលគណនេយ្យករទទួលបន្ទុកគណនីត្រូវទទួល (AR Accountant)។ ក្នុងរបាយការណ៍នោះមានបញ្ចូលគ្នានៃចំណូលដែលអាចប្រកាសពន្ធបាន (Tax Invoice) និងមិនអាចប្រកាសពន្ធបាន ដូចជា Debit Note, Reimbursement...

❖ តារាងបញ្ជីចំនាយ និងវិក័យប័ត្រចំនាយ

សម្រាប់រាល់ការចំនាយ អ្នកជាប់ភារៈប្រកាសពន្ធរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ិលត្រូវធ្វើការប្រមូលមិនត្រឹមតែបញ្ជីចំនាយប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រមូលរាល់វិក័យប័ត្រចំនាយទាំងអស់មកធ្វើការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យគ្រប់ចំណាយព្រោះចំនាយទាំងនោះខ្លះជាប់ពន្ធអាករលើតម្លៃបន្ថែមជាប់ពន្ធកាត់ទុក ខ្លះមិនជាប់អាករ ឬមិនជាប់ឥណទាននិងវិក័យប័ត្រចំនាយដែលពន្ធដារមិនទទួលស្គាល់[40]។

[40] សូមមើលឧបសម្ព័ន្ធទី១៖ សេចក្តីណែនាំស្តីពីការប្រើប្រាស់វិក័យប័ត្រ

❖ តារាងបញ្ជីប្រាក់ខែ

បញ្ជីប្រាក់ខែ ត្រូវយកពីគណនេយ្យករដែលរៀបចំបញ្ជីប្រាក់បៀវត្សបុគ្គលិកប្រចាំខែដែលអ្នកត្រូវប្រកាស និងពីផ្នែកធនធានមនុស្ស ដើម្បីទទួលបានចំនួនទឹកប្រាក់ដែលបុគ្គលិកទទួលបាន ព្រមទាំងព័ត៌មានមួយចំនួនទាក់ទងនឹងបុគ្គលិកនីមួយៗផងដែរដូចជា ចំនួនប្រពន្ធកូន មុខងារ...។

### ៣.២.២ ការរៀបចំឯកសារ

រាល់ឯកសារដែលប្រមូល បានពីគណនេយ្យករ និងផ្នែកដែលពាក់ពន្ធ័រួចមក។ ជំហានបន្ទាប់គឺការរៀបចំឯកសារទាំងនោះដើម្បីទទួលបានព័ត៌មាន ទិន្នន័យ និងឯកសារ តម្រូវក្នុងការបំពេញ និងកិបភ្ជាប់លិខិតប្រកាសពន្ធ។ ជាទូទៅការជ្រើសរើស កម្មវិធីក្នុងការកាន់កាប់បញ្ជីការគណនេយ្យ និងប្រើប្រាស់កម្មវិធីគណនេយ្យកុំព្យូទ័រខុសៗគ្នា ទៅតាមក្រុមហ៊ុនខ្លះប្រើប្រាស់ QuickBooks ខ្លះប្រើប្រាស់Peachtree...... ឬមានកម្មវិធីគណនេយ្យមួយផ្ទាល់ខ្លួនប្រើប្រាស់តែម្តង។ ចំពោះក្រុមហ៊ុនខេមវីល គ្លូបិល Quickbooks ត្រូវបានប្រើប្រាស់ ក្នុងការកត់ត្រារាល់ចំណូល ចំនាយ បញ្ជីការគណនេយ្យរបស់ក្រុមហ៊ុន ដោយកត់ត្រាជាភាសាអង់គ្លេស និងកត់ត្រាចំនួនទឹកប្រាក់ជារូបិយប័ណ្ណដុល្លារ។ ផ្ទុយពីរដ្ឋបាលពន្ធដារ ដែលតម្រូវឲ្យរាល់ចំនួនទឹកប្រាក់ប្រកាសពន្ធត្រូវគិតជាប្រាក់រៀល។ ជាដំណោះស្រាយ ដើម្បីធ្វើការដាក់លិខិតប្រកាសពន្ធនេះបាន ក្រុមហ៊ុនបានរៀបចំឯកសារតារាងបញ្ជីជាភាសាខ្មែរ លាយភាសាអង់គ្លេស ពិសេសប្តូរទឹកប្រាក់ពីរូបិយប័ណ្ណដុល្លាទៅជារៀល ដោយផ្អែកលើតារាងអត្រាប្តូរប្រាក់ដែលអគ្គនាយកដ្ឋានពន្ធដារបានបង្ហោះក្នុងវេបសាយ។ ជាមួយគ្នានេះដែរ គណនេយ្យករដែលទទួលភារៈត្រូវរៀបចំឯកសារ បានរៀបចំតារាងក្នុងកម្មវិធីMicrosoft Excel ចំនួន 3Sheetsធំៗគឺ

❖ តារាងលម្អិតពន្ធលើប្រាក់បៀវត្សចំពោះនិយោជិក[41]

*រូបភាពទី២៖ គំរូបញ្ជីប្រាក់បៀវត្សបុគ្គលិក*


បញ្ជីប្រាក់បៀវត្សន៍បុគ្គលិក
ខែ មិនា ឆ្នាំ ២០១៧
CAMWELL GLOBAL Co.,Ltd
K009-901637190
Rate: 3,986

| Nº | Name of Employee | | Function | Salary to be paid (USD) | Over Time (OT) (USD) | Deduction from Salary (USD) | Salary to be Paid Before Tax (Riels) | Spouse | Children | Allowance | Salary Tax Calculation Base (Riels) | Tax Rate | Tax on Salary (Riels) | Net Salary | Remark |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | [illegible] | Sok San | Driver | 100 | | | 398,600 | 1 | 0 | 150,000 | 248,600 | 0% | 0 | 100.00 | |

[41] សូមមើលឧបសម្ព័ន្ធទី ៩៖ បញ្ជីប្រាក់បៀវត្សបុគ្គលិក

(បញ្ជីប្រាក់បៀវត្សន៍បុគ្គលិកក្រុមហ៊ុនខេមរីល គ្លូប៊ល)

ជាក់ស្តែងតារាងនេះត្រូវបានរដ្ឋបាលសារពើពន្ធរៀបចំឡើងក្នុងលិខិតប្រកាសពន្ធលើប្រាក់បៀវត្ស (ពបវ) តែម្តងរួចទៅហើយ ក៏ប៉ុន្តែដោយសារចំនួនបុគ្គលិកក្នុងក្រុមហ៊ុនមានចំនួនច្រើនជាងប្រអប់ក្នុងតារាងនោះ ទើបក្រុមហ៊ុន ជាទូទៅ រៀបចំតារាងលម្អិតពន្ធលើប្រាក់បៀវត្សចំពោះនិយោជិត សម្រាប់ជាឯកសារភ្ជាប់ជាមួយលិខិតប្រកាសពន្ធលើប្រាក់បៀវត្ស។ ក្រុមហ៊ុនខេមរីល គ្លូប៊ល បានរៀបចំតារាងប្រាក់បៀវត្សឲ្យបុគ្គលិកម្នាក់ៗជារៀងរាល់ខែ ដោយអនុវត្តបានយ៉ាងខ្ជាប់ខ្ជួនទៅតាមការណែនាំ និងស្របតាមច្បាប់សារពើពន្ធកម្ពុជាកំណត់។ ជាក់ស្តែងក្រុមហ៊ុន ខេមរីល គ្លូប៊ល មានបុគ្គលិកសុទ្ធតែជានិវាសនជន ដូចនេះតារាងនេះក្រុមហ៊ុនបានរៀបចំសម្រាប់តែបុគ្គលិកនិវាសនជនដូចមានក្នុងឧបសម្ព័ន្ធទី៥ប៉ុណ្ណោះ។ ដោយតារាងលម្អិតពន្ធលើប្រាក់បៀវត្សចំពោះនិយោជិត ត្រូវបានធ្វើការគណនាក្នុងកម្មវិធី Microsoft Excel ដើម្បីគណនាប្រាក់ពន្ធលើប្រាក់បៀវត្សហើយចំណុចសំខាន់ៗដែលអ្នកទទួលភារៈរៀបចំឯកសារត្រូវផ្តោតលើ នោះ រួមមាន៖

- អត្រាប្តូរប្រាក់: សម្រាប់ប្រាក់បៀវត្សប្រចាំខែដែលត្រូវប្រកាសពន្ធ ដែលជាអត្រាប្តូរប្រាក់ចេញដោយរដ្ឋបាលពន្ធដារក្នុងវេបសាយ មកបំពេញក្នុងប្រអប់អត្រាប្តូរប្រាក់(N5) ទើបធ្វើការគណនាបានព្រោះការកត់ត្រា និងការបើកប្រាក់បៀវត្សឲ្យបុគ្គលិកជារូបិយប័ណ្ណដុល្លា។

*រូបភាពទី៣៖ អត្រាប្តូរប្រាក់សម្រាប់ប្រាក់បៀវត្ស*

| | | | |
|---|---|---|---|
| 14-16 | 1$ | 3,986 រៀល | បៀវត្ស |

(សេចក្តីជូនដំណឹងស្តីពីអត្រាប្តូរប្រាក់ផ្លូវការប្រចាំខែមីនា ឆ្នាំ២០១៧)

- ប្រាក់បៀវត្សបើកឲ្យបុគ្គលិក(USD): ការកត់ត្រាក្នុងបញ្ជី និងការបើកប្រាក់បៀវត្សឲ្យបុគ្គលិក ក្រុមហ៊ុនប្រើប្រាស់ជារូបិយប័ណ្ណដុល្លារ។
- ប្រាក់បៀវត្សបើកឲ្យបុគ្គលិកមុនកាត់ពន្ធ(Riel): ដើម្បីធ្វើការគណនាប្រាក់ពន្ធលើប្រាក់បៀវត្សបាន ត្រូវគុណប្រាក់បៀវត្សបើកឲ្យបុគ្គលិក (USD) និងអត្រាប្តូរប្រាក់ (សម្រាប់ប្រាក់បៀវត្សប្រចាំខែ)។
- សហព័ទ្ធ (ប្តី ឬប្រពន្ធ): កត់ត្រាចំនួនប្តី ឬប្រពន្ធរបស់បុគ្គលិក ដែលច្បាប់សារពើពន្ធអនុញ្ញាតឲ្យធ្វើការកាត់បន្ថយពន្ធលើប្រាក់បៀវត្សបាន។

- កូន: កត់ត្រាចំនួនកូនក្នុងបន្ទុករបស់បុគ្គលិក ដែលច្បាប់សារពើពន្ធអនុញ្ញាតឲ្យធ្វើការកាត់បន្ថយពន្ធលើប្រាក់បៀវត្សបាន។
    - ❖ កំណត់សម្គាល់៖ ឆ្នាំ២០១៦ សហព័ទ្ធ និងកូន អនុញ្ញាតឲ្យកាត់បន្ថយពន្ធ ក្នុងម្នាក់ចំនួន ៧០,០០០រៀល។ ឆ្នាំ២០១៧ សហព័ទ្ធ និងកូន អនុញ្ញាតឲ្យកាត់បន្ថយ ពន្ធក្នុងម្នាក់ចំនួន ១៥០,០០០រៀល។
- ទឹកប្រាក់កាត់បន្ថយ: គណនេយ្យករក្រុមហ៊ុនខេមរីល គ្លូប៊ល បានប្រើប្រាស់រូបមន្ត =Round((E+F)*150000,0) សម្រាប់ប្រាក់បៀវត្សឆ្នាំ២០១៧
- មូលដ្ឋានគិតពន្ធបរ: ស្មើប្រាក់បៀវត្សបើកឲ្យបុគ្គលិកមុនកាត់ពន្ធ(Riel) ដកទឹកប្រាក់ត្រូវកាត់បន្ថយ។ (H=D-G)

ដោយសារមានការកែសម្រួលប្រាក់បៀវត្សជាប់ពន្ធ ដូចនេះធ្វើឲ្យតារាងគណនាប្រាក់ពន្ធកាត់ទុកលើប្រាក់បៀវត្សបុគ្គលិកមានការប្រើប្រាស់រូបមន្តគណនាខុសគ្នារវាងឆ្នាំ២០១៦ និង២០១៧៖

- អត្រាពន្ធ
    - ➢ ២០១៦៖ គណនាតាមរូបមន្ត =IF(L6>12500000,20%,IF(L6>8500000,15%,IF(L6>1250000,10%,IF(L6>800000,5%,0))))
    - ➢ ២០១៧៖ គណនាតាមរូបមន្ត =IF(L6>12500000,20%,IF(L6>8500000,15%,IF(L6>1500000,10%,IF(L6>1000000,5%,0))))
- ពន្ធលើប្រាក់បៀវត្ស: សម្រាប់ឆ្នាំ២០១៧ ត្រូវបានគណនាតាមរូបមន្ត៖ =IF(N10=5%,ROUND(M10*N10-50000,0),IF(N10=10%,ROUND(M10*N10-125000,0),IF(N10=15%,ROUND(M10*N10550000,0),IF(N10>20%,ROUND(M10*N10-1175000,0),0))))
- ប្រាក់បៀវត្សក្រោយបង់ពន្ធ: ត្រូវគណនាដើម្បីដឹងពីចំនួនទឹកប្រាក់ដែលក្រុមហ៊ុនត្រូវចំនាយ និងជាប្រាក់បៀវត្សពិតដែលបុគ្គលិកទទួលបានក្រោយកាត់ពន្ធលើប្រាក់បៀវត្ស។

*រូបភាពទី៤៖ គំរូតារាងគណនាពន្ធលើប្រាក់បៀវត្សនិវាសនជន*

| | A | C | D | E | F | G | H | I | J |
|---|---|---|---|---|---|---|---|---|---|
| 91 | No | | No. of Employee | Salary to be Paid Before Tax (Riels) | Spouse | Children | Tax on Salary Calculation Base | Tax Rate | Tax on Salary |
| 92 | | | A | B | C | D | : B-(C+D)*75,( | F | G |
| 93 | 1 | | 31 | 24,693,270 | 18 | 19 | 19,143,270 | 0% | 0 |
| 94 | 2 | | 7 | 8,649,620 | 1 | - | 8,499,620 | 5% | 144,981 |
| 95 | 3 | | 8 | 34,678,200 | 4 | 10 | 32,578,200 | 10% | 2,437,820 |
| 96 | 4 | | - | 0 | - | - | 0 | 15% | 0 |
| 97 | 5 | | - | 0 | - | - | 0 | 20% | 0 |
| 98 | **TOTAL** | | **46** | **68,021,090** | **23** | **29** | **60,221,090** | | **2,582,801** |

(តារាងគណនាក្នុងMicrosoft Excel)

ជាមួយតារាងតារាងលម្អិតពន្ធលើប្រាក់បៀវត្សចំពោះនិយោជិកដែលនឹងភ្ជាប់ជាមួយលិខិតប្រកាសពន្ធ ក្រុមហ៊ុនក៏មានតារាង ព័ត៌មានសំខាន់ៗជាសង្ខេបមួយ សម្រាប់បំពេញក្នុងលិខិតប្រកាសពន្ធផងដែរ។ តារាងនោះមានធាតុសំខាន់ដែលត្រូវជាប់ពន្ធតាមអត្រាពន្ធនីមួយៗ បូករួមនឹងរូបមន្តសម្រាប់គណនាផងដែរ៖

- ចំនួនបុគ្គលិក៖ ដោយគណនាតាមរូបមន្ត =COUNTIF($M$6:$M$43,H60)
- ប្រាក់បៀវត្សបើកឲ្យបុគ្គលិកមុនកាត់ពន្ធ(Riel)៖ គណនាតាមរូបមន្ត =SUMIF($M$6:$M$43,$H$60,$H$6:$H$43)
- ចំនួនសហព័ទ្ធសរុប៖ ដោយគណនាតាមរូបមន្ត =SUMIF($M$6:$M$48,$H$65,$I$7:$I$48)
- ចំនួនកូនសរុប៖ ដោយគណនាតាមរូបមន្ត =SUMIF($M$6:$M$48,$H65,$J$6:$J$48)
- ចំនួនមូលដ្ឋានគិតពន្ធបវ៖ ដោយគណនាតាមរូបមន្ត =SUMIF($M$6:$M$48,$H65,$L$6:$L$48)
- អត្រាពន្ធ ដោយគ្រាន់តែដាក់បញ្ចូលអត្រាពន្ធ មានដូចជា ០% ៥% ១០% ១៥% ២០%
- ពន្ធលើប្រាក់បៀវត្ស៖ ត្រូវបានគណនាតាមរូបមន្ត =SUMIF($M$6:$M$48,$H65,$N$6:$N$48)
- ចំនួនសរុបនៃធាតុនីមួយៗ ដោយប្រើរូបមន្ត Sum ឧទាហរណ៍៖ ចំនួនសរុបនៃចំនួនបុគ្គលិកស្មើ =SUM(C65:C69)។

❖ សៀវភៅទិន្នានុប្បវត្តិទិញប្រចាំខែ

*រូបភាពទី៥៖ គំរូសៀវភៅទិន្នានុប្បវត្តិទិញ*

សៀវភៅទិន្នានុប្បវត្តិទិញ

ខែ មីនា ឆ្នាំ ២០១៧

**ក្រុមហ៊ុន ខេមវីល គ្លូបិល ខូអិលធីឌី** — លេខអត្តសញ្ញាណកម្មអតប K009-901637190

CAMWILL GLOBAL Co.,Ltd

ផ្ទះលេខ 2J ផ្លូវ 1980 សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ — Rate : 3996

| លេខ | វិក័យប័ត្រ | | | | | | ការទិញ | | | | | សរុបថ្លៃទិញរួមទាំងអាករ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថ្ងៃ.ខែ.ឆ្នាំ | លេខវិក័យប័ត្រ | អ្នកផ្គត់ផ្គង់ | លេខអត្តសញ្ញាណកម្មសារពើពន្ធ | បរិយាយ | ពន្ធកាត់ទុក | ការទិញមិនជាប់អាករ ឬការទិញគ្មាន | ការទិញជាប់អាករ: ការនាំចូលបនុករដ្ឋ តំលៃជាប់អាករ | អាករ | ការទិញក្នុងស្រុក តំលៃជាប់អាករ | អាករ | |
| | P1 | P2 | P3 | P4 | P5 | P6 | P7 | P9 | P10 | P11 | P12 | P13 |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | TOTAL | $ 487.23 | $ 33,032.29 | $ - | $ - | $ 340.00 | $ 34.00 | $ 33,406.29 |
| | | | | | | | R 131,997,038 | | | R 1,358,640 | R 135,864 | R 133,491,542 |

(សៀវភៅទិន្នានុប្បវត្តិទិញក្នុងMicrosoft Excel)

រាល់ចំណាយប្រចាំខែដែលអាចប្រកាសពន្ធ និងទទួលស្គាល់ពីរដ្ឋបាលពន្ធដារ ត្រូវបានកត់ត្រាចូលក្នុងសៀវភៅនិទ្ទានុប្បវត្តិលក់នេះ។ ក្រោយពីបានប្រមូល ពិនិត្យ និងដកចេញនូវចំណាយ ឬវិក័យប័ត្រមិនសមស្របណាដែលរដ្ឋបាលសារពើពន្ធមិនទទួលស្គាល់ចេញ គណនេយ្យករដែលទទួលបន្ទុកនឹងធ្វើការកត់ត្រាចូលនៅចំណាយជាប់អាករ ចំនាយមិនជាប់អាករ ឬចំណាយមិនអនុញ្ញាតឥណទាន ព្រមទាំងបង្ហាញពីពន្ធកាត់ទុក និងអាករលើតម្លៃបន្ថែមផងដែរ។ខាងក្រោមនេះនឹងបង្ហាញពីចំណុចនីមួយៗក្នុងតារាងសៀវភៅទិន្នានុប្បវត្តិទិញ៖

- លេខ : សម្រាប់ចុះលេខចំណាយដែលក្រុមហ៊ុនខេមវីលគ្លូបិលបានចុះសម្រាប់សម្គាល់ចំណាយនីមួយៗ
- ថ្ងៃខែឆ្នាំ : ជាកាលបរិច្ឆេទដែលចុះក្នុងវិក័យប័ត្រចំណាយនោះ
- លេខវិក័យបត្រ : ចុះលេខវិក័យបត្រទាំងនោះចូលចំណុចនេះ
- អ្នកផ្គត់ផ្គង់ : សំដៅដល់ឈ្មោះអ្នកលក់ ឃីហោហាងឬតូប ក្រុមហ៊ុនដែលផ្គត់ផ្គង់ទំនិញ ឬសេវាមកកាន់ក្រុមហ៊ុនខេមវីលគ្លូបិល
- លេខអត្តសញ្ញាណកម្មសារពើពន្ធ : សម្រាប់ចុះលេខ VAT TIN ក្រុមហ៊ុនជាប់ពន្ធដែលផ្គត់ផ្គង់ទំនិញ ឬសេវាមកកាន់ក្រុមហ៊ុនខេមវីលគ្លូបិល។ ឧទាហរណ៍៖ ក្រុមហ៊ុនសន្តិសុខ

- បរិយាយ : គឺជាការរៀបរាប់មុខទំនិញ ដែលបានទិញ ឬទទួលបានការផ្តល់សេវាក្នុងវិក័យប័ត្រ។
- ចំណាយមិនជាប់អាករ ឬចំនាយមិនអនុញ្ញាតឥណទាន: កត់ត្រាចំនាយដែលជាប់ពន្ធកាត់ទុក និងចំណាយ ដែលមិនជាប់អាករលើតម្លៃបន្ថែម ឬអាករផ្សេងទៀត។ បញ្ជាក់បន្ថែមសម្រាប់ប្រាក់បៀវត្សដែលបុគ្គលិកទទួលបានពិតប្រាកដក្រោយកាត់ពន្ធលើប្រាក់បៀវត្សក៏ត្រូវកត់ត្រាចូលក្នុងចំណុចនេះដែរ។
- ពន្ធកាត់ទុក: ជាចំនួនទឹកប្រាក់ពន្ធកាត់ទុកដែលគណនាចេញពីភាគរយនៃចំណាយមិនជាប់អាករ ឬចំណាយមិនអនុញ្ញាតឥណទានទៅតាមប្រភេទ និងអត្រាភាគរយនៃចំណាយជាប់ពន្ធកាត់ទុកនោះ។ ជាទូទៅក្រុមហ៊ុនខេមរីលគ្លូប៊ិល ជាប់ពន្ធកាត់ទុក ធំៗ៣ គឺ ការបង់ថ្លៃឈ្នួលចលន និងអចលនទ្រព្យ (១០%) ការបង់ការប្រាក់ឲ្យអ្នកជាប់ពន្ធមិនមែនជាធនាគារ ឬស្ថាប័នសញ្ជ័យធន (១៥%) និងការបំពេញសេវានានា (១៥%)។
- ការនាំចូល: ក្នុងចំណុចនេះក្រុមហ៊ុនមិនដែលមានការទិញដោយនាំចូលពីខាងក្រៅឡើយ ដូចនេះ មិនមានអ្វីកត់ត្រាក្នុងចំណុចនេះទេ។ ក្នុងករណីប្រសិនបើមាន នោះគណនេយ្យករអាចធ្វើការកត់ត្រាបែងចែកនូវចំណាយមុនជាប់អាករ និងចំនាយអាករលើចំនាយនោះ
- ការទិញក្នុងស្រុក: សំដៅដល់ចំណាយណាដែលក្រុមហ៊ុនបានទិញទំនិញ ឬសេវាពីបុគ្គលជាប់ពន្ធ និងមានវិក័យប័ត្រអាករ ហើយត្រូវតែជាចំណាយដែលគោរពលក្ខខណ្ឌចំណាយនៃការផ្គត់ផ្គង់ដែលជាប់អាករ ដូចបានចែងក្នុងមាត្រា ៦០ នៃច្បាប់សារពើពន្ធកម្ពុជា។ ក្នុងរង្វង់១០ខែគិតចាប់ពីខែ មិថុនា ឆ្នាំ២០១៦ ដល់ខែមីនា ឆ្នាំ២០១៧ ក្រុមហ៊ុនខេមរីល គ្លូប៊ិលនេះបានចំណាយលើការផ្គត់ផ្គងជាប់អាករ ដូចជា ចំណាយលើការប្រើប្រាស់អ៊ីនធើណេត ការចំណាយសេវាកម្មសន្តិសុខ ការចំណាយលើការដឹកជញ្ជូន.. ។ ក្រុមហ៊ុនក៏មានចំណាយលើការផ្គត់ផ្គង់មិនជាប់អាករដល់បុគ្គលជាប់អាករផងដែរ ដូចជាក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា អគ្គីសនីកម្ពុជា រដ្ឋាករទឹកស្វ័យតក្រុងភ្នំពេញ...។ សម្រាប់ការចំណាយទាំងនេះ ត្រូវបានកត់ត្រា ក្នុងចំណាយមិនជាប់អាករ ឬចំណាយមិនអនុញ្ញាតឥណទាន។
- សរុបថ្លៃទិញរួមទាំងអាករ: ជាការបូកបញ្ចូលរាល់ចំណាយទាំងអស់មិនថាចំណាយជាប់ ឬមិនជាប់អាករសរុប ដើម្បីបង្ហាញពីការចំណាយសរុបរបស់ក្រុមហ៊ុន។

❖ សៀវភៅទិន្នានុប្បវត្តិលក់ប្រចាំខែ

*រូបភាពទី៦៖ គំរូសៀវភៅទិន្នានុប្បវត្តិលក់*




(សៀវភៅទិន្នានុប្បវត្តិលក់ក្នុងMicrosoft Excel)

សម្រាប់បង្ហាញពីចំណូលដោយសង្ខេបនិងសរុបរបស់ក្រុមហ៊ុនខេមរីលគ្លូប៊ិល គណនេយ្យករបានរៀបចំតារាងមួយនេះដើម្បីបង្ហាញចំណូល និងអាករលើតម្លៃបន្ថែមប្រចាំខែប្រកាសពន្ធដែលបានពីអតិថិជនរបស់ខ្លួន។

- អត្រា : ត្រូវយកអត្រាជាមធ្យមប្រចាំខែដែលប្រកាសពន្ធតាមតារាងអត្រាប្តូរប្រាក់របស់ពន្ធដារ បានផ្សព្វផ្សាយរៀងរាល់ខែ។
- លេខវិក័យបត្រ : លេខវិក័យបត្រត្រូវតែរៀងគ្នា តាមលំដាប់លំដោយ
- អ្នកទិញ : រាយនាមករណ៍នៃបុគ្គល ឬក្រុមហ៊ុន ដែលក្រុមហ៊ុនបំពេញសេវាឲ្យមិនថាអតិថិជននោះ បានទូទាត់ ឬមិនទាន់បានទូទាត់ក៏ដោយ។ ដោយឡែកអតិថិជនរបស់ក្រុមហ៊ុនខេមរីលគ្លូប៊ិលសុទ្ធតែជាក្រុមហ៊ុនសហគ្រាស ក្នុងរយៈពេល១០ខែនេះ។
- លេខអត្តសញ្ញាណកម្មសារពើពន្ធ(VAT TIN) : របស់ក្រុមហ៊ុន សហគ្រាស ឬរោងចក្រដែលជាអតិថិជនក្រុមហ៊ុនខេមរីល គ្លូប៊ិល ហើយជាបុគ្គលជាប់ពន្ធ និងបានចុះបញ្ជីពន្ធដារ
- បរិយាយ : ជាការរៀបរាប់ពីទំនិញ ឬសេវាកម្ម ដែលក្រុមហ៊ុនជាទូទៅលក់ឲ្យអតិថិជនសម្រាប់ក្រុមហ៊ុនខេមរីលគ្លូប៊ិល ចាត់ទុកថាជា សេវាលើការដឹកជញ្ជូន និងរត់ឯកសារ។
- បរិមាណ និងការទិញមិនជាប់អាករ : ក្រុមហ៊ុនមិនមានបំពេញឡើយ។

- ការលក់ក្នុងស្រុក : គឺការទិញពីសំណាក់រូបវន្តបុគ្គលនៅក្នុងស្រុក ដែលក្រុមហ៊ុនក៏មិនទាន់មានអតិថិជនជារូបវន្តបុគ្គលនៅឡើយ។
- ការលក់ដោយបុគ្គលជាប់ពន្ធ(ក្រុមហ៊ុន) : ដោយបែងចែកជាពីរផ្នែកគឺការលក់តម្លៃជាប់អាករ និងអាករ
- សរុបថ្លៃទិញរួមអាករ : ជាចំនួនសរុបនៃការលក់ដែលជាប់អាករ បូកជាមួយតម្លៃអាករក្នុងមួយវិក័យបត្រ

នៅក្រោមនៃតារាង មានប្រអប់សម្រាប់៖

- សរុបការលក់(USD) : ទាំងតម្លៃជាប់អាករ អាករ និងការទិញរួមអាកររបស់វិក័យបត្រទាំងអស់
- សរុបការលក់(Riel) : ដោយយកសរុបការលក់(USD)នីមួយៗ គុណនឹងអត្រាប្តូរប្រាក់ខាងលើតារាង(N5)។
- ១%នៃប្រាក់ចំណូលមិនគិតបញ្ចូលអាករ: គណនាដោយយកសរុបការលក់សរុបការលក់(Riel) គុណនឹង១% ដែលជាប្រាក់រំដោះពន្ធលើប្រាក់ចំណេញ (PPT)

### ៣.២.៣ ការបំពេញលិខិតប្រកាសពន្ធ

ដំណាក់កាលបន្ទាប់ គឺការបំពេញលិខិតប្រកាសពន្ធដែលក្រុមហ៊ុនខេមវីលគ្លូបិលត្រូវបង់។ ជាបឋម គ្រប់លិខិតប្រកាសពន្ធប្រចាំខែ គឺត្រូវបំពេញពត៌មានក្រុមហ៊ុនជាមុនសិន ដូចលិខិតប្រកាសពន្ធប្រចាំខែក្រុមហ៊ុនខេមវីល គ្លូបិលជាឧទាហរណ៍ជាដើម។

*រូបភាពទី៧៖ ព័ត៌មានសហគ្រាសក្នុងលិខិតប្រកាសប្រចាំខែ*

| 02 | Period covered by this return | 01 | TIN |
|---|---|---|---|
| From (DD) 01 Month (MM) 03 Year (YYYY) 2017 | From (DD) 31 Month (MM) 03 Year (YYYY) 2017 | | 9 0 1 6 3 7 1 9 0 |

| 03 | | | |
|---|---|---|---|
| Name of Enterprise | ក្រុមហ៊ុន ខេមវីល គ្លូបិល ខូអិលធីឌី | | |
| Business Activities | [illegible] | | |
| Address: No | 2J | Street | 1980 |
| Group | | Village | |
| Sangkat | ភ្នំពេញថ្មី | District | សែនសុខ |
| Municipality | ភ្នំពេញ | | |
| Fax/Phone | 023 231 726 | E-mail | info@camwillglobal.com |

(លិខិតប្រកាសប្រចាំខែមីនា ២០១៧)

ជារៀងរាល់ខែ ក្រុមហ៊ុនខេមវីលគ្លូបិលយកព័ត៌មាន និងចំនួនដែលបានរៀបចំ និងគណនាពីក្នុងMicrosoft Excel បំពេញលិខិតប្រកាសពន្ធចំនួន ៤ដូចខាងក្រោម៖

❖ លិខិតប្រកាសពន្ធប្រាក់រំដោះលើប្រាក់ចំណេញ

នៅក្នុងលិខិតប្រកាសនេះ មានរួមបញ្ចូលប្រាក់រំដោះពន្ធលើប្រាក់ចំណេញ អាករពិសេស អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ និងពន្ធដទៃទៀត។ សម្រាប់ក្រុមខេមរីលគ្លូប៊ិល ដែលជាក្រុមហ៊ុនរកកម្រៃជើងសារលើការដឹកជញ្ជូន ជាប់កាតព្វកិច្ចបង់ពន្ធតែប្រាក់រំដោះពន្ធលើប្រាក់ចំណេញប៉ុណ្ណោះ។

នៅក្នុងលិខិតប្រកាស ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ស្ថិតនៅចំណុចទី I។ ក្រុមហ៊ុនខេមរីល គ្លូប៊ិល តែងតែបង់ប្រាក់ពន្ធរំដោះលើប្រាក់ចំណូលសរុបទាំងអស់សម្រាប់ខែដែលប្រកាសតែម្តង ដូចនេះក្នុងប្រអប់ លេខ៤ និង៧ ឥណទានយោងពីខែមុន បំពេញថាគ្មាន។ ប្រអប់លេខ៥ មូលដ្ឋានគិតប្រាក់រំដោះក្នុងខែ តួលេខទឹកប្រាក់ដែល ត្រូវយកមកបំពេញ គឺយកចេញពីសៀវភៅទិន្នានុប្បវត្តិលក់ប្រចាំខែ ដោយយកចំណូល ដែលរកបានសរុបមិនរួមបញ្ចូលអាករមកបំពេញ។ ប្រអប់លេខ ០៦ ប្រាក់រំដោះក្នុងខែ (អត្រា ១%) ក៏យកចេញពីសៀវភៅទិន្នានុប្បវត្តិលក់ប្រចាំខែ ចំណុច១%នៃប្រាក់ចំណូលមិនគិតបញ្ចូលអាករ ដែលបានគណនារួចរាល់ មកបំពេញតែម្តង។ ដោយមិនបានយោងឥណទានទៅមុខ និងគ្មានជាប់អាករអ្វីទៀត គណនេយ្យករគ្រាន់តែយកតួលេខពីប្រអប់ ០៦ ទៅបំពេញប្រអប់លេខ០៨ និងប្រអប់លេខ ១៩ ជាការស្រេច។

*រូបភាពទី៨៖ បំពេញលិខិតប្រកាសពន្ធរំដោះលើប្រាក់ចំណេញ*

Notes : Boxes from 08 to 16 are for the relevant enterprises subject to those taxes. Please fill "Nil" if there is no figure to be filled.

| | | | | | |
|---|---|---|---|---|---|
| **I. Prepayment of Profit Tax** | | | 04 | Credit from Last Month | 0 |
| 05 | Prepayment Calculated Base for the Month | 415,428,156 R | 06 | Prepayment for the Month (Rate: 1%) | 4,154,282 R |
| 07 | Credit Carried Forwards | 0 | 08 | Prepayment of Profit Tax Due | 0 |
| **II. Specific Tax on Certain Merchandises and Services** | | | | | |
| 09 | Specific Tax Calculation Base | | 10 | Specific Tax Due at the rate of % | |
| 11 | Specific Tax Calculation Base | | 12 | Specific Tax Due at the rate of % | |
| **III. Accommodation Tax** | | | | | |
| 13 | Accommodation Tax Calculation Base | | 14 | Accom. Tax Due (Rate: 2%) | |
| **IV. Public Lighting Tax** | | | | | |
| 15 | Public Lighting Tax Calculation Base | | 16 | Public Lighting Tax Due (Rate 3%) | |
| **V. Other Taxes** ( Specify ) * | | | | | |
| 17 | Tax Calculation Base | | 18 | Tax Due at the rate of % | |
| | | ( [08] + [10] + [12] + [14] + [16] + [18] ) | 19 | Total Tax Due | 4,154,282 R |

(លិខិតប្រកាសប្រាក់រំដោះពន្ធលើប្រាក់ចំណេញខែមីនា២០១៧)

ផ្នែកបន្ទាប់ដែលត្រូវបំពេញទៀតនោះ នៅទំព័រទី២ ផ្នែកការផ្គត់ផ្គង់សេវា បំពេញតួលេខថ្លៃសរុបមិនរួមបញ្ចូលពន្ធអាករ ឲ្យដូចតួលេខដែលបំពេញក្នុងប្រអប់ ០៥ និងបំពេញលេខវិក័យបត្រពីលេខ INV17-000XX to 000XX ពីក្នុងសៀវភៅទិន្នានុប្បវត្តិលក់ប្រចាំខែ។ ចុងក្រោយបំពេញទីកន្លែង និងកាលបរិច្ឆេទ ហើយរៀបចំលិខិតប្រកាស ដោយមានចុះហត្ថលេខាពីកម្មសិទ្ធករ ក្រុមហ៊ុនខេមរីល គ្លូប៊ិលជាការស្រេច។

*រូបភាពទី៩៖បំពេញលិខិតប្រកាសប្រាក់រំដោះលើប្រាក់ចំណេញផ្នែកខាងក្រោយ*

| ការផ្គត់ផ្គង់សេវា Supply of Services | | | | | |
|---|---|---|---|---|---|
| លរ Nº | បរិយាយមុខសេវា Description of Services | បរិមាណ Quantity | មូលដ្ឋានសម្រាប់គិតអាករពិសេស Base for Specific Tax | ថ្លៃសរុបមិនរួមបញ្ចូលពន្ធអាករ Total Amount Excluding Tax | វិក្កយបត្រពីលេខដល់លេខ Invoice from Nº to Nº |
| | សេវាកែប្រែជើងសារលើការដឹកជញ្ជូនទំនិញ | | | 415,428,156 R | INV17-00175-288 |
| | សរុប Total | | | 415,428,156 R | |

(លិខិតប្រកាសប្រាក់រំដោះពន្ធលើប្រាក់ចំណេញខែមីនា២០១៧, ផ្នែកខាងក្រោយ)

❖ លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស

បន្ទាប់ពីបានបំពេញព័ត៌មានក្រុមហ៊ុនរួចរាល់ហើយ ផ្នែកបន្ទាប់ដែលក្រុមហ៊ុនត្រូវប្រកាស និងបំពេញនោះគឺផ្នែក I. ពន្ធលើប្រាក់បៀវត្សចំពោះនិយោជិតជានិវាសនជនដូចបានរៀបរាប់នៅចំណុចតារាងលម្អិតពន្ធលើប្រាក់បៀវត្សចំពោះនិយោជិករួចហើយ។ ជាក់ស្តែងតារាងក្នុងផ្នែកនេះ គណនេយ្យករក្រុមហ៊ុនខេមរីល គ្លូប៊ិលបានរៀបចំរួចរាល់ដូចគ្នានឹងតារាងផ្នែកនេះ ដូច្នេះ គណនេយ្យករគ្រាន់តែយកតួលេខដែលបានគណនាមកបំពេញជាការស្រេច និងបំពេញទីកន្លែង និងកាលបរិច្ឆេទរៀបចំលិខិត ដោយមានចុះហត្ថលេខាពីកម្មសិទ្ធករក្រុមហ៊ុនខេមរីល គ្លូប៊ិល។ ចំណែកឯ តារាងនៅទំព័របន្ទាប់ មិនបាច់បំពេញអ្វីទាំងអស់ ព្រោះក្រុមហ៊ុនមានឯកសារតារាង

លម្អិតពន្ធលើប្រាក់បៀវត្សចំពោះនិយោជិកសម្រាប់ភ្ជាប់រួចហើយ។

*រូបភាពទី១០៖ បំពេញលិខិតប្រកាសពន្ធលើប្រាក់បៀវត្ស*

I. Tax on Salary on Resident Employees

| 04 | No. of Employee | Salary to be Paid | Spouse | No. of M Children | Tax on Salary Calculation Base | Tax Rate | Tax on Salary |
|---|---|---|---|---|---|---|---|
| | A | B | C | D | E = B – [(C + D) x 150,000] | F | G |
| 1 | 31 | 24,693,270 | 18 | 19 | 19,143,270 | 0% | 0 |
| 2 | 7 | 8,649,620 | 1 | 0 | 8,499,620 | 5% | 144,981 |
| 3 | 8 | 34,678,200 | 4 | 10 | 32,578,200 | 10% | 2,437,820 |
| 4 | | | | | | 15% | |
| 5 | | | | | | 20% | |
| សរុប Total | 46 | 68,021,090 | 23 | 29 | 60,221,090 | | 2,582,801 |

(លិខិតប្រកាសពន្ធលើប្រាក់បៀវត្សខែមីនា ២០១៧)

❖ លិខិតប្រកាសអាករលើតម្លៃបន្ថែម

ជាលិខិតប្រកាសពន្ធប្រចាំខែ ដែលមានលក្ខណ:ស្មុគ្រស្មាញបន្តិចក្នុងការបំពេញ។ បន្ទាប់ពី ការបំពេញព័ត៌មានក្រុមហ៊ុន ក្រឡេកមើលប្រអប់ ០៤ គឺមិនបំពេញអ្វីឡើយ ដោយសារប្រអប់នេះ ត្រូវបំពេញថាគ្មាន សម្រាប់តែក្រុមហ៊ុនដែលគ្មានប្រតិបត្តិការទិញលក់ប៉ុណ្ណោះ។ បំពេញពាក្យ គ្មាន ក្នុងប្រអប់លេខ០៥ ដោយសារក្រុមហ៊ុនគ្មានឥណទានអាករលើធាតុចូលពីខែមុនទេ។ ចំណុចដែល គណនេយ្យករក្រុមហ៊ុនខេមរីល គ្លូបិលយកចិត្តទុកដាក់បំពេញនោះ គឺការទិញទំនិញ ឬសេវាក្នុងខែ(ធាតុចូល) និង ការលក់ទំនិញ ឬសេវាកម្ម ឬការនាំចេញក្នុងខែ (ធាតុចេញ)។ សម្រាប់ធាតុចូល(Input) ចាប់ផ្ដើមបំពេញពីប្រអប់ ០៦(ការទិញមិនជាប់អាករ ឬការទិញមិនអនុញ្ញាតឥណទាន បំពេញតួលេខសរុបនៃចំនាយមិនជាប់អាករ ឬចំនាយមិនអនុញ្ញាតឥណទាន ពីសៀវភៅទិន្នានុប្បវត្តិទិញប្រចាំខែ។ ប្រអប់ ០៧ ការទិញក្នុងស្រុក បំពេញចំនួនសរុបនៃការទិញក្នុងស្រុក និងប្រអប់ ០៨ បំពេញចំនួនសរុបអាករ ដែលយកចេញពីក្នុង សៀវភៅទិន្នានុប្បវត្តិទិញប្រចាំខែ។ សម្រាប់ប្រអប់ ៩ និង១០ បំពេញពាក្យ គ្មាន ដោយសារក្រុមហ៊ុនមិនបាននាំចូលទំនិញ ឬសេវាពីក្រៅប្រទេសឡើយ។ ដូចនេះប្រអប់ ១១ បំពេញតួលេខដូចប្រអប់ ០៨។ ចំពោះធាតុចេញ(Output) ប្រអប់ដែលបំពេញតួលេខ គឺ ១៤ និង១៥ បំពេញពាក្យថា គ្មាន ព្រោះក្រុមហ៊ុនខេមរីល គ្លូបិលមិនមានការលក់មិនជាប់អាករ និងការលក់នាំចេញឡើយ។ ជាហេតុធ្វើឲ្យ ក្រុមហ៊ុនមានតែការលក់តាមអត្រាធម្មតា ១០% នៃការផ្គត់ផ្គង់សេវាក្នុងស្រុក ដែលត្រូវបំពេញប្រអប់ ១៤ បំពេញចំនួនសរុបតម្លៃជាប់អាករ ហើយប្រអប់ ១៥ នូវទឹកប្រាក់សរុបអាករ (១០% នៃសរុបតម្លៃជាប់អាករ ឬសរុបការលក់(Riel) ដែលយកមកពីសៀវភៅទិន្នានុប្បវត្តិលក់ប្រចាំខែ។

នៅក្នុងប្រអប់ ១៦ គឺជាផលដកនៃប្រអប់ ១៦ និង១១ (Output-Input) ជាការកាត់កងគ្នារបស់អាករលើតម្លៃបន្ថែម និងជាទឹកប្រាក់ដែលក្រុមហ៊ុនខេមរីល គ្លូប៊ិលត្រូវបង់ទៅពន្ធដារ។

*រូបភាពទី១១៖ បំពេញលិខិតប្រកាសអាករលើតម្លៃបន្ថែម*



If you have made no purchases and no sales, fill " NIL " in this box — 04

If you have no entry for a box, fill " NIL ". Do not leave any box blank unless you fill " NIL " in box 04.

| | | | | |
|---|---|---|---|---|
| Input tax credit from previous month | | | 05 | |
| Month's purchases of goods and services ( Input) — Value exclusive of VAT | | | | |
| Non-taxable or non-creditable purchases | 06 | R 131,997,038 | | |
| 10% Standard rated local purchases | 07 | R 1,358,640 | 08 | R 135,864 |
| 10% Standard rated imports | 09 | គ្មាន | 10 | គ្មាន |
| Total amount of input tax ( 05+08+10 ) | | | 11 | R 135,864 |
| Month's sales of goods and services or exports ( Output ) — Value exclusive of VAT | | | | |
| Non-taxable sales | 12 | គ្មាន | | |
| 0% Exports | 13 | គ្មាន | | |
| 10% Standard rated sales | 14 | 415,428,156 R | 15 | 41,542,816 R |
| If box 15 exceeds box 11, pay the difference | | | 16 | R 41,406,952 |
| If box 11 exceeds box 15, claim the difference for : | | | | |
| Refund | 17 | | | |
| Credit carried forward | | | 18 | |

(លិខិតប្រកាសអាករលើតម្លៃបន្ថែមខែមីនា ២០១៧)

❖ លិខិតប្រកាសពន្ធកាត់ទុក

ការចាប់ផ្តើមបំពេញដំបូងរបស់លិខិតប្រកាសពន្ធកាត់ទុក គឺដូចការបំពេញលិខិតប្រកាសប្រចាំខែដែរ មុននឹងឈានដល់ការបំពេញការប្រកាសពន្ធកាត់ទុក។ ក្រោយពីត្រួតពិនិត្យចំនាយក្នុងទិន្នានុប្បវត្តិទិញដែលជាកម្មវត្ថុជាប់ពន្ធកាត់ទុក និងបង់ទៅឲ្យបុគ្គលជានិវាសនជន ឬអនិវាសនជន រួចមក ឃើញថាការចំនាយទាំងនោះមិនមានបង់ទៅអនិវាសនជនឡើយ គឺបង់ឲ្យតែនិវាសនជនប៉ុណ្ណោះ ដូច្នេះប្រអប់ក្នុងចំណុចលេខ ៥ រក្សាទុកនៅទំនេរ ឬបំពេញថាគ្មាន។ ចំណុចដែលគណនេយ្យករ ផ្តោតលើគឺចំណុច ៤ ដែលត្រូវបំពេញតួលេខចូល។ រាល់ការចំនាយរបស់ក្នុងកំលុង១០ខែនោះ ក្រុមហ៊ុនខេមរីល គ្លូប៊ិលជាប់ពន្ធកាត់ទុកតែលើការចំនាយលើសេវានានាការបង់ការប្រាក់ឲ្យបុគ្គល ដែលមិនមែនជាធនាគារ និងការបង់ថ្លៃឈ្នួលផ្ទះ និងដី។ ដូចនេះចំណុច ៤ ដែលគណនេយ្យករក្រុមហ៊ុនខេមរីល គ្លូប៊ិល បំពេញ គឺប្រអប់លេខ ១ (ការចំនាយលើសេវានានា សួយសារចំពោះទ្រព្យអរូបី និងភាគកម្មក្នុងធនធានរ៉ែ) ប្រអប់លេខ ២(ការបង់ការប្រាក់ឲ្យទៅអ្នកជាប់ពន្ធមិនមែនជាធនាគារ ឬស្ថាប័នសញ្ជ័យធន) និងប្រអប់លេខ ៣ (ការបង់ថ្លៃឈ្នួលចលន និងអចលនទ្រព្យ) ដោយបំពេញ ចំនួនសរុបនៃចំនាយលើសេវានានា ចំនួនសរុប

នៃចំណាយការប្រាក់ និងចំនួនសរុបនៃចំណាយថ្លៃឈ្នួលដី និងផ្ទះ ព្រមទាំងទឹកប្រាក់ពន្ធកាត់ទុក ដែលគណនាតាមអត្រានៃចំណាយនោះទៅបំពេញក្នុងប្រអប់ពន្ធកាត់ទុករៀងគ្នាតាមកម្មវត្ថុដែល ក្រុមហ៊ុនជាប់ពន្ធកាត់ទុក រួចសរុបទឹកប្រាក់ត្រូវបើក និង សរុបពន្ធកាត់ទុក ដែលត្រូវបង់ទៅ រដ្ឋបាលពន្ធដារ។

*រូបភាពទី១២៖ បំពេញលិខិតប្រកាសពន្ធកាត់ទុក*

| 04 | កម្មវត្ថុនៃការទូទាត់ប្រាក់<br>Object of Payment | ទឹកប្រាក់ត្រូវបើក<br>Amount to be Paid | អត្រាពន្ធ<br>Tax Rate | ពន្ធកាត់ទុក<br>Withholding Tax | កំណត់សម្គាល់<br>Remarks |
|---|---|---|---|---|---|
| | A | B | C | D = B x C | |
| 1 | ការបំពេញសេវានានា សួយសារចំពោះទ្រព្យអរូបី ភាគកម្មក្នុងធនធានរ៉ែ<br>Performance of Services, Royalty for Intangibles, Interests in Minerals | R 2,341,656 | 15% | R 351,248 | |
| 2 | ការបង់ការប្រាក់ឱ្យទៅអ្នកជាប់ពន្ធមិនមែនជាធនាគារឬស្ថាប័នសន្សំប្រាក់<br>Payment of Interest to Non-Bank or Saving Institution Taxpayers | R 7,174,898 | 15% | R 1,076,235 | |
| 3 | ការបង់ការប្រាក់ឱ្យអ្នកជាប់ពន្ធដែលមានគណនីសន្សំមានកាលកំណត់ *<br>Payment of Interest to Taxpayers who have Fixed Term Deposit Accounts | | 6% | | |
| 4 | ការបង់ការប្រាក់ឱ្យអ្នកជាប់ពន្ធដែលមានគណនីសន្សំគ្មានកាលកំណត់ *<br>Payment of Interest to Taxpayers who have Non-Fixed Term Saving | | 4% | | |
| 5 | ការបង់ថ្លៃឈ្នួលចលនទ្រព្យនិងអចលនទ្រព្យ<br>Payment of Rental/Lease of Movable and Immovable Property | R 5,194,800 | 10% | R 519,480 | |
| | សរុប<br>Total | R 14,711,354 | | R 1,946,963 | |

(លិខិតប្រកាសពន្ធកាត់ទុកខែមីនា ២០១៧)

ទំព័របន្ទាប់ ក្រុមហ៊ុនខេមរីល គ្លូប៊ិលបានបំពេញតារាងលម្អិតអំពីពន្ធកាត់ទុកចំពោះអ្នកជាប់ពន្ធជានិវាសនជន។ តារាងនេះ ត្រូវរាយឈ្មោះចំណាយនីមួយៗដែលជាកម្មវត្ថុជាប់ពន្ធកាត់ទុក និងពន្ធកាត់ទុកនៃចំណាយនីមួយៗនោះ។ ឧទាហរណ៍៖ ការបង់ថ្លៃឈ្នួល គឺជាការសរុបបញ្ចូលគ្នារវាងចំណាយជួលផ្ទះ និងជួលដី ដែលចំណាយទាំងពីរនេះត្រូវបង្ហាញក្នុងតារាងលម្អិតនេះ។

*រូបភាពទី១៣៖ តារាងលម្អិតអំពីពន្ធកាត់ទុកនិវាសនជន*

តារាងលម្អិតអំពីពន្ធកាត់ទុកចំពោះអ្នកជាប់ពន្ធនិវាសនជន Details on the Withholding Tax on Resident Taxpayers

| ល.រ<br>No. | ឈ្មោះអ្នកទទួលប្រាក់<br>Name of Recipients | កម្មវត្ថុនៃការទូទាត់ប្រាក់<br>Object of Payment | លេខវិក្កយបត្រ<br>Invoice/Payment Note | ទឹកប្រាក់ត្រូវបើកមុនការកាត់ទុក<br>Amount Before Tax Withheld | អត្រាពន្ធ<br>Tax Rate | ពន្ធកាត់ទុក<br>Withholding Tax |
|---|---|---|---|---|---|---|
| A | B | C | D | E | F | G = E x F |
| | Kong Chanmalem | ជួលដី | PV-0217-002 | R 1,198,800 | 10% | R 119,880 |
| | Ms. Sokchan | ជួលទីតាំង | PV-0217-043 | R 3,996,000 | 10% | R 399,600 |
| | Ms. Sokchan | ការប្រាក់ | | R 7,174,898 | 15% | R 1,076,235 |
| | | សេវា | | R 2,341,656 | 15% | R 351,248 |

(លិខិតប្រកាសពន្ធកាត់ទុកខែមីនា ២០១៧)

### ៣.២.៤ ការបង់ប្រាក់នៅធនាគារ

ក្នុងការបង់ប្រាក់ពន្ធប្រចាំខែរបស់ក្រុមហ៊ុន ខេមរីល គ្លូប៊ិល គឺមិនដែលមានការយឺតយ៉ាវ ឬសុំយោងជាឥណទានទៅមុខឡើយ ដោយបង់ចំនួនទឹកប្រាក់បានត្រឹមត្រូវ និងទាន់ពេលវេលា។ រដ្ឋបាលពន្ធដារបានបង្ហាញដំណើរការដាក់លិខិតប្រកាសពន្ធ ដែលមានពីររបៀប ដោយក្រុមហ៊ុនខេមរីល គ្លូប៊ិលជ្រើសរើសរបៀបទីពីរ គឺក្រោយពីរៀបចំ និងបំពេញលិខិតប្រកាសពន្ធ ព្រមទាំងឯកសារភ្ជាប់រួចរាល់ គណនេយ្យករទទួលបន្ទុកមានភារៈស្រង់តួលេខពីលិខិតប្រកាសពន្ធទាំង

នោះ ក្នុងទម្រង់បង់ប្រាក់ពន្ធ P101 បំពេញតាមកុំព្យូទ័រ ដូចក្នុងឧបសម្ព័ន្ធទី៤។ ក្នុងទម្រង់នេះ គណនេយ្យករបំពេញខែដែលប្រកាស ហើយកាលបរិច្ឆេទត្រូវបំពេញកាលបរិច្ឆេទបង់ នៅធនាគារនោះតែម្តង។ បន្ទាប់មក √ លើសាខាពន្ធដារ និងបំពេញ "ខណ្ឌសែនសុខ" ដែលជាទីតាំងក្រុមហ៊ុនស្ថិតនៅ និងជាសាខាពន្ធដារដែលក្រុមហ៊ុនត្រូវបង់ពន្ធចូល និងដាក់លិខិតប្រកាសពន្ធ។ បន្ទាប់មក៖

- បំពេញឈ្មោះក្រុមហ៊ុនដូចមានក្នុងវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម គឺក្រុមហ៊ុន ខេមវីល គ្លូប៊ល ខូអិលធីឌី ទាំងជាភាសាខ្មែរ និងអក្សរឡាតាំង CAMWILL GLOBAL CO.,LTD ព្រមជាមួយនឹងលេខអត្តសញ្ញាណកម្មសារពើពន្ធគឺ K009-901637190
- ធ្វើការ √ ប្រភេទពន្ធ និង បំពេញលេខគណនី សាខាពន្ធដារខណ្ឌសែនសុខ (001000 2366318) ព្រមទាំងទឹកប្រាក់ពន្ធដែលក្រុមហ៊ុនត្រូវបង់ មានដូចជា៖

  ១០. ពន្ធលើប្រាក់បៀវត្ស

  ១២.ពន្ធប្រាក់រំដោះលើប្រាក់ចំណេញ

  ១៦.ពន្ធកាត់លើសេវាកម្ម ១៥%

  ១៧.ពន្ធកាត់ទុកលើការប្រាក់ ១៥%

  ២៤.ពន្ធកាត់ទុកលើថ្លៃឈ្នួល(រូបវន្តបុគ្គល)

  ២៦.អាករលើតម្លៃបន្ថែម
- រួចគណនេយ្យករទៅបង់ពន្ធនៅធនាគារ ដោយភ្ជាប់ជាមួយទម្រង់បង់ប្រាក់ពន្ធ ដូចមានក្នុងឧបសម្ព័ន្ធទី ៤ រួចចុះហត្ថលេខា ឈ្មោះ និងលេខទូរស័ព្ទ។

ជាទូទៅក្រុមហ៊ុនខេមវីល គ្លូប៊លទៅបង់ពន្ធនៅធនាគារអេស៊ីលីដា និងកាណាឌីយ៉ា។ បន្ទាប់ពីធ្វើការបង់ពន្ធ បុគ្គលិកធនាគារ នឹងឲ្យបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធចំនួនពីរសន្លឹកមកវិញជាការស្រេច។

### ៣.២.៥ ការដាក់លិខិតប្រកាសពន្ធទៅសាខាពន្ធដារ

លិខិតប្រកាសពន្ធ និងឯកសារភ្ជាប់ដែលបានរៀបចំ ត្រូវបានរៀបចំជាបីច្បាប់ដោយកិបភ្ជាប់បង្កាន់ដៃបង់ប្រាក់ពន្ធពីធនាគារ រួច បោះត្រាគ្រប់សន្លឹក នៃឯកសារភ្ជាប់ទាំងអស់ និងគ្រប់លិខិតប្រកាសពន្ធទាំងអស់ ត្រូវដាក់ឲ្យនាយកគ្រប់គ្រងទូទៅចុះហត្ថលេខា និងបោះត្រាក្រុមហ៊ុន បន្ទាប់មកយកលិខិតប្រកាសពន្ធប្រចាំខែ និងឯកសារភ្ជាប់ទាំងនោះទៅដាក់ នៅសាខាពន្ធដារ

ខណ្ឌសែនសុខ។ ក្រោយពីមន្ត្រីពន្ធដារខណ្ឌ ពិនិត្រសព្វគ្រប់មិនឃើញមានកំហុសឆ្គង ឬត្រូវការកែតម្រូវទេ មន្ត្រីពន្ធដារនឹងចុះហត្ថលេខាលើលិខិតប្រកាសរបស់ក្រុមហ៊ុនទាំងអស់ និងចេញលិខិតបញ្ជាក់ការទទួលលិខិតប្រកាសប្រចាំខែ បោះត្រាទទួលបានចំណូលលើឯកសារទាំងបីច្បាប់ និងប្រគល់ឯកសារប្រកាស មួយ ច្បាប់ត្រលប់មកឲ្យក្រុមហ៊ុនវិញដើម្បី ទុកតម្កល់ជាឯកសារវិញ។

សម្រាប់ការយកលិខិតប្រកាសពន្ធរដ្ឋបាលពន្ធដារ កាលពីឆ្នាំ ២០១៦ មិនមានភ្ជាប់លិខិតផ្ទេរសិទ្ធិសម្រាប់បុគ្គលដែលទទួលបន្ទុកទំនាក់ទំនងជាមួយមន្ត្រីពន្ធដារឡើយ ទោះជាមានមាត្រា ១០៦ ក្នុងចសពបានកំណត់ក៏ដោយ។ ដោយឡែកក្នុង២០១៧ គ្រប់សាខាពន្ធដារ ក៏ដូចជាសាខាពន្ធដារខណ្ឌសែនសុខ តម្រូវឲ្យគ្រប់ក្រុមហ៊ុនទាំងអស់រៀបចំលិខិតផ្ទេរសិទ្ធិដូចក្នុង ទើបអនុញ្ញាតឲ្យដាក់លិខិតប្រកាសពន្ធបាន។

ដូចបានបង្ហាញពីខាងលើ ឯកសារដាក់ទៅរដ្ឋបាលពន្ធដារត្រូវរៀបចំ៣ច្បាប់ តាមលំដាប់នៃការរៀបលិខិតប្រកាស និងឯកសារត្រូវរៀបចំដូចខាងក្រោម៖

- លិខិតប្រកាសប្រាក់រំដោះពន្ធលើប្រាក់ចំណេញ
- លិខិតប្រកាសអាករលើតម្លៃបន្ថែម
- ឯកសារសៀវភៅទិន្នានុប្បវត្តទិញ
- វិក័យបត្រអាកររបស់អ្នកផ្គត់ផ្គង់
- ឯកសារសៀវភៅទិន្នានុប្បវត្តលក់
- លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស
- ឯកសារតារាងលម្អិតពន្ធលើប្រាក់បៀវត្សចំពោះនិយោជិក
- លិខិតប្រកាសពន្ធកាត់ទុក។

## ៣.៣ ដំណើរការការប្រកាសពន្ធប្រចាំឆ្នាំ

ដំណើរការនៃការបង់ពន្ធប្រចាំឆ្នាំ នៅពេលយកទៅបង់នៅធនាគារ និងដាក់លិខិតប្រកាសនៅរដ្ឋបាលពន្ធដារ គឺមិនមានអ្វីខុសប្លែកគ្នាឡើយ។ ខុសប្លែកតែការរៀបចំឯកសារ និង ការបំពេញឯកសារ និងលិខិតប្រកាសប៉ុណ្ណោះ។ សម្រាប់ក្រុមហ៊ុនខេមរីលគ្លូប៊ល ពន្ធប្រចាំឆ្នាំដែលក្រុមហ៊ុនត្រូវបង់នោះមានពន្ធប៉ាតង់ និងពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

### ៣.៣.១ ពន្ធប៉ាតង់

ក្រុមហ៊ុនខេមរីល គ្លូប៊ិលបានចុះបញ្ជីពន្ធដារស្របតាមច្បាប់សារពើពន្ធ នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៦ ក្នុងនាមជាអ្នកជាប់ពន្ធមធ្យម ដែលមានលេខអត្តសញ្ញាណកម្មសារពើពន្ធ (TIN): K009-901637190។ ពន្ធប៉ាតង់របស់ក្រុមហ៊ុនខេមរីល គ្លូប៊ិលទើបតែបង់ពន្ធប៉ាតង់បាន ពីរឆ្នាំគឺ ឆ្នាំចុះបញ្ជីពន្ធដារ(២០១៦) និងឆ្នាំបន្ទាប់(២០១៧)។

❖ ឆ្នាំចុះបញ្ជីពន្ធដារ (២០១៦)

ឆ្នាំ២០១៦ ជាឆ្នាំដែលក្រុមហ៊ុនខេមរីលបានបង្កើតឡើង និងបានចុះបញ្ជីពន្ធដារ។ ពន្ធប៉ាតង់ជាពន្ធប្រចាំឆ្នាំដែលតម្រូវឲ្យបង់នៅដើមឆ្នាំ ឬនៅពេលចុះបញ្ជីពន្ធដារដំបូងតែម្តង។ ករណីក្រុមហ៊ុនខេមរីល គ្លូប៊ិល ចុះបញ្ជីពន្ធដារនៅ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ ដែលស្ថិតនៅក្នុងរយៈពេល ៦ខែដំបូង នៃឆ្នាំ២០១៦ ដូចនេះ ក្រុមហ៊ុនខេមរីល គ្លូប៊ិលត្រូវបង់ពន្ធប៉ាតង់ក្នុងចំនួនទឹកប្រាក់ ១,២០០,០០០រៀល នៅពេលជាមួយគ្នានៃការសុំចុះបញ្ជីពន្ធដារនោះតែម្តង។ សម្រាប់ប័ណ្ណប៉ាតង់ ២០១៦ និងឯកសារដទៃទៀត មន្ត្រីពន្ធដារបានយកមកប្រគល់ជូន ក្រុមហ៊ុនខេមរីល គ្លូប៊ិលដល់ក្រុមហ៊ុនក្រោយការដាក់ពាក្យសុំចុះបញ្ជីពន្ធដាររួចមួយសប្តាហ៍។

❖ ឆ្នាំបន្ទាប់ (២០១៧)

សម្រាប់ការបង់ពន្ធប៉ាតង់ ២០១៧នេះ គឺមិនមានភាពស្មុគ្រស្មាញអ្វីច្រើនដូចឆ្នាំ ២០១៦ ទៀតនោះទេ ហើយក៏មិនចាំបាច់បំពេញលិខិតប្រកាសពន្ធប៉ាតង់ប្រចាំឆ្នាំទៀតដែរ គឺដោយសារតែក្រុមហ៊ុនខេមរីល គ្លូប៊ិលបានធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស តាមរបបស្វ័យប្រកាស តាម (ទម្រង់ ១០១) និងមានប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។ ដូចនេះការប្រកាសពន្ធប៉ាតង់ប្រចាំឆ្នាំ ២០១៧ គណនេយ្យករទទួលបន្ទុកប្រកាសពន្ធបានជ្រើសរើសយកការបំពេញទម្រង់បង់ពន្ធ P101 សម្រាប់ប្រចាំឆ្នាំតាមប្រព័ន្ធកុំព្យូទ័រ (ដាក់ដាច់ដោយឡែកពីទម្រង់បង់ពន្ធ P101 សម្រាប់ប្រចាំខែ ប្រសិនបើអ្នកទៅបង់នៅធនាគារក្នុងពេលតែមួយ) នូវព័ត៌មានតម្រូវមួយចំនួន និង គូស √ ក្នុងប្រអប់មុខ ពន្ធប៉ាតង់ ព្រមទាំងបំពេញទឹកប្រាក់ដែលត្រូវបង់ចំនួន ១,២០០,០០០រៀល និងលេខគណនីធនាគាររបស់សាខាពន្ធដារខណ្ឌសែនសុខ (០០១០០០២៣៦៨៣១) ហើយចុះហត្ថលេខា និងឈ្មោះអ្នកបំពេញ។

បន្ទាប់មក គណនេយ្យកររបស់ក្រុមហ៊ុនខេមរីល គ្លូប៊ិល ត្រូវយកទម្រង់នេះទៅបង់នៅធនាគារ (ជំរើសដែលល្អគួរទៅទីស្នាក់ការកណ្តាលរបស់ធនាគារ ព្រោះមានតែទីស្នាក់ការកណ្តាលទេទើបអាចព្រីនប៉ាតង់បាន ប៉ុន្តែត្រូវអស់កម្រៃ ៤,០០០រៀល សម្រាប់ការព្រីនម្តង ឬអាច

ទៅព្រីននៅរដ្ឋបាលសារពើពន្ធដោយមិនអស់កម្រៃក៏បាន)។ ពេលនោះធនាគារបានឲ្យបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធចំនួនពីរសន្លឹកដូចគ្នា (ពណ៌សសម្រាប់មន្ត្រីពន្ធដារ និងពណ៌ផ្កាឈូកសម្រាប់អ្នកជាប់ពន្ធ)។

ចុងក្រោយ គណនេយ្យករធ្វើការថតចម្លងប័ណ្ណប៉ាតង់ ២០១៧ កិបភ្ជាប់ជាមួយបង្កាន់ដៃពីធនាគារ រៀបចំចំនួន៣ច្បាប់យកទៅសាខាពន្ធដារខណ្ឌសែនសុខ។ នៅទីនោះ មន្ត្រីពន្ធដារធ្វើការពិនិត្យ ហើយចេញលិខិតបញ្ជាក់ការទទួលលិខិតប្រកាសពន្ធប៉ាតង់ប្រចាំឆ្នាំ ២០១៧កិបភ្ជាប់ពន្ធប៉ាតង់ និងបង្កាន់ដៃពីធនាគារត្រលប់មកវិញ ដើម្បីឲ្យក្រុមហ៊ុនទុកជាឯកសារ។

❖ បញ្ហាជួបប្រទះ

ជាមួយនឹងដំណើរការប្រកាសពន្ធប៉ាតង់ដោយរលូននេះ ក្រុមហ៊ុនខេមរីល គ្លូប៊ិលក៏ជួបប្រទះការរាំងស្ទះក្នុងការប្រើប្រាស់ប៉ាតង់២០១៧នេះផងដែរ គឺដោយសារតែកំហុសបច្ចេកទេសរបស់រដ្ឋបាលសារពើពន្ធ ដែលធ្វើឲ្យខុសសញ្ជាតិ របស់ម្ចាស់ក្រុមហ៊ុនខេមរីល គ្លូប៊ិល។ ជាដំណោះស្រាយ គណនេយ្យករបានទៅសាលាជាតិពន្ធដារ ជាន់ទី៦ដើម្បីធ្វើការជូនដំណឹង និងកែតម្រូវកំហុសនេះឡើងវិញ ហើយត្រូវទៅព្រីនប៉ាតង់ថ្មីដែលត្រឹមត្រូវ ព្រមទាំងប្រគល់ជូនទៅសាខាពន្ធដារខណ្ឌសែនសុខម្តងទៀត។

### ៣.៣.២ ពន្ធលើប្រាក់ចំណេញ

ក្រុមហ៊ុនខេមរីល គ្លូប៊ិលបានប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦ ដែលជាប់អត្រាពន្ធលើប្រាក់ចំណេញ ២០% ហើយជាឆ្នាំដំបូងដែលក្រុមហ៊ុនរៀបចំ និងបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំនេះ។ សម្រាប់ដំណើរការរៀបចំ និងបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦របស់ក្រុមហ៊ុនខេមរីល គ្លូប៊ិលមានដំណើរការបំពេញតាមលំនាំដូចខាងក្រោម៖

1. **ទំព័រទី១៖ ស្តីពីព័ត៌មានទូទៅរបស់សហគ្រាស៖** គណនេយ្យករបាន បំពេញប្រអប់នីមួយៗក្នុងទំព័រនេះ ដែលព័ត៌មានត្រូវបំពេញក្នុងទំព័រនេះគឺយកចេញពីវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុន ដែលចំណុចដែលគួរប្រុងប្រយត្ន័នោះគឺការបំពេញលេខអត្តសញ្ញាណកម្មសារពើពន្ធ ឈ្មោះក្រុមហ៊ុន សកម្មភាពអាជីវកម្មសំខាន់ៗ និងអាស័យដ្ឋានក្រុមហ៊ុន។ ដោយឡែកប្រអប់ "15: ពន្ធប្រាក់ចំណេញត្រូវបង់" ឬ "16: ឥណទានពន្ធ

យោងទៅមុខ" ត្រូវបំពេញក្រោយបង្អស់ នៅពេលដែលប្រាក់ចំណេញជាប់ពន្ធត្រូវបាន គណនា។

*រូបភាពទី១៩៖ បំពេញព័ត៌មានទូទៅរបស់សហគ្រាស*

| | | |
|---|---|---|
| Tax Period: Number of Month | 07 Months | From: DD 01 MM 06 YYYY 2016 — Until: DD 31 MM 12 YYYY 2017 |
| 1 | Tax Identification Number (TIN) | K 0 0 9 - 9 0 1 6 3 7 1 9 0 |
| 2 | Name of Enterprise | ក្រុមហ៊ុន ខេមរីល គ្លូបិល ខូអិលធីឌី |
| 3 | Date Registered with Tax Administration | 03 មិថុនា 2016 |
| 4 | Name of Director/Manager/Owner | នេន នីសារឿន |
| 5 | Main Business Activities | សេវាកម្មដើងសាលើការដឹកជញ្ជូនទំនិញ |
| 6 | Name of Accountant/Consultant/Accounting Firm | កាក់ វីរៈធារី |
| 7 | Current Registered Office Address | ផ្ទះលេខ ២៨ ផ្លូវ ១៩៨០ សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានី ភ្នំពេញ |
| 8 | Current Principal Establishment Address | ផ្ទះលេខ ២៨ ផ្លូវ ១៩៨០ សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានី ភ្នំពេញ |
| 9 | Current Raw Materials/Goods Warehouse Address | |
| 10 | Accounting Records | ☑ Using Accounting Software; ☐ Not Using Accounting Software |
| 11 | Statutory Audit Requirement | ☐ Required (Subject to submit audit report); ☑ Not Required |
| 12 | Legal Form or form of business operation | ☑ Private Limited Company; ☐ State Joint Venture; ☐ Sole Proprietorship; ☐ Public Limited Company; ☐ Foreign Company's Branch; ☐ General Partnership/Pass-though; ☐ Interest in Joint Venture; ☐ Representative Office; ☐ Limited Partnership; ☐ Public Enterprise; ☐ Non-Government Organization; ☐ Single Member Private Company Limited; ☐ State Enterprise; ☐ Others |
| 13 | Profit Tax Exemption | Year of First Revenue: 2016; Year of First Profit: គ្មាន; Priority Period: ... year |
| 14 | Profit Tax Rate | ☐ 30%; ☑ 20%; ☐ 5%; ☐ 0%; ☐ Progressive Rate by Tranches from 0% to 20% |
| 15 | Profit Tax Due | |
| 16 | Tax Credit Carried Forward | |

(លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦,ព័ត៌មានទូទៅរបស់សហគ្រាស)

2. **ទំព័រទី២៖ ស្តីពីព័ត៌មានទូទៅរបស់សហគ្រាស៖** ត្រូវបំពេញព័ត៌មាន អំពីការចូលរួមមូលធន និង ព័ត៌មានរបស់និយោជិកក្នុងសហគ្រាសនៅក្នុងការិយបរិច្ឆេទ ដែល តម្រូវ។ នៅក្នុងទំព័រនេះ គឺត្រូវបំពេញតារាង ២ (ទី ១៖ ការចូលរួមមូលធន និង ទី ២៖ ព័ត៌មានរបស់និយោជិកក្នុងសហគ្រាសនៅក្នុងការិយបរិច្ឆេទ)។

- **ការចូលរួមមូលធន**: សម្រាប់ដើមការិយបរិច្ឆេទ ការចូលរួមមូលធនរបស់ក្រុមហ៊ុន ខេមរីលគ្លូប៊ិល គណនេយ្យករបានយកទិន្នន័យពីក្នុងលក្ខន្តិកៈក្រុមហ៊ុន ដោយសារជាឆ្នាំដំបូងដែលក្រុមហ៊ុនប្រកាសពន្ធលើប្រាក់ចំណេញនេះ។ សម្រាប់ចុងការិយបរិច្ឆេទ តួលេខទិន្នន័យរក្សានៅដដែល ឬប្រែប្រួលគឺមើលទៅតាមតារាងតុល្យការចុងឆ្នាំរបស់ក្រុមហ៊ុន។ ដោយសរុបទឹកប្រាក់របស់ចុងការិយបរិច្ឆេទ ស្មើនឹង A29 "មូលធន/មូលធនភាគហ៊ុន"

- **ព័ត៌មានអំពីនិយោជិកសហគ្រាសនៅក្នុងការិយបរិច្ឆេទ**: បង្ហាញពីអ្នកគ្រប់គ្រងជាអ្នកចូលហ៊ុន អ្នកគ្រប់គ្រងមិនមែនជាអ្នកចូលហ៊ុន និងសរុបបុគ្គលិក កម្មករ និងបុគ្គលិកកម្មករជាប់ពន្ធលើប្រាក់បៀវត្ស

3. **ទំព័រទី៥ និង៦៖ របាយការណ៍លទ្ធផល៖**

*តារាងទី១០៖ របាយការណ៍លទ្ធផលប្រចាំឆ្នាំ (CWG)*

| របាយការណ៍លទ្ធផល | | |
|---|---|---|
| ចំណូលប្រតិបត្តិការ | B0 | 2,117,937,261 |
| ការផ្គត់ផ្គង់សេវា | B3 | 2,117,937,261 |
| ថ្លៃដើមសេវាបានផ្គត់ផ្គង់ | B5.1 | 1,843,953,853 |
| ចំណូលដុល | B6 | 273,983,408 |
| ចំណាយប្រតិបត្តិការ | B19 | 955,158,351 |
| ចំណាយបៀវត្ស | B20 | 273,983,408 |
| ចំណាយប្រេង ឧស្ម័ន អគ្គីសនី និងទឹក | B21 | 8,367,945 |
| ចំណាយធ្វើដំណើរ និងចំណាយស្នាក់នៅ | B22 | 14,950,301 |
| ចំណាយលើការជួល | B24 | 45,839,430 |
| ចំណាយលើការថែទាំ និងជួសជុល | B25 | 84,067,326 |
| ចំណាយកម្រៃជើងសារ | B27 | 21,509,433 |
| ចំណាយរំលស់ | B33 | 367,566,570 |
| ចំណាយផ្សេងៗ | B38 | 139,196,232 |
| ប្រាក់ខាតពីប្រតិបត្តិការ | B39 | (681,187,710) |
| ចំណាយការប្រាក់បង់ឲ្យនិវាសនជន | B40 | 36,664,451 |
| ប្រាក់ចំណេញមុនបង់ពន្ធ | B42 | (717,852,161) |
| ពន្ធលើប្រាក់ចំណេញ | B43 | 0 |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | B44 | (717,852,161) |

(លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦,របាយការណ៍លទ្ធផល)

- **ចំណូលប្រតិបត្តិការ៖** ការផ្គត់ផ្គង់សេវា ជាចំណូលដែលក្រុមហ៊ុនខេមរីលគ្លូប៊ិល រកបានពីសេវាដឹកជញ្ជូន កម្រៃជើងសាររត់ឯកសារគយ ការជួលកុងតេន័រ ចំណូលពីការចេញជូស និងចំណូលដទៃផ្សេងៗទៀតក្នុងរយៈពេល៧ខែដែលក្រុមហ៊ុនបានដំណើរការអាជីវកម្ម។
- **ចំណាយប្រតិបត្តិការ៖** ក្រុមហ៊ុនបានចំណាយទៅលើចំណាយប្រាក់បៀវត្សបុគ្គលិក ចំណាយប្រើប្រាស់អគ្គីសនី និងទឹក ចំណាយធ្វើដំណើរ និងស្នាក់នៅដើម្បីទំនាក់ទំនងជាមួយអតិថិជន ចំណាយលើការជួល (ដូចជាការជួលម៉ាស៊ីនកូពីជាដើម) ចំណាយលើការថែទាំ (សេវាថែទាំផ្នែកទន់របស់កុំព្យូទ័រ) និងចំណាយកម្រៃជើងសារ (សម្រាប់ការរកអតិថិជនមកឲ្យក្រុមហ៊ុន) ចំណាយរំលស់ទ្រព្យសកម្ម និងចំណាយផ្សេងៗទៀត)។
- **ប្រាក់ខាតពីប្រតិបត្តិការ៖** គឺអវិជ្ជមាន ដោយមូលហេតុ ចំណូលដែលក្រុមហ៊ុនរកបាននៅមានកម្រិតទាបនៅឡើយ ហើយការចំណាយគឺមានច្រើនដោយសារតែក្រុមហ៊ុនទើបតែដំណើរការត្រូវចំណាយចាយវាយច្រើន។ ហើយប្រាក់ចំណេញ/ខាតពីប្រតិបត្តិការនេះ គឺត្រូវយកទៅបំពេញក្នុងប្រអប់ A35 "ប្រាក់ចំណេញ/ខាតពីប្រតិបត្តិការនៃការិយបរិច្ឆេទនេះ"។
- **ចំណាយការប្រាក់៖** ក្រុមហ៊ុនបានខ្ចីពីតែពីបុគ្គលនិវាសនជនប៉ុណ្ណោះ។
- **ពន្ធលើប្រាក់ចំនេញ៖** ត្រូវបានចន្លោះចោលសិន ព្រោះត្រូវគណនានៅតារាងគណនាពន្ធលើប្រាក់ចំណេញសិន។
- **ប្រាក់ចំណេញក្រោយបង់ពន្ធ៖** ដោយក្រុមហ៊ុនខេមរីល គ្លូប៊ិលទទួលលទ្ធផលអវិជ្ជមាន(ប្រាក់ខាត)។

4. **ទំព័រទី ៣ និង៤៖ តារាងតុល្យការ៖**

តារាងតុល្យការក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ក្រុមហ៊ុនខេមរីលគ្លូប៊ិលបានទាញយកតារាងតុល្យការនៅក្នុង Quickbooks យកមករៀបចំ សម្រួលសារជាថ្មី ដើម្បីបំពេញតារាងនេះ។ តារាងតុល្យការមានពីរផ្នែកធំៗ គឺ ផ្នែកទ្រព្យសកម្ម (A0) និង ផ្នែកមូលនិធិ និងបំណុល (A27) ដែលចំនួនសរុបនៃផ្នែកទាំងពីរនេះដាច់ខាតត្រូវតែមានចំនួនស្មើគ្នា។

*តារាងទី១១៖ តារាងតុល្យការ (ផ្នែកទ្រព្យសកម្ម)*

| តារាងតុល្យការ (ផ្នែកទ្រព្យសកម្ម) | | |
|---|---|---|
| 1. ទ្រព្យសកម្ម | A0 | 1,822,597,907 |
| ទ្រព្យសកម្មរយៈពេលវែង | A1 | 1,249,225,347 |
| រោងចក្រ(ក្រៅពីអាគារ) និងបរិក្ខារ | A7 | 1,249,225,347 |
| ទ្រព្យសកម្មរយៈពេលខ្លី | A13 | 573,372,560 |
| គណនីត្រូវទទួល /អតិថិជន | A18 | 272,183,106 |
| ចំណាយបានកត់ត្រាមុន | A20 | 15,187,928 |
| សាច់ប្រាក់នៅក្នុងបេឡា និងធនាគារ | A21 | 220,351,032 |
| ទ្រព្យសកម្មរយៈពេលខ្លីដទៃទៀត | A25 | 65,650,494 |

(លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦, តារាងតុល្យការ)

នៅក្នុងផ្នែកទ្រព្យសកម្ម មានតែផ្នែកមួយចំនួននៅក្នុងតារាងប៉ុណ្ណោះដែលត្រូវបានបំពេញចូល ដែលមានការរាយរាប់បញ្ជាក់បន្ថែមនៅខាងក្រោមនេះ៖

- **ទ្រព្យសម្មរយៈពេលវែង៖** របស់ក្រុមហ៊ុនខេមរីល គ្លូបិល គឺបរិក្ខារ ដូចជាគ្រឿងបរិក្ខារការិយាល័យ រថយន្តដឹកជញ្ជូនទំនិញតូចធំ កុងធីន័រ ឡានស្ទូច....សម្រាប់បម្រើសកម្មភាពចំបងរបស់អាជីវកម្ម
- **ទ្រព្យសកម្មរយៈពេលខ្លី៖** មានដូចជា គណនីត្រូវទទួល/អតិថិជន(អតិថិជនជំពាក់ក្នុងការិយបរិច្ឆេទ) ចំណាយកត់ត្រាមុន សាច់ប្រាក់សរុបដែលមាននៅក្នុងបេឡា និងធនាគារ និងទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ(រួមមានប្រាក់បុគ្គលិកយកលុយមុនប្រាក់តម្កល់ប្រាក់នៅអគ្គនាយកដ្ឋានគយ ថ្លៃកក់ទូកុងតេន័រជាដើម...)។

*តារាងទី១២៖តារាងតុល្យការ (ផ្នែកមូលនិធិ/ទុនម្ចាស់ទ្រព្យ និងបំណុល)*

| តារាងតុល្យការ (ផ្នែកមូលនិធិ/ទុនម្ចាស់ទ្រព្យ និងបំណុល) | | |
|---|---|---|
| 2. មូលនិធិ/ទុនម្ចាស់ទ្រព្យ និងបំណុល | A27 | 1,822,597,907 |
| មូលនិធី/ទុនម្ចាស់ទ្រព្យ | A28 | 328,477,493 |
| មូលធន/មូលធនភាគហ៊ុន | A29 | 1,249,225,347 |
| លទ្ធផលខាតនៃការិយបរិច្ឆេទ | A35=B44 | 1,009,663,095 |

| | | |
|---|---|---|
| បំណុលរយៈពេលវែង | A36 | 1,236,165,000 |
| បំណុលភាគីជាប់ទាក់ទិន | A37 | 1,236,165,000 |
| បំណុលរយៈពេលខ្លី | A41 | 257,955,537 |
| គណនីត្រូវសងបុគ្គលជាប់ទាក់ទិន | A44 | 207,605,725 |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | A48 | 3,657,225 |
| ពន្ធអាករផ្សេងៗត្រូវបង់ | 49 | 46,692,587 |

(លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦, តារាងតុល្យការ)

- **មូលនិធិ/ទុនម្ចាស់ទ្រព្យ៖** ចំនួនសរុបនៃមូលធន/ មូលធនភាគហ៊ុននៅចុងការិយបរិច្ឆេទរបស់ម្ចាស់ភាគហ៊ុន ដែលមានឈ្មោះក្នុងលក្ខន្តិកៈក្រុមហ៊ុន ហើយចំនួននេះត្រូវស្មើនឹងចំនួនសរុបទឹកប្រាក់ចុងការិយបរិច្ឆេទនៃការចូលរួមធន។ចំណែកលទ្ធផលខាត នៃការិយបរិច្ឆេទនេះគឺត្រូវយកតម្លៃលេខ ពីតារាងរបាយការណ៍លទ្ធផល នៅជួរប្រអប់ B44 មកបំពេញក្នុងជួរប្រអប់ A35។
- **បំណុលរយៈពេលវែង៖** មានតែបំណុលបានខ្ចីពី អ្នកស្រី គាត សុខចាន់ដែលជាភាគីជាប់ទាក់ទិន
- **បំណុលរយៈពេលខ្លី៖** គណនីត្រូវសងបុគ្គលជាប់ទាក់ទិន(អ្នកផ្គត់ផ្គង់ប្រេង ជើងសាររត់ឯកសារ...); ពន្ធលើប្រាក់ចំណេញត្រូវបង់ (បានកត់ត្រាប្រាក់រំដោះលើប្រាក់ពន្ធលើប្រាក់ចំណេញខែធ្នូ ដែលជាក់ស្តែងចំណុចនេះត្រូវយក E53 ប្រាក់ពន្ធលើប្រាក់ចំណេញដែលត្រូវបំពេញចូល) និងពន្ធ អាករត្រូវបង់ផ្សេងៗ (រួមមាន VAT, WHT TOS, PPT ខែធ្នូ ឆ្នាំ២០១៦ដែលមិនទាន់បានបង់ជូនរដ្ឋ)។

5. **ទំព័រទី៨៖ ថ្លៃដើមទំនិញបានលក់៖** តារាងនេះ សម្រាប់គណនាថ្លៃដើមទំនិញ ឬសេវាបានចំពោះសហគ្រាសពាណិជ្ជកម្ម និងសេវាកម្ម ដូចក្រុមហ៊ុនខេមរីល គ្លូប៊ិលជាដើម។ ប៉ុន្តែតារាងនេះ ក្រុមហ៊ុនខេមរីល គ្លូប៊ិលមិនបានបំពេញនោះទេ។
6. **ទំព័រទី១៣៖ តារាងរំលស់តាមច្បាប់សារពើពន្ធ៖** នៅក្នុងតារាងនេះ ក្រុមហ៊ុនមានតែទ្រព្យរូបីថ្នាក់ដែលក្រុមហ៊ុនធ្វើរំលស់ ក្នុងករណីតម្លៃទ្រព្យនោះចាប់ពី ២លានរៀល ឡើងទៅ

មានដូចជា គ្រឿងបរិក្ខារ គ្រឿងសង្ហារឹម បរិក្ខារថយន្ត កុងតេន័រ និង ពិសេសរថយន្តដឹកជញ្ជូន ឡានស្ទូច... ទើបក្រុមហ៊ុនធ្វើការរំលស់។

*រូបភាពទី១៥៖ រំលស់ទ្រព្យរូបីថ្នាក់២ ដល់ថ្នាក់៤*

III រំលស់ទ្រព្យរូបីថ្នាក់ ២ ដល់ថ្នាក់ ៤ (រំលស់តាមវិធីសាស្ត្រថយចុះតាមសមតុល្យ)
Depreciation of Tangible Fixed Assets Class 2 - 4 (Declining Balance Method)

| ល.រ No. | [illegible] Fixed Assets | [illegible] Historical Cost | [illegible] Undepreciated Value at the Beginning of the Period | [illegible] Acquisitions, Transfers-in, Production or Construction During the Period | [illegible] Written-off or Disposal Value During the Period | [illegible] Depreciation Based Value During the Period | [illegible] Degree Rate | [illegible] Deprec. Allowance of the Period | [illegible] Undeprec. Value at the End of the Period (Net Book Value) |
|---|---|---|---|---|---|---|---|---|---|
| | | (1) | (2) | (3) | (4) | (5)=(2)+(3)-(4) | (6) | (7)=(5)*(6) | (8)=(5)-(7) |
| | ទ្រព្យថ្នាក់ ២ Class 2 | | | | | | 50% | | |
| | ទ្រព្យថ្នាក់ ៣ Class 3 | 1,470,267,010 | | | | 1,470,267,010 | 25% | 367,566,762 | 1,102,700,257 |
| | ទ្រព្យថ្នាក់ ៤ Class 4 | | | | | | 20% | | |
| | សរុបថ្នាក់ ២ ដល់ ៤ Total of Class 2 - 4 | 1,470,267,010 | | | | 1,470,267,010 | | 367,566,762 | 1,102,700,257 |
| | សរុបរួម Grand Total | 1,470,267,010 | | | | 1,470,267,010 | | 367,566,762 | 1,102,700,257 |

(លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦, តារាងរំលស់សារពើពន្ធ)

7. **ទំព័រទី១១៖ តារាងគណនាវិភាគទានសប្បុរសធម៌ ការប្រាក់អាចកាត់កងបាន និងឥណទានខាតយោងទៅមុខ៖**

**ក-ការគណនាវិភាគទានសប្បុរសធម៌**

ដោយសារក្រុមហ៊ុនខេមរីលគ្លូប៊ល មិនមានការចំណាយវិភាគទានសប្បុរសធម៌នៅក្នុងការិយបរិច្ឆេទនេះឡើយ ដូចនេះ តារាងនេះគណនេយ្យករមិនចាំបាច់បំពេញអ្វីឡើយ ដោយរក្សាទុកឲ្យនៅទំនេរ។ ដូចនេះ **តារាងគណនាពន្ធលើប្រាក់ចំណេញ៖** តួលេខបំពេញប្រអប់ "E36: ចំណាយវិភាគទានសប្បុរសធម៌មិនអាចកាត់កងបាន" ដែលបានតារាងគណនាវិភាគទានប្បុរសធម៌នេះស្មើសូន្យ និងគណនា "E37:ប្រាក់ចំណេញ(ខាត) មុននិយ័តកម្មលើការប្រាក់/"។

8. **ទំព័រទី១១៖ តារាងគណនាវិភាគទានសប្បុរសធម៌ ការប្រាក់អាចកាត់កងបាន និងឥណទានខាតយោងទៅមុខ៖**

**ខ-ការគណនាចំណាយការប្រាក់**

ក្រុមហ៊ុនខេមរីល គ្លូប៊ល មានចំណាយការប្រាក់ មិនមានចំណូលការប្រាក់ឡើយ។ ដោយចំណាយការប្រាក់អាចកាត់កង 0 នោះចំនួនដែលទឹកប្រាក់ ដែលត្រូវបូក/ដកចេញពីប្រាក់ចំណេញជាប់ពន្ធ ឬត្រូវយោងទៅមុខ នោះគឺស្មើសូន្យ ។

9. **ទំព័រទី១២៖ តារាងគណនាវិភាគទានសប្បុរសធម៌ ការប្រាក់អាចកាត់កងបាន និងឥណទានខាតយោងទៅមុខ៖**

**គ-តារាងតាមដានលទ្ធផលសារពើពន្ធខាតយោងទៅមុខ**

ឆ្នាំ២០១៦ជាឆ្នាំដំបូងដែលក្រុមហ៊ុនដំណើរការអាជីវកម្ម ហើយក្នុងឆ្នាំនេះ ក្រុមហ៊ុនខេមរីល គ្លូប៊ល ទទួលបានលទ្ធផលខាតសារពើពន្ធពីប្រអប់E39 ដែលក្រុមហ៊ុនមានសិទ្ធយោងលទ្ធផលខាតនេះទៅឆ្នាំបន្ទាប់ សម្រាប់ទុកកាត់កងជាមួយប្រាក់ចំណេញជាប់ពន្ធនៅឆ្នាំ២០១៧ និងឆ្នាំបន្ទាប់នៅក្នុងតារាងនេះ ដោយឡែកឆ្នាំនេះក្រុមហ៊ុនទទួលបានលទ្ធផលសារពើពន្ធខាត ហើយជាឆ្នាំដំបូង គណនេយ្យករបំពេញក្នុងប្រអប់ ឆ្នាំ N** ត្រង់លទ្ធផលខាតសារពើពន្ធក្នុងការិយបរិច្ឆេទមួយប៉ុណ្ណោះ ។

*រូបភាពទី១៦៖ តារាងតាមដានលទ្ធផលខាតយោងទៅមុខ*



[illegible] K 0 0 9 - 9 0 1 6 3 7 1 9 0

Table of Taxable Accumulated Losses Carried Forward

| [illegible] Period | [illegible] Taxable Profit During the Period (1) | [illegible] Taxable Loss During the Period (2) | [illegible] Loss Allowance During the Period (3) | [illegible] Accumulated Losses Allowance (4)* | [illegible] Losses Carried Forward (5)=(2)-(3)-(4) |
|---|---|---|---|---|---|
| ឆ្នាំ N-5 Year N-5 | | | | | |
| ឆ្នាំ N-4 Year N-4 | | | | | |
| ឆ្នាំ N-3 Year N-3 | | | | | |
| ឆ្នាំ N-2 Year N-2 | | | | | |
| ឆ្នាំ N-1 Year N-1 | | | | | |
| ឆ្នាំ N** Year N** | | 819,857,982 | - | - | - |

(លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦,តារាងតាមដានលទ្ធផលខាតយោងទៅមុខ)

### 10. **ទំព័រទី១០៖ តារាងគណនាពន្ធលើប្រាក់ចំណេញ៖**

*តារាងទី១៣៖ តារាងគណនាពន្ធលើប្រាក់ចំណេញ (CWG)*

| | តារាងគណនាពន្ធលើប្រាក់ចំណេញ | | |
|---|---|---|---|
| | **ប្រាក់ចំណេញមុនបង់ពន្ធ** | E1=B42 | (717,852,161) |
| បូក | ចំណាយមិនអាចកាត់កងបាន | | |
| | ចំណាយរំលស់គណនេយ្យ | E2 | 221,021,663 |
| | លាភការរបស់អាជីវករ និងគ្រួសារ | E13 | 44,519,868 |
| | សរុប | E17 | 265,561,531 |
| | ចំណូលជាប់ពន្ធតែមិនត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ | | 0 |
| ដក | ចំណាយមិនកត់ត្រាក្នុងបញ្ជីគណនេយ្យអាចកាត់កងក្នុងឆ្នាំ | | |
| | រំលស់អនុញ្ញាតតាមច្បាប់សារពើពន្ធ | E25 | 367,566,752 |

| | | | |
|---|---|---|---|
| | សរុប | E30 | 367,566,752 |
| ដក | ចំណូលកត់ត្រាក្នុងបញ្ជីគណនេយ្យតែមិនត្រូវជាប់ពន្ធក្នុងឆ្នាំ | | 0 |
| | **ប្រាក់ខាតក្រោយនិយ័តកម្ម** | E35 | (819,857,382) |
| បូក | ចំណាយសប្បុរសធម៌ដែលមិនឲ្យកាត់កង | E36 | 0 |
| | **ប្រាក់ខាតមុននិយ័តកម្មលើការប្រាក់** | E37 | (819,857,382) |
| +/- | និយ័តកម្មលើការប្រាក់ | E38 | 0 |
| | **ប្រាក់ខាតក្នុងការិយបរិច្ឆេទ** | E39 | (819,857,382) |
| ដក | ខាតយោងពីឆ្នាំមុនអនុញ្ញាត | E40 | 0 |
| | **ប្រាក់ខាតជាប់ពន្ធសម្រាប់គណនាពន្ធលើប្រាក់ចំណេញ** | E41 | (819,857,382) |
| | ពន្ធលើប្រាក់ចំណេញតាមអត្រា ២០% | E42 | (163,971,476) |
| | **បំណុលពន្ធលើប្រាក់ចំណេញ E46>0 នាំឲ្យE46=0** | E46 | 0 |
| | ***ពន្ធអប្បបរមា ១%នៃ B0*** | E47 | 21,180,978 |
| | **បំណុលពន្ធលើប្រាក់ចំណេញត្រូវបង់** | | |
| | សម្រាប់ក្រុមហ៊ុនខេមរីល គ្លូបិល(Non-QIP) | E50 | 21,180,978 |
| ដក | ឥណទានពន្ធកាត់ទុកបានបង់ក្នុងឆ្នាំ | E51 | 12,054,494 |
| | ប្រាក់រំដោះពន្ធលើប្រាក់ចំណេញបានបង់ក្នុងឆ្នាំ | E52.1 | 21,180,978 |
| | **ពន្ធលើប្រាក់ចំណេញត្រូវយោងទៅឆ្នាំបន្ទាប់** | E53 | 0 |
| | សម្រាប់ក្រុមហ៊ុនខេមរីល គ្លូបិល(Non-QIP) | | |

(លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦,តារាងគណនាពន្ធលើប្រាក់ចំណេញ CWG)

ជាការគណនាប្រាក់ពន្ធលើប្រាក់ចំណេញរបស់ក្រុមហ៊ុនខេមរីល គ្លូបិលដែលបានប្រកាសសម្រាប់ឆ្នាំ២០១៦។

- **បំណុលពន្ធលើប្រាក់ចំណេញ** របស់ក្រុមហ៊ុន CWG ជាក់ស្តែងជាចំនួនអវិជ្ជមានដែលស្មើពន្ធលើប្រាក់ចំណេញតាមអត្រាគឺ (163,971,476) ដោយសារក្រុមហ៊ុនមិនមានឥណទានបរទេស និងឥណទានពន្ធបន្ថែមលើការបែកចែកភាគលាភក្នុងឆ្នាំនោះទេ។ ក្នុងករណីបំណុលពន្ធលើប្រាក់ចំណេញគណនាចេញចំនួនអវិជ្ជមានដូចនេះ តួលេខ

ដែលត្រូវបំពេញក្នុងបំណុលពន្ធលើប្រាក់ គឺលេខសូន្យ ព្រោះតាមតារាងគណនាពន្ធលើប្រាក់ចំណេញ បំណុលពន្ធលើប្រាក់ចំណេញត្រូវធំជាង ឬស្មើសូន្យ។

- ***ពន្ធអប្បបរមា*** គឺស្មើ ១ភាគរយនៃចំណូលប្រតិបត្តិការសរុបប្រចាំឆ្នាំ (B0) ស្មើ 21,180,978។
- **បំណុលពន្ធលើប្រាក់ចំណេញត្រូវបង់** សម្រាប់ក្រុមហ៊ុនខេមរីល គ្លូប៊ល (Non-QIP) បានពីការប្រៀបធៀបរវាងបំណុលពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា។ ដោយក្រុមហ៊ុនខេមរីល គ្លូប៊លមានបំណុលពន្ធលើប្រាក់ចំណេញ (E46=0) តូចជាងពន្ធអប្បបរមា (E47= 21,180,970) នាំឲ្យបំណុលពន្ធលើប្រាក់ចំណេញត្រូវបង់ស្មើ ចំនួនកាត់បន្ថយនោះ E48=21,180,970 ត្រូវចាត់ទុកជាការទូទាត់ ប្រាក់ពន្ធអប្បបរមា សម្រាប់ឆ្នាំ ២០១៦។

  នេះជាការសង្ខេបករណីរបស់ក្រុមហ៊ុនCWG៖ E46 < E47 $\Rightarrow$ E47-E46= A ដូចនេះ E50=A

- **ពន្ធលើប្រាក់ចំណេញត្រូវយោងទៅឆ្នាំបន្ទាប់**

បន្ទាប់ពីធ្វើការទូទាត់បំណុលពន្ធអប្បបរមារួច ទើបយកបំណុលពន្ធលើប្រាក់ចំណេញត្រូវបង់ទៅប្រៀបធៀប ជាមួយសរុបនៃប្រាក់ពន្ធកាត់ទុក និងពន្ធរំដោះលើប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៦។ ដូចបានគណនារួចពីខាងលើ បំណុលពន្ធ លើប្រាក់ចំណេញ (E50=21,180,970) មានចំនួនតិចជាងផលបូកនៃឥណទានពន្ធកាត់ទុក (E51=12,054,494) និងឥណទានពន្ធលើប្រាក់រំដោះលើប្រាក់ចំណេញ (E52 = 21, 180,978) នាំឲ្យក្រុមហ៊ុនអាចយោងចំនួន**ពន្ធលើប្រាក់ចំណេញនេះ ត្រូវយោងទៅ**ឆ្នាំ ២០១៧ និងឆ្នាំបន្តបន្ទាប់បាន។

សង្ខេបការគណនាប្រាក់ពន្ធលើប្រាក់ចំណេញត្រូវយោងទៅឆ្នាំបន្ទាប់

E50 < (E51+E52) $\Rightarrow$ E50 - (E51+E52) = -A

ដូចនេះ E53= -A ចំនួនប្រាក់នេះត្រូវយកទៅបំពេញក្នុងប្រអប់លេខ១៦ ទំព័រទី១ នៃលិខិតប្រកាសពន្ធលើប្រាក់ចំណេញ។

11. **ទំព័រទី ១៖ ស្តីពីព័ត៌មានទូទៅរបស់សហគ្រាស៖** ត្រូវបំពេញ "16:ឥណទានពន្ធយោងទៅមុខ"សម្រាប់ពន្ធដែលក្រុមហ៊ុនខេមរីលគ្លូបិលគណនាឃើញអវិជ្ជមាន

*រូបភាពទី១៧៖ បំពេញឥណទានពន្ធយោងទៅមុខ*



| | | | |
|---|---|---|---|
| 13 Profit Tax Exemption | Year of First Revenue 2016 | Year of First Profit គ្មាន | Priority Period..................year |
| 14 Profit Tax Rate | ☐ 30% ☑ 20% ☐ 5% ☐ 0% | ☐ Progressive Rate by Tranches from 0% to 20% | |
| 15 Profit Tax Due | | 16 Tax Credit Carried Forward | (12,054,494) |

(លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ២០១៦, ទំព័រទី១)

## ៣.៤ របាយការណ៍ចំណាយបង់ពន្ធសរុប

### ៣.៤.១ ចំណាយបង់ពន្ធប្រចាំខែសរុប

ក្រោយធ្វើប្រតិបត្តិការអាជីវកម្ម និងអនុវត្តការប្រកាសពន្ធអស់រយៈពេល៩ខែ ក្រុមហ៊ុន ខេមរីល គ្លូបិល បានចំណាយលើការបង់ប្រចាំខែ លើពន្ធរំដោះលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុកដូចមានក្នុងតារាងខាងក្រោម៖

*តារាងទី១៤៖ តារាងរបាយការណ៍សរុបនៃការបង់ពន្ធប្រចាំខែ(ឆ្នាំ២០១៦)គិតជារៀល*

| 2016 | June | July | Aug | Sep | Oct | Nov | Dec |
|---|---|---|---|---|---|---|---|
| PPT | 209,815 | 529,042 | 2,773,052 | 5,270,528 | 4,222,033 | 4,556,828 | 3,639,178 |
| VAT | 2,098,148 | 5,290,415 | 27,599,420 | 51,707,224 | 41,992,632 | 44,839,575 | 36,161,895 |
| TOS | 2,025,450 | 2,052,010 | 1,672,742 | 2,290,700 | 2,261,295 | 2,206,443 | 2,779,260 |
| WHT | 530,660 | 531,700 | 532,610 | 532,480 | 633,629 | 591,465 | 8,701,950 |
| TOTAL | 4,864,073 | 8,403,167 | 32,577,824 | 59,800,932 | 49,109,589 | 52,194,311 | 51,282,283 |

*តារាងទី១៥៖ របាយការណ៍សរុបនៃការបង់ពន្ធប្រចាំខែ(ឆ្នាំ២០១៧)*

| 2017 | Jan | Feb | Mar |
|---|---|---|---|
| PPT | 3,082,996 | 3,474,099 | 4,154,282 |
| VAT | 30,692,701 | 34,411,762 | 41,406,952 |
| TOS | 2,665,108 | 2,636,660 | 2,582,801 |
| WHT | 1,757,722 | 2,108,433 | 1,946,963 |
| TOTAL | 38,198,527 | 42,630,954 | 50,090,998 |

*ដ្យាក្រាមសរសេរដេកទី១៖ ប្រៀបធៀបចំនាយបង់ពន្ធពីខែមិថុនា ២០១៦ ដល់ខែមីនា២០១៧*




យោងតាមតារាងរបាយការណ៍បង់ពន្ធរបស់ក្រុមហ៊ុនខេមវីល គ្លូប៊ល ក្នុងរយៈពេល៩ខែដំបូងនៃដំណើរការប្រតិបត្តិការអាជីវកម្ម ដោយសង្កេតឃើញក្នុងក្រាបសសរ យ៉ាងច្បាស់ថាការចំណាយបង់ពន្ធពី ១ខែទៅ ១ខែ គឺមានការប្រែប្រួលឡើងចុះ។

- សម្រាប់ចំណាយបង់ពន្ធលើប្រាក់បៀវត្ស មិនសូវមានការប្រែប្រួលអ្វីគួរឲ្យកត់សម្គាល់ឡើយ។
- សម្រាប់ចំណាយពន្ធកាត់ទុក៖ ចំណាយបីប្រភេទសំខាន់ៗ គឺចំណាយលើសេវាកម្ម ការបង់ការប្រាក់ ការជួលអចលនទ្រព្យ មានការប្រែប្រួលកើនឡើងខ្លាំងលេចធ្លោជាងគេនៅខែធ្នូ ឆ្នាំ២០១៦ ដោយសារក្នុងខែនោះ ក្រុមហ៊ុនបានចំណាយទៅលើការប្រាក់ចំនួន ៥,៩៧២,៥២៩៛ និងចំណាយ ជួសជុលកែលំអការិយាល័យចំនួន ២,២៩០, ៥៨៣៛ ដែលទាញឲ្យចំណាយ ដែល ត្រូវជាប់ពន្ធកាត់ទុកកើនឡើងបែបនេះ។
- សម្រាប់ពន្ធរំដោះលើប្រាក់ចំណេញ ដែលចំនួនទឹកប្រាក់បង់ពន្ធអាស្រ័យទៅនឹងប្រាក់ចំណូលដែលរកបានប្រចាំខែ មិនគិតរួមបញ្ចូល អាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុនខេមវីល គ្លូប៊ល ដោយចំនួនបង់ពន្ធនេះមិនមានអ្វីគួរឲ្យកត់សម្គាល់ឡើយ។
- សម្រាប់ចំណាយបង់អាករលើតម្លៃបន្ថែម ដែលបានពីការកាត់កងរវាង អាករលើធាតុចូល និងធាតុចេញ។ ក្រុមហ៊ុនខេមវីល គ្លូប៊ល ជាក្រុមហ៊ុនដឹកជញ្ជូន និងជើងសារ ដូចនេះអាករលើធាតុចូលមិនសូវមានច្រើនដូចក្រុមហ៊ុនផលិតកម្ម និងលក់ទំនិញ

សម្រាប់កាត់កងជាមួយអាករលើធាតុចេញឡើយ ដែលជាមូលហេតុធ្វើឲ្យចំណាយបង់អាករលើតម្លៃបន្ថែមខ្ពស់ អាស្រ័យតាមចំណូលដែលក្រុមហ៊ុនរកបានក្នុង ១ខែៗ។

- សម្រាប់ចំនួនសរុបនៃចំនាយប្រចាំខែ ក្នុងរយៈពេល៩ខែនេះ ក្រុមហ៊ុនខេមរីល គ្លូប៊ល បានចំណាយបង់ពន្ធះ
  - **ចំណាយបង់ពន្ធតិចជាងគេ** គឺខែមិថុនា ព្រោះជាខែដែលក្រុមហ៊ុន ទើបតែចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម ដូចនេះ ចំណូល និងចំណាយមិនសូវមានច្រើននៅឡើយទេ។
  - **ចំណាយបង់ពន្ធច្រើនជាងគេ** គឺខែកញ្ញា ព្រោះក្នុងខែនេះ ក្រុមហ៊ុនរកចំណូលបានយ៉ាងច្រើន ដែលធ្វើឲ្យអាករលើធាតុចូលក៏កើនឡើងយ៉ាងគួរឲ្យកត់សម្គាល់។ រៀងរាល់ខែការចំណាយបង់ពន្ធ គឺប្រែប្រួលឡើងចុះគឺទៅតាម ចំណាយអាករលើតម្លៃបន្ថែម។ ក្នុងខែកញ្ញានេះ ក្រុមហ៊ុនចំណាយអាករលើតម្លៃបន្ថែម រហូតដល់ ៥១,៧០៧,២២៤រៀល ដែលធ្វើឲ្យចំណាយបង់ពន្ធសរុបចំនួន ៥៩,៨០០,៩៣២រៀល។

### ៣.៤.២ ចំណាយបង់ពន្ធប្រចាំឆ្នាំសរុប

❖ ឆ្នាំ២០១៦

- ពន្ធប៉ាតង់២០១៦ បង់អស់ទឹកប្រាក់ ១,២០០,000រៀល។
- ពន្ធលើប្រាក់ចំណេញ ប្រកាសសូន្យ ដូចបង្ហាញពីផ្នែកខាងលើឃើញថាលទ្ធផលសារពើពន្ធក្នុងការិយបរិច្ឆេទ២០១៦ គឺទទួលបានលទ្ធផលខាត ចំនួន 819,857,382រៀល ដែលត្រូវយោងឥណទានខាតយោងទៅមុខសម្រាប់កាត់កងនៅឆ្នាំបន្ទាប់។

❖ ឆ្នាំ២០១៧

- ពន្ធប៉ាតង់២០១៧ បង់អស់ទឹកប្រាក់ចំនួន ១,២០០,000រៀល។

# ជំពូកទី ៤

# ការវិភាគ SWOT

# ជំពូក ៤

# ការវិភាគSWOT លើការប្រកាសពន្ធ

ក្រោយពីបានដឹង និងសិក្សាពីនិតីវិធី និងដំណើរការនៃការប្រកាសពន្ធរបស់ក្រុមហ៊ុនរួចមក ចំណុចខាងក្រោមនេះនឹងបង្ហាញផងដែរ នូវចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ល លើការប្រកាសពន្ធ ទាំងប្រចាំខែ និងប្រចាំឆ្នាំ។

## ៤.១ ចំណុចខ្លាំង

ក្រុមហ៊ុនខេមរីល គ្លូប៊ល ជាក្រុមហ៊ុនដែលមានសក្តានុពល បើទោះជាក្រុមហ៊ុនក្មេងខ្ចីក្នុងវិស័យសេវាកម្រៃជើងសារលើការដឹកជញ្ជូនក៏ដោយ ពិសេសក្មេងខ្ចីក្នុងការប្រកាសពន្ធ ប៉ុន្តែសមត្ថភាព និងលទ្ធភាពក្នុងការប្រកាសពន្ធមានប្រសិទ្ធភាព ដែលក្នុងនោះរួមមាន៖

- គណនេយ្យករមានចំណេះដឹង និងជំនាញផ្នែកគណនេយ្យ និងការប្រកាសពន្ធ
- រាល់ឯកសារ និងព័ត៌មានដែលប្រកាសពន្ធសុទ្ធតែមានភាពច្បាស់លាស់ និងត្រឹមត្រូវ
- គណនេយ្យករបានចូលរួមតាមដានគ្រប់ព័ត៌មានដែលបានបច្ចុប្បន្នភាពទាន់ពេលវេលា និងធ្វើឲ្យការប្រកាសពន្ធរាល់ខែសមស្របតាមច្បាប់ និងទាន់ពេលវេលា
- ក្រុមហ៊ុនបានបង់ពន្ធ និងបានដាក់ឯកសារ និងលិខិតប្រកាសពន្ធទៅរដ្ឋបាលពន្ធដារបានទៀងទាត់ និងទាន់ពេលវេលា
- ក្រុមហ៊ុនបានប្រើប្រាស់ប្រព័ន្ធសុវត្ថិភាពCloud ក្នុងការរក្សាទុកទិន្នន័យឯកសារផ្នែកទន់ (Soft Copy) រីឯទិន្នន័យឯកសារផ្នែករឹង (Hard Copy) ត្រូវបានតម្កល់ទុកយ៉ាងមានសុវត្ថិភាពផងដែរ។

## ៤.២ ចំណុចខ្សោយ

ទន្ទឹមនឹងការរកឃើញនូវភាពខ្លាំងរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ល ក៏មានចំណុចខ្វះខាត និងកម្សោយដែលបានកើតមាននៅពេលរៀបចំឯកសារ ដើម្បីដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ។

- ពេលចាប់ផ្តើមប្រកាសពន្ធដំបូង ការរៀបចំឯកសារភ្ជាប់ នៅមានចំនុចខ្វះខាត
- មានភាពពិបាក និងស្មុគ្រស្មាញក្នុងការប្រមូលឯកសារពីផ្នែកផ្សេងៗម្តងៗ សម្រាប់រៀបចំឯកសារប្រកាសពន្ធ

- វិក័យបត្រក្នុងការវិភាគចំណាយ មានភាពមិនច្បាស់លាស់ដោយសារការសរសេរវិក័យប័ត្រមិនសូវច្បាស់ និង វិក័យប័ត្រខ្លះមិនទាន់មានលក្ខណៈត្រឹមត្រូវ។

**៤.៣.បញ្ហាប្រឈម**

- មិនអាចប្រកាសចំណាយមួយចំនួនដែលមិនមានវិក័យបត្រមិនត្រឹមត្រូវ និងសមស្របដែលអាចប្រកាសពន្ធបាន ព្រោះរដ្ឋបាលពន្ធដារមិនទទួលស្គាល់ចំណាយ
- ព័ត៌មានខ្លះ រដ្ឋបាលពន្ធដារមិនបានជូនដំណឹងតាមវេបសាយ ឡើយ ដែលជាហេតុធ្វើឲ្យខកខានព័ត៌មាន និងត្រូវកែសម្រួលម្តងទៀតពេលដាក់លិខិតប្រកាសពន្ធម្តងៗ
- ក្រុមហ៊ុនប្រឈមនឹងការខាតបង់ពេលវេលា និងប្រាក់កាសពេលមានបញ្ហា ទោះជាបញ្ហានោះបង្កឡើងដោយរដ្ឋបាលពន្ធដារក៏ដោយ។ ឧទាហរណ៍៖ ប័ណ្ណប៉ាតង់2017 ខុសឈ្មោះ។

**៤.៤ ឱកាស**

- រួមចំណែកបង់ពន្ធជូនរដ្ឋ ក្នុងគោលដៅមិនត្រឹមតែទទួលបានប្រាក់ចំណេញ ប៉ុន្តែចូលរួមអភិវឌ្ឍជាតិ
- ជាភស្តុតាងបង្ហាញពីការលំនឹង និងការវិវឌ្ឍន៍នៃក្រុមហ៊ុន
- បង្ហាញដល់អតិថិជនថាក្រុមហ៊ុនជាក្រុមហ៊ុនស្របតាមច្បាប់ មានបានចុះបញ្ជីត្រឹមត្រូវ ដែលអតិថិជនមានទំនុកចិត្តក្នុងចាប់ដៃគូរកស៊ីជាមួយគ្នាបាន
- អាចចូលប្រឡូកក្នុងទីផ្សារអន្តរជាតិ និងប្រកួតប្រជែងគ្នាបានដោយតម្លាភាព។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ច្បាប់សារពើពន្ធនៃកម្ពុជាត្រូវបានកែសម្រួល និងធ្វើវិសោធនកម្មជារឿយៗ។ តួយ៉ាង នីតិវិធីក្នុងការប្រកាសពន្ធស្វ័យប្រកាស ដែលតម្រូវឲ្យក្រុមហ៊ុនខេមរីល គ្លូប៊ល ក៏ដូចជាក្រុមហ៊ុនដទៃទៀត ត្រូវតាមដានព័ត៌មាន និងការវិវត្តន៍នៃច្បាប់នេះ ក៏ដូចជាប្រកាសដែលពាក់ព័ន្ធនឹងនីតិវិធីប្រកាសពន្ធផ្សេងៗ ដើម្បីឲ្យការអនុវត្តកាន់តែមានប្រសិទ្ធភាព ត្រឹមត្រូវ និងអនុលោមទៅតាមច្បាប់។

បើក្រឡេកទៅមើលការអនុវត្តផ្ទាល់នៃដំណើរការក្នុងការប្រកាសពន្ធរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ល យើងបានកត់សម្គាល់ឃើញថាមានលក្ខណៈល្អប្រសើរ មិនថាការកាន់កាប់បញ្ជីការគណនេយ្យ ការរៀបចំលិខិតប្រកាស និងការដាក់លិខិតប្រកាសនោះទេ គឺត្រូវបានរៀបចំទៅតាមលំដាប់លំដោយនៃដំណាក់កាលនីមួយៗ។ ក្នុងដំណាក់កាលនីមួយៗទៀតសោត គឺមានប្រព័ន្ធនិងតារាងគណនាពន្ធ ការបំពេញលិខិតប្រកាសដែលត្រូវបានរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើឲ្យមានភាពងាយស្រួលក្នុងការរៀបចំឯកសារប្រកាសឲ្យមានប្រសិទ្ធភាពខ្ពស់ រហ័ស ពិសេសមានភាពសមស្របអនុលោមទៅតាមច្បាប់សារពើពន្ធ និងរដ្ឋបាលពន្ធដារបានកំណត់។ ការដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ ក្រុមហ៊ុនខេមរីល គ្លូប៊លអនុវត្តបានត្រឹមត្រូវ និងមិនមានភាពយឺតយ៉ាវ សូម្បីការរក្សាទុកឯកសារពន្ធ និងឯកសារជាប់ពាក់ព័ន្ធទាំងអស់ក៏ត្រូវបានរក្សាទុកយ៉ាងល្អ។

ក្រុមហ៊ុនខេមរីល គ្លូប៊លបានធ្វើការបង់ពន្ធបានទាន់ពេលវេលា និងទៀងទាត់ល្អ មិនដែលគេចវេសកាតព្វកិច្ចម្តងណាឡើយ បើទោះជាក្រុមហ៊ុនទើបតែបង្កើតក្មេងខ្ចី តែមានទំនួលខុសត្រូវខ្ពស់ក្នុងនាមជាអ្នកជាប់ពន្ធមធ្យមដែលត្រូវមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋយ៉ាងខ្ជាប់ខ្ជួន។ ពីមួយខែទៅមួយខែ ក្រុមហ៊ុនខេមរីល គ្លូប៊ល បានចំណាយបង់ពន្ធជូនរដ្ឋ មិនដែលអាក់ខាន និងយឺតយ៉ាវឡើយ ទោះខែខ្លះរបាយការណ៍លទ្ធផលរបស់ក្រុមហ៊ុនបង្ហាញថាខាតក៏ដោយ។

យោងតាមរបាយការណ៍ចំណាយបង់ពន្ធ ការចំណាយក្នុងការបង់ពន្ធរាល់ខែរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ល មានការប្រែប្រួលអាស្រ័យទៅតាមចំណូលចំណាយជាប់ពន្ធក្នុងការប្រតិបត្តិការអាជីវកម្ម។ បន្ថែមពីនេះទៅទៀត របាយការណ៍ការចំណាយបង់ពន្ធរបស់ក្រុមហ៊ុនខេមរីល បានឆ្លុះបញ្ចាំងទាំងភាពវិជ្ជមាន និងអវិជ្ជមាន។ ផលវិជ្ជមាន គឺបង្ហាញថាក្រុមហ៊ុនមានការរីកចម្រើនទៅមុខ ព្រោះកាលណាការចំណាយបង់ពន្ធកាន់តែច្រើន នោះទំហំប្រតិបត្តិការអាជីវកម្មក៏កាន់តែ

ធំផងដែរ។ រីឯផលអវិជ្ជមានវិញ គឺក្នុងមួយខែៗ ក្រុមហ៊ុនត្រូវចំណាយបង់លើការបង់ពន្ធយ៉ាងច្រើនសន្ធឹកសន្ធាប់ដូចបង្ហាញក្នុងរបាយការណ៍ ដែលក្នុងឆ្នាំដំបូងនោះនៃអាជីវកម្មក្រុមហ៊ុនមិនបានទទួលប្រាក់ចំណេញនៅឡើយទេក្នុងរយៈពេលនោះ។

ជារួមមក របាយការណ៍កម្មសិក្សានេះអាចសន្និដ្ឋានបានជាពីរផ្នែកថា ទីមួយ ការតាមដានព័ត៌មានទាក់ទងពីនីតិវិធី ក្នុងការអនុវត្តការប្រកាសពន្ធពិតជាចាំបាច់ និងមានសារៈសំខាន់ណាស់ក្នុងនាមជាអ្នកជាប់ពន្ធមិនថារូបវន្តបុគ្គល ឬនីតិបុគ្គល។ ទីពីរ គឺការអនុវត្តការប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនខេមរីល គ្លូប៊ិលពិតជាគោរពបានត្រឹមត្រូវ ស្របតាមច្បាប់ និងតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ។

## ២. អនុសាសន៍

ឆ្លងតាមការវិភាគSWOT ក្នុងការអនុវត្តប្រកាសពន្ធដែលយើងបានរកឃើញក្នុងពេលចុះកម្មសិក្សានៅក្រុមហ៊ុនខេមរីល គ្លូប៊ិល ក្នុងរបាយការណ៍នេះសូមផ្តល់នូវមតិយោបល់មួយចំនួនទៅដល់ក្រុមហ៊ុនខេមរីល គ្លូប៊ិលដូចខាងក្រោម ដើម្បីឲ្យការអនុវត្តនេះកាន់តែមានប្រសិទ្ធភាព និងដើម្បីបញ្ចៀសនូវបញ្ហាទាំងឡាយណាដែលអាចកើតមានឡើង នៅពេលប្រកាសពន្ធលើកក្រោយទៀត៖

- ធ្វើការបណ្តុះបណ្តាលគ្រប់បុគ្គលិកផ្នែកបញ្ជាទិញ អំពីចំណេះដឹងទាក់ទងនឹងគំរូវិក័យប័ត្រ ដែលពន្ធដារទទួលស្គាល់
- រៀបចំប្រព័ន្ធប្រមូលឯកសារដែលត្រូវប្រកាសពន្ធកាន់តែមានប្រសិទ្ធភាព
- គួររៀបចំតារាងសង្ខេបលក្ខណៈចំណាយ និងចំណូលប្រភេទណាដែលជាប់ពន្ធ ដែលបង្កលក្ខណៈងាយស្រួលដល់អ្នកតំណាងក្រុមហ៊ុនរៀបចំឯកសារប្រកាសពន្ធ។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

- ច្បាប់ស្តីពីសារពើពន្ធកម្ពុជា, លេខនស/រកម/០៣០៣/០១០, ៣១ ខែមីនា ឆ្នាំ២០០៣
- ច្បាប់ស្តីពីហិរញ្ញវត្ថុក្នុងការគ្រប់គ្រងឆ្នាំ ២០១៧, លេខនស/រកម/១២១៩/០១៩, ១៥ ធ្នូ ឆ្នាំ ២០១៦
- ច្បាប់ស្តីពីហិរញ្ញវត្ថុក្នុងការគ្រប់គ្រងឆ្នាំ ២០១៦, លេខនស/រកម/១២១៩/០១៦, ២១ ធ្នូ ឆ្នាំ ២០១៥
- ប្រកាសស្តីពីការចុះបញ្ជីពន្ធដារ, លេខ៤៥៦សហវ, ០៦ មេសា ឆ្នាំ ២០១៦
- ប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស, លេខ១១៧៣សហវ.ពដ.ប្រក, ៣១ ធ្នូ ឆ្នាំ២០០៣
- ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ, លេខ១០៥៩សហវ.ពដ.ប្រក, ១២ ធ្នូ ឆ្នាំ២០០៣
- ប្រកាសស្តីពីការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធ, លេខ១៨១៩សហវ.ប្រក, ២៥ ធ្នូ ឆ្នាំ ២០១៦
- ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រង និងប្រមូលអាករបំភ្លឺសាធារណៈរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ១៧៥សហវ.ពដ.ប្រក, ២២ មករា ឆ្នាំ ២០០២
- ប្រកាសស្តីពីការអនុវត្តន៍អាករលើការស្នាក់នៅ, លេខ ៣៨០សហវ.ពដ, ១៤ កក្កដា ឆ្នាំ ២០០៥
- សេចក្តីណែនាំស្តីពីការប្រើប្រាស់វិក័យប័ត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស, លេខ១១២៧អពដ, ២៦ មករា ឆ្នាំ ២០១៦
- សេចក្តីណែនាំស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្ស, លេខ០១៧សហវ.អពដ, ២៧ ធ្នូ ឆ្នាំ ២០១៦
- សេចក្តីជូនដំណឹងស្តីពីការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញក្នុងស្រុក, លេខ៤២២៧អពដ, ២២ មីនា ឆ្នាំ ២០១៦
- សេចក្តីជូនដំណឹងស្តីពីការដាក់លិខិតប្រកាស និងបង់ពន្ធប៉ាតង់ឆ្នាំ ២០១៧, លេខ១៨៩៧អពដ, ៣១ មករា ឆ្នាំ ២០១៧
- ទៀ វ៉ាន់ថា "Cambodia Taxation", មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហរិញ្ញវត្ថុឆ្នាំទី៤, សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សឿង ខេមរ័ត្ន និងភឿន សារីន, "របបស្វ័យប្រកាសពន្ធដារនៅកម្ពុជា" (និក្ខេបបទថ្នាក់បរិញ្ញាប័ត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)
- Expert Teams of ODI Asia "Advance Cambodia Tax System &Tax Compliance" (HAGAR Catering, Phnom Penh, 24th-25th May 2011

- "ពន្ធដារកម្ពុជា", វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ
- www.tax.gov.kh (ចូលទស្សនាថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៧)
- www.camwillglobal.kh (ចូលទស្សនាថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៧)
- http://www.pwc.com/kh/en/publications/assets/Cambodia-PBT-2015-final.pdf (ចូលទស្សនាថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៧)
- http://www.vdb-loi.com/cambodia-tax-and-legal/tax-on-profit-top-in-cambodia-2/ (ចូលទស្សនាថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៧)
- https://www.dfdl.com/resources/legal-and-tax-updates/cambodia-tax-update-draft-law-on-financial-management-2017/ (ចូលទស្សនាថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៧)
- http://www.phnompenhpost.com/national/understanding-annual-tax-profit-declarations (ចូលទស្សនាថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៧)
- http://www.angkorvoice.com/articles/100 (ចូលទស្សនាថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៧)

# ឧបសម្ព័ន្ធទី១៖

# បទបញ្ញត្តិផ្សេងៗស្តីពី

# ពន្ធស្ម័យប្រកាស

## កម្រងសំណួរ

1. តើក្រុមហ៊ុនបានបង្កើតឡើងនៅឆ្នាំណា? មានអ្នកណាជាម្ចាស់?
2. តើក្រុមហ៊ុនមានទស្សនៈវិស័យ បេសកកម្ម និងគោលបំណងដូចម្តេចខ្លះ?
3. តើក្រុមហ៊ុនមាននិមិត្តសញ្ញា និងអត្ថន័យដូចម្តេចដែរ?
4. តើក្រុមហ៊ុនមានរចនាសម្ព័ន្ធដូចម្តេច?
5. តើក្រុមហ៊ុនមានបុគ្គលិកសរុបទាំងអស់ប៉ុន្មាននាក់?
6. តើក្រុមហ៊ុនបានផ្តល់ជូនសេវាកម្មអ្វីខ្លះដល់អតិថិជន? សេវាកម្មចំបង?
7. តើក្រុមហ៊ុនមានដៃគូពាណិជ្ជកម្មជាមួយក្រុមហ៊ុនណាខ្លះ?
8. តើក្រុមហ៊ុនបានចុះបញ្ជីជាមួយពន្ធដារនៅឆ្នាំណា?
9. តើក្រុមហ៊ុនជាប្រភេទក្រុមហ៊ុនជាប់ពន្ធតូច ធំ ឬ មធ្យម?
10. តើក្រុមហ៊ុនបានអនុវត្តការប្រកាសពន្ធតាមនីតិវិធីជូនពន្ធដារបានត្រឹមត្រូវដែរទេ?
11. តើក្រុមហ៊ុនបានជួបបញ្ហាអ្វីខ្លះក្នុងការប្រកាសពន្ធជូនពន្ធដារ?
12. តើក្រុមហ៊ុនបានដោះស្រាយបញ្ហានោះដោយវិធីណា?
13. សូមរៀបរាប់ពីនីតិវិធីក្នុងការប្រកាសពន្ធដែលពន្ធដារបានកំណត់ជូន។
14. សូមរៀបរាប់ពីដំណើរការក្នុងការប្រកាសពន្ធស្វ័យប្រកាសរបស់ក្រុមហ៊ុន។
15. តើក្រុមហ៊ុនមានប្រភេទពន្ធស្វ័យប្រកាសអ្វីខ្លះ? ក្នុងចំណោមពន្ធទាំងអស់ តើពន្ធមួយណាដែលក្រុមហ៊ុនគិតថាសំខាន់ជាងគេ ហើយមានភាពស្មុគស្មាញជាងគេ?
16. តើពន្ធដារមានគោលនយោបាយបែបណា បើសិនជាក្រុមហ៊ុនមានការយឺតយ៉ាវក្នុងការបង់ពន្ធ? តើក្រុមហ៊ុនធ្លាប់ជួបវិបត្តិនេះដែរទេ?
17. ក្រៅពីបញ្ហានានា តើពន្ធដារបានផ្តល់ជូននូវភាពងាយស្រួល ក៏ដូចជាការលើកទឹកចិត្តអ្វីដែរទេជូនចំពោះក្រុមហ៊ុន?
18. សូមបកស្រាយពីរបៀបក្នុងការគណនាពន្ធប្រចាំខែ និងប្រចាំឆ្នាំរបស់ក្រុមហ៊ុន។
19. តើក្រុមហ៊ុនបានប្រើវិធីសាស្ត្រអ្វីខ្លះក្នុងការគណនាពន្ធប្រចាំខែ និងប្រចាំឆ្នាំ?
20. នៅពេលអនាគត តើក្រុមហ៊ុនមានយុទ្ធសាស្ត្របែបណាក្នុងការពង្រឹងការអនុវត្តន៍នីតិវិធីប្រកាសពន្ធរបស់ខ្លួន?

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ........សហវ

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីពន្ធដារ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ១៨១៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានពន្ធដារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការចុះបញ្ជីពន្ធដារ ស្របតាមមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះមានគោលដៅដូចខាងក្រោម÷

- ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីគ្រប់គ្រង ឱ្យបានកាន់តែប្រសើរឡើងនូវទិន្នន័យរបស់អ្នកជាប់ពន្ធ
- គាំទ្រដល់ការផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យបានកាន់តែល្អប្រសើរ
- គាំទ្រដល់ការគ្រប់គ្រងការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធ ដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ÷

- ពាក្យ "**ការចុះបញ្ជីពន្ធដារ**" សំដៅដល់ការចុះបញ្ជី អ្នកជាប់ពន្ធទាំងឡាយដែលធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ពាក្យ "**អ្នកជាប់ពន្ធ**" សំដៅដល់បុគ្គលទាំងឡាយដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។
- ពាក្យ "**សកម្មភាពសេដ្ឋកិច្ច**" សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើ ជានិច្ចកាលជាប់បន្ត ឬ មួយដងមួយគ្រា ដើម្បីរក ឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។
- ពាក្យ "**អាជីវកម្ម**" សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលពីការផលិតនិងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួលឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត។

**ប្រការ ៥.- កាតព្វកិច្ចចុះបញ្ជីពន្ធដារ**

បុគ្គលទាំងឡាយ ត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ។

**ប្រការ ៦.- ការស្នើសុំចុះបញ្ជីពន្ធដារ**

បុគ្គលទាំងឡាយ ដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវធ្វើការស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិក (E-registration) ដោយត្រូវបំពេញ

ទម្រង់ចុះបញ្ជីដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងតម្រូវឱ្យភ្ជាប់មកជាមួយនូវឯកសារដូចមានកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ ៧.- ឯកសារ និងការតម្រូវ សម្រាប់ការចុះបញ្ជីពន្ធដារ**

**១- អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ**

**ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ**

ប្រធាន ឬអ្នកតំណាងរបស់ ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម÷

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ឬ/និង
  - លក្ខន្តិកៈ ឬអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)
- **ឯកសារបញ្ជាក់អត្តសញ្ញាណ ប្រធានឬអ្នកតំណាង**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល០៣ខែ ដែលមានទំហំ ៣៥ x ៤៥មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះនិងចុះហត្ថលេខាម្ចាស់រូបថត នៅខាងខ្នង
- **ឯកសារបញ្ជាក់ទីតាំង**
  - ប័ណ្ណកម្មសិទ្ធិទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

**ខ. សហគ្រាសឯកបុគ្គល និងសហគ្រាសនីតិបុគ្គល**

ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ត្រូវបានតម្រូវឱ្យមកថតរូប ស្កែនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

ករណីប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាសដែលមានសញ្ជាតិបរទេស ហើយស្នាក់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមិនអាចអញ្ជើញមកថតរូប ស្កែនម្រាមដៃ ត្រូវធ្វើលិខិតផ្ទេរសិទ្ធិឱ្យអ្នកតំណាងណាមួយនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ មកថតរូបនិងស្កែនម្រាមដៃជំនួសបាន និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធ ដែលមានចែងក្នុងប្រការនេះ ដើម្បីទទួលបាននូវប័ណ្ណពន្ធប៉ាតង់ ឬ/និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

ចំពោះប្រធានក្រុមប្រឹក្សាភិបាលឬម្ចាស់សហគ្រាសមានសញ្ជាតិបរទេស តែស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រធានក្រុមប្រឹក្សាភិបាលឬម្ចាស់សហគ្រាសមានសញ្ជាតិខ្មែរ ត្រូវបានតម្រូវឱ្យមកថតរូប និងស្កែនម្រាមដៃ និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធ ដែលមានចែងក្នុងប្រការនេះ ដើម្បីទទួលបាននូវ

ប័ណ្ណពន្ធប៉ាតង់ ឬ/និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

ក្នុងករណីចាំបាច់ អ្នកជាប់ពន្ធអាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប និងស្កែនម្រាមដៃ ដល់ទីតាំងសហគ្រាស ឬទីកន្លែងសមស្របណាមួយ។

ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន បណ្ណាធិការ ឬអ្នកតំណាង ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម÷

- **ឯកសារចុះបញ្ជីចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ឬ/និង
  - លិខិតទទួលចុះបញ្ជីនូវការបង្កើតសាខា ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ (សម្រាប់ការចុះបញ្ជីសាខា) ឬ/និង
  - លក្ខន្តិកៈក្រុមហ៊ុនសម្រាប់នីតិបុគ្គល ឬ/និង
  - ព័ត៌មានគណនីធនាគាររបស់សហគ្រាស ដូចជាលិខិតបញ្ជាក់ គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ។
- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធករ ឬម្ចាស់ភាគហ៊ុន បណ្ណាធិការ អ្នកតំណាង និងអ្នកគ្រប់គ្រងសាខា**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែ ដែលមានទំហំ ៣៥ x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល។
- **ឯកសារបញ្ជាក់ទីតាំងទីចាត់ការសហគ្រាស អាជីវកម្មគោលដើម សាខាសហគ្រាស និងឃ្លាំង**
  - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ
- **ឯកសារផ្សេងៗ**
  - វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់)
  - អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)។

### គ. សមាគម និងអង្គការនានា

ប្រធានសមាគម ប្រធានអង្គការនានាដែលធ្វើអាជីវកម្ម ឬអ្នកតំណាងណាមួយដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវបានតម្រូវឱ្យមកថតរូប និងស្កែនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ និងតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម÷

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**

- លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ឬ/និង
- លក្ខន្តិកៈ ឬអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច ឬ/និង
- ព័ត៌មានគណនីធនាគារ ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនី ដែលចេញដោយធនាគារ (សម្រាប់តែសមាគម ឬអង្គការនានា ដែលធ្វើអាជីវកម្ម)

- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធាន ឬអ្នកតំណាង**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥ x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬអ្នកតំណាង សមាគម ឬអង្គការនានា។
- **ឯកសារបញ្ជាក់ទីតាំង**
  - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

## ២- អ្នកជាប់ពន្ធដទៃទៀត

អ្នកជាប់ពន្ធតូច ឬបុគ្គលទាំងឡាយណាដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល០៣ខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០ លានរៀល ត្រូវបានតម្រូវឱ្យបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ និងភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬច្បាប់ថតចម្លងនៃឯកសារទាំងឡាយដែលមានបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ដូចខាងក្រោម ÷

- **ឯកសារចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជីចេញដោយ ក្រសួង ស្ថាប័នពាក់ព័ន្ធ (បើមាន)
- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់កម្មសិទ្ធិករ**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព
  - រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ០៣ខែ ដែលមានទំហំ ៣៥x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះ និងចុះហត្ថលេខាទទួលខុសត្រូវដោយម្ចាស់រូបថត។
- **ឯកសារបញ្ជាក់ទីតាំងអាជីវកម្មដ្ឋាន**
  - ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
  - លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

## ៣- ការប្រើប្រាស់អាសយដ្ឋានក្នុងការចុះបញ្ជីពន្ធដារ និងតម្រូវការឯកសារភ្ជាប់បន្ថែម

សម្រាប់គោលដៅនៃការចុះបញ្ជីពន្ធដារ អាសយដ្ឋាននៃទីតាំងរបស់ស្ថាប័ន ឬទីចាត់ការសហគ្រាស ឬសាខាសហគ្រាស ឬសមាគម ឬអង្គការនានា ដែលគ្មានអគារ (ដីទំនេរ) ឬមានសំណង់ទើបតែចាប់ផ្ដើមសាងសង់

មិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាអាសយដ្ឋានសម្រាប់ការចុះបញ្ជីពន្ធដារបានឡើយ វៀរលែងតែមានការយល់ព្រមពីអគ្គនាយកដ្ឋានពន្ធដារ។

អ្នកជាប់ពន្ធដែលមានអាសយដ្ឋានស្នាក់នៅ ខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន អ្នកជាប់ពន្ធត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៨.- ការស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាសដែលបានចុះបញ្ជី**

១. អនុលោមតាមមាត្រា ១០១ នៃច្បាប់ស្ដីពីសារពើពន្ធ អ្នកជាប់ពន្ធបានចុះបញ្ជីពន្ធដាររួចហើយ ត្រូវបានតម្រូវឱ្យធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ក្នុងករណីដែលព័ត៌មានណាមួយក្នុងចំណោមព័ត៌មានខាងក្រោមនេះត្រូវបានផ្លាស់ប្ដូរ៖

ក. នាមករណ៍សហគ្រាស

ខ. អាសយដ្ឋានទីចាត់ការ កន្លែងប្រកបអាជីវកម្មជាគោលដើម ឬសាខា ឃ្លាំងរបស់សគ្រាស

គ. អាសយដ្ឋានម្ចាស់សហគ្រាស អភិបាល ឬបណ្ណាធិការ របស់សហគ្រាស

ឃ. ទ្រង់ទ្រាយគតិយុត្តរបស់សហគ្រាស

ង. កម្មវត្ថុអាជីវកម្ម

ច. ការផ្ទេរ ការបញ្ឈប់អាជីវកម្ម

ឆ. សមាសភាពអ្នកគ្រប់គ្រង

ជ. អ្នកទទួលបន្ទុកកិច្ចការពន្ធ

ឈ. លេខគណនីធនាគារសហគ្រាស

ញ. លេខទំនាក់ទំនង (លេខទូរស័ព្ទ សារអេឡិកត្រូនិក)។

២. អ្នកជាប់ពន្ធត្រូវស្នើសុំមករដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីមានការផ្លាស់ប្ដូរព័ត៌មានដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ ដើម្បីធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងភ្ជាប់មកនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារចុងក្រោយនៃឯកសារនានាដែលបានតម្រូវក្នុងប្រការ៧ នៃប្រកាសនេះ។

៣. ចំពោះអ្នកជាប់ពន្ធដែលមានការផ្លាស់ប្ដូរអាសយដ្ឋានទីចាត់ការសហគ្រាស ឬទ្រង់ទ្រាយគតិយុត្តរបស់សហគ្រាស ដែលនាំឱ្យមានការផ្លាស់ប្ដូរពីការគ្រប់គ្រងរបស់អង្គភាពពន្ធដារមួយ ទៅអង្គភាពពន្ធដារមួយទៀត ត្រូវធ្វើការស្នើសុំផ្លាស់ប្ដូរអង្គភាពទៅតាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៤. ចំពោះអ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ប្រធានស្ថាប័នរដ្ឋ ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ប្រធានអង្គការមិនមែនរដ្ឋាភិបាល ត្រូវមកធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងភ្ជាប់មកនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារចុងក្រោយនៃឯកសារនានាដែលបានតម្រូវក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ៩.- កម្រៃសេវាចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស**

១. កម្រៃសេវាចុះបញ្ជីពន្ធដារមានដូចខាងក្រោម៖

- ០ រៀល សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ ដែលបានស្នើសុំ ដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌ១ នៃប្រការ៧ នៃប្រកាសនេះ
- ២០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធតូច និងអ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល ០៣ ខែ ណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០លានរៀល ដែលបានស្នើសុំដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ៧ នៃប្រកាសនេះ
- ៤០០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគម និងអង្គការនានា ដែលបានស្នើសុំ ដូចមានចែងក្នុងវាក្យខណ្ឌ ខ និង វាក្យខណ្ឌ គ នៃកថាខណ្ឌ១ នៃប្រការ៧ នៃប្រកាសនេះ។

២. កម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះមានដូចខាងក្រោម÷

- ០ រៀល សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ
- ១០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធតូច ឬបុគ្គលទាំងឡាយណាដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល០៣ខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០ លានរៀល
- ២០០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគម និងអង្គការនានា។

៣. កម្រៃសេវាដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ៩ នៃប្រការនេះ ត្រូវអនុវត្តផងដែរចំពោះអ្នកជាប់ពន្ធដែលមានការផ្លាស់ប្តូរព័ត៌មាននៅលើប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬស្នើសុំបោះពុម្ពឡើងវិញនូវ ប័ណ្ណពន្ធប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬលិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ។ ដោយឡែកការស្នើសុំបោះពុម្ពប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារឡើងវិញ អ្នកជាប់ពន្ធត្រូវបានតម្រូវឱ្យបង់កម្រៃសេវា ចំនួន ៥ ០០០ រៀល។

**ប្រការ ១០.-ការបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ**

រដ្ឋបាលសារពើពន្ធ ត្រូវចេញលិខិតបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ ដោយបញ្ជាក់កាលបរិច្ឆេទទទួលសំណុំឯកសារបន្ទាប់ពីបានពិនិត្យឃើញថា សំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារនោះត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ១១.- រយៈពេលទទួលបានការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស**

១. អ្នកជាប់ពន្ធអាចទទួលបានសេចក្តីសម្រេចចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសក្នុងរយៈពេល÷

- ០១ថ្ងៃ ទៅ ០៧ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិកត្រូនិក (E-registration)

- ០៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះការចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

២. ក្រោយពេលចុះបញ្ជីពន្ធដារ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសរួចរាល់ រដ្ឋបាលសារពើពន្ធត្រូវចុះដល់ទីតាំងផ្ទាល់របស់សហគ្រាស ដើម្បីថតរូបទីតាំង និងកត់ត្រាទិន្នន័យរបស់ទីតាំងសហគ្រាស (GPS) ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ និងប្រគល់ឯកសារផ្លូវការដែលបានចេញដោយរដ្ឋបាលសារពើពន្ធ ដោយមានការចុះហត្ថលេខាទទួលត្រឹមត្រូវពីអ្នកជាប់ពន្ធ។

៣. ឯកសារផ្លូវការ នៃការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលត្រូវប្រគល់ទទួលមានដូចខាងក្រោម÷

**ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា គណបក្សនយោបាយ សមាគម អង្គការនានា ដែលមិនប្រកបអាជីវកម្ម**

- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ឬ/និង
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ

**ខ. សហគ្រាសឯកបុគ្គល សហគ្រាសនីតិបុគ្គល សមាគម និងអង្គការនានា ដែលប្រកបអាជីវកម្ម**

- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណពន្ធប៉ាតង់ ឬ/និង
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ

**គ. អ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០លានរៀល ឬមានផលរបរក្នុងរយៈពេលបីខែណាមួយដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តក្រោម ៦០លានរៀល**

- លិខិតបញ្ជាក់ការចុះបញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ

**ប្រការ ១២.- សិទ្ធិរបស់រដ្ឋបាលសារពើពន្ធ**

អនុលោមតាមមាត្រា១០៣ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីជាឯកតោភាគីចំពោះ អ្នកជាប់ពន្ធដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី ហើយពុំបានមកចុះបញ្ជី។ ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី និងកំណត់នូវអ្នកតំណាងណាមួយរបស់សហគ្រាស ដើម្បីមកថតរូបនិងស្កេនម្រាមដៃដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។

ក្នុងករណីដែលប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន ប្រធានអង្គការនានា និងអ្នកតំណាង មានការទាក់ទិននឹងការគ្រប់គ្រងសហគ្រាស ឬសមាគម ឬអង្គការនានា ដទៃទៀតដែលមានជំពាក់បំណុលពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធការចុះបញ្ជីពន្ធដារ។

**ប្រការ ១៣.- សិទ្ធិរបស់អ្នកជាប់ពន្ធ**

អ្នកជាប់ពន្ធមានសិទ្ធិដាក់បណ្តឹងតវ៉ាទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំឱ្យពិនិត្យ

ឡើងវិញ លើការបដិសេធការចុះបញ្ជី។ ក្នុងករណីអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អ្នកជាប់ពន្ធអាចប្តឹងតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ។

**ប្រការ ១៤.- ទោសទណ្ឌ**

ការមិនបានចុះបញ្ជីពន្ធដារ មិនបានធ្វើបច្ចុប្បន្នភាពព័ត៌មាន ឬការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរដូចមានចែងក្នុងប្រការ៥ និងប្រការ៨ នៃប្រកាសនេះ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើរំលងស្មុះលើបទប្បញ្ញត្តិស្តីពីពន្ធដារ និងត្រូវរងទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ១៥.-និរាករណ៍**

ប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការចុះបញ្ជីពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៦.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកជាប់ពន្ធដែលមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១៧ សហវ.អគព

# សេចក្តីណែនាំ
## ស្តីពីការអនុវត្តអត្រាពន្ធលើប្រាក់បៀវត្សថ្មី

អនុលោមតាមមាត្រា៤៧ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំ ដូចតទៅ÷

### ១. រយៈពេលអនុវត្តនិងអត្រាកំណើនតាមថ្នាក់ថ្មី

គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានា ដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ពន្ធលើប្រាក់បៀវត្ស (ពបវ) ត្រូវចាប់អនុវត្តអត្រាកំណើនតាមថ្នាក់ថ្មីចំពោះប្រាក់បៀវត្ស ដែលបើកជូននិយោជិតក្នុងខែមករា ឆ្នាំ២០១៧ ដែលនឹងត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃ ទី២០ នៃ ខែកុម្ភៈ ឆ្នាំ២០១៧។

តារាងអត្រាកំណើនតាមថ្នាក់ថ្មីមានដូចខាងក្រោម ÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១ 000 000 ៛ | 0% |
| ពី | ១ 000 00១ ៛ | ដល់ | ១ ៥00 000 ៛ | ៥% |
| ពី | ១ ៥00 00១ ៛ | ដល់ | ៨ ៥00 000 ៛ | ១0% |
| ពី | ៨ ៥00 00១ ៛ | ដល់ | ១២ ៥00 000 ៛ | ១៥% |
| | | លើសពី | ១២ ៥00 000 ៛ | ២0% |

### ២. ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក

ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ ដើម្បីសម្រួលជីវភាពរស់នៅរបស់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ រាជរដ្ឋាភិបាលក៏បានសម្រេចធ្វើការដំឡើងកម្រិតកាត់បន្ថយមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះ ក្នុងម្នាក់ៗពី ៧៥ 000 រៀល ដល់ ១៥0 000 រៀល ក្នុងមួយខែ (កើនឡើងពីរដង)។ ការដំឡើងកម្រិតកាត់បន្ថយនេះ ធ្វើឱ្យមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សកាន់តែតិចដែលនាំឱ្យមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិត ដែលមានបន្ទុកចិញ្ចឹមកូន ប្តីឬប្រពន្ធ និងដែលមានប្រាក់បៀវត្សលើសពី ១ 000 000 រៀល អាចនឹងរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។


ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## ៣. ការគណនាពន្ធលើប្រាក់បៀវត្ស

ក- យោងតាមមាត្រា៤២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពាក្យ “ប្រាក់បៀវត្ស” សំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះ ការបំពេញសកម្មភាពបំរើការងារ។

ខ- ប្រាក់ឧបត្ថម្ភមួយចំនួនដែលកម្មករនិយោជិត រោងចក្រ សហគ្រាស ទទួលបានពីការបំពេញការងារដូចមានចែងក្នុងសារាចរលេខ ០០១ សហវ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែម ត្រូវបានអនុញ្ញាតឱ្យដកចេញពីមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។

គ- ដើម្បីគណនាពន្ធលើប្រាក់បៀវត្សរបស់និយោជិតនិវាសជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សដោយយកចំនួនប្រាក់បៀវត្សសរុប ក្រៅពីប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភ ដូចមានក្នុងចំណុច ខ ខាងលើ ដកចេញនូវ ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក។ បន្ទាប់មក ត្រូវពិនិត្យមើលថាតើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងថ្នាក់អត្រាពន្ធណាមួយ ទើបយកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រាពន្ធ ហើយដកចេញនូវលម្អៀងលើសប្រាក់ពន្ធ សម្រាប់ថ្នាក់អត្រាពន្ធនោះ។ លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ គឺជាផលបូកនៃពន្ធលើប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១ ០០០ ០០០ រៀលដំបូង និងលម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ។

ឃ- តារាងអត្រាកំណើនតាមថ្នាក់និងលម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រា | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ |
|---|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១ ០០០ ០០០ ៛ | ០ % | 0 ៛ |
| ពី | ១ ០០០ ០០១ ៛ | ដល់ | ១ ៥០០ ០០០ ៛ | ៥ % | ៥០ ០០០ ៛ |
| ពី | ១ ៥០០ ០០១ ៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១០ % | ១២៥ ០០០ ៛ |
| ពី | ៨ ៥០០ ០០១ ៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥ % | ៥៥០ ០០០ ៛ |
| | | លើសពី | ១២ ៥០០ ០០០ ៛ | ២០ % | ១ ១៧៥ ០០០ ៛ |

**រូបមន្ត÷**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ x សហព័ទ្ធនិងចំនួនកូនក្នុងបន្ទុក

មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស(មពបវ) = ប្រាក់បៀវត្សជាប់ពន្ធ(បវ) - ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក

ពន្ធលើប្រាក់បៀវត្ស(ពបវ) = មូលដ្ឋានគិត ពបវ x អត្រាពន្ធ - លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់នីមួយៗ(លបព)

**ឧទាហរណ៍ទី១÷** កម្មករនិយោជិតម្នាក់មានប្រាក់បៀវត្ស ២ ០០០ ០០០ រៀល

ក. ករណីនៅលីវ

មពបវ = ២ ០០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ១០%

លបព = ១២៥ ០០០៛

ពបវ = (២ ០០០ ០០០៛ x ១០%) - ១២៥ ០០០៛ = <u>៧៥ ០០០</u>៛

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៤ = ៦០០ ០០០៛

មពបវ = ២ ០០០ ០០០៛ - ៦០០ ០០០៛ = ១ ៤០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ៥%

លបព = ៥០ ០០០៛

ពបវ = (១ ៤០០ ០០០៛ x ៥%) - ៥០ ០០០៛ = **២០ ០០០៛**

**គ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៦ ក្នុងបន្ទុក**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៧ = ១ ០៥០ ០០០៛

មពបវ = ២ ០០០ ០០០៛ - ១ ០៥០ ០០០៛ = ៩៥០ ០០០៛ ជាប់ពន្ធក្នុងអត្រា 0%

ពបវ = 0៛

**ឧទាហរណ៍ទី២÷** កម្មករនិយោជិតម្នាក់មានប្រាក់បៀវត្ស ១២ ៦០០ ០០០ រៀល

**ក. ករណីនៅលីវ**

មពបវ = ១២ ៦០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ២0%

លបព = ១ ១៧៥ ០០០៛

ពបវ = (១២ ៦០០ ០០០៛ x ២0%) - ១ ១៧៥ ០០០៛ = **១ ៣៤៥ ០០០៛**

**ខ. ករណីមានសហព័ទ្ធជាមេផ្ទះ និងកូន៣**

ទាយជ្ជទានសហព័ទ្ធនិងកូនក្នុងបន្ទុក = ១៥០ ០០០៛ X ៤ = ៦០០ ០០០៛

មពបវ = ១២ ៦០០ ០០០៛ - ៦០០ ០០០៛ = ១២ ០០០ ០០០៛ ជាប់ពន្ធក្នុងអត្រា ១៥%

លបព = ៥៥០ ០០០៛

ពបវ = (១២ ០០០ ០០០៛ x ១៥%) - ៥៥០ ០០០៛ = **១ ២៥០ ០០០៛**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្ម ស្ថាប័នរដ្ឋ និងអង្គការនានាដែលមានកាតព្វកិច្ចកាត់ទុកនិងបង់ប្រាក់ពន្ធលើប្រាក់បៀវត្ស នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ២០១១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ កាលប្បវត្តិ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...១១២៧...អពដ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦

# សេចក្តីណែនាំ
## ស្តីពីការប្រើប្រាស់វិក្កយបត្រ
## សម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស

អនុលោមតាមមាត្រា៧៧ មាត្រា៧៨ មាត្រា៧៩ និងមាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម (អតប) ព្រមទាំងសេចក្តីជូនដំណឹងលេខ០២៤ សហវ-ពដ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) អ្នកជាប់ពន្ធទាំងអស់ត្រូវចេញវិក្កយបត្រលើរាល់ការលក់ ឬផ្គត់ផ្គង់ទំនិញឬសេវា ឱ្យបានត្រឹមត្រូវតាមគំរូដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ (គំរូវិក្កយបត្រទី១ ទី២ ទី៣ និងទី៤)។

ក្នុងការពង្រឹងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងការគ្រប់គ្រងចំណូលសារពើពន្ធឱ្យមានតម្លាភាពដើម្បីបង់ចូលថវិកាជាតិ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំអំពីវិធានប្រើប្រាស់វិក្កយបត្រដូចខាងក្រោម÷

ក- វិក្កយបត្រត្រូវមាននិទ្ទេសសំខាន់ៗមួយចំនួន ដូចខាងក្រោម÷

១- ឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្ម អ.ត.ប (VATTIN) របស់សហគ្រាសជាអ្នកលក់ ឬអ្នកផ្គត់ផ្គង់

២- ត្រូវមានលេខរៀងវិក្កយបត្រតាមលំដាប់ និងត្រូវមានកាលបរិច្ឆេទចេញវិក្កយបត្រ ឱ្យបានច្បាស់លាស់

៣- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទិញ ព្រមទាំងលេខអត្តសញ្ញាណកម្ម អ.ត.ប ប្រសិនបើអ្នកទិញជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

៤- សេចក្តីបរិយាយ បរិមាណ និងថ្លៃលក់ទំនិញ ឬសេវា

៥- តម្លៃសរុបដែលមិនទាន់គិតអាករ និងប្រាក់អាករដាច់ដោយឡែក

៦- គុណភាពទឹកថ្នាំបោះពុម្ពលើវិក្កយបត្រ និងសន្លឹកក្រដាសវិក្កយបត្រ ត្រូវតែរក្សាទុកបានយូរ។

ខ- រាល់វិក្កយបត្រ ត្រូវសរសេរ ឬបោះពុម្ពជាភាសាខ្មែរ ឬអាចជាពីរភាសា គឺភាសាខ្មែរនិងភាសាអង់គ្លេស ហើយដែលភាសាអង់គ្លេស ត្រូវនៅពីក្រោមភាសាខ្មែរ

គ- ត្រូវចេញវិក្កយបត្រអាករ (Tax Invoice) រាល់ការផ្គត់ផ្គង់ទំនិញ ឬសេវាទាំងអស់ ដល់អតិថិជនជាបុគ្គលជាប់អាករ ឬចេញវិក្កយបត្រធម្មតា (Commercial Invoice) ដល់អតិថិជនដែលមិនមែនជាបុគ្គលជាប់អាករ

ឃ- អ្នកជាប់ពន្ធត្រូវប្រើប្រាស់វិក្កយបត្រតាមលំដាប់លេខរៀងពេញមួយឆ្នាំ និងត្រូវរក្សាទុកជាឯកសារ សម្រាប់គោលដៅពន្ធដារ រយៈពេល ១០ ឆ្នាំ

ង- ចំពោះវិក្កយបត្រមិនត្រឹមត្រូវតាមទម្រង់ដូចមានកំណត់ក្នុងសេចក្តីណែនាំនេះ គឺមិនត្រូវបានអនុញ្ញាតឱ្យយកមកប្រើប្រាស់ជាឥណទានអាករលើធាតុចូល (VAT Credit) និងមិនត្រូវបានអនុញ្ញាតឱ្យធ្វើការកាត់កងជាចំណាយសម្រាប់គណនាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំទេ។ រាល់ការស្នើសុំឥណទានអាករលើធាតុចូល (VAT Credit) ប្រចាំខែ ត្រូវភ្ជាប់មកជាមួយនូវវិក្កយបត្រអាករត្រឹមត្រូវ ឬជាឯកសារស្កែន (Scan) ចេញពីច្បាប់ដើម (Soft Copy)។ ដូចគ្នានេះដែរ ចំពោះរាល់ការស្នើសុំកាត់កងចំណាយ ក៏ត្រូវមានវិក្កយបត្រត្រឹមត្រូវ ដូចមានកំណត់ក្នុងសេចក្តីណែនាំនេះផងដែរ។ /ឥ.

ច- អំពីគំរូវិក្កយបត្រ

វិក្កយបត្រអាករលើតម្លៃបន្ថែម (Tax Invoice) ត្រូវរចនាស្របតាមគំរូវិក្កយបត្រទាំងបួនប្រភេទ ដូចភ្ជាប់ជូនក្នុងឧបសម្ព័ន្ធនេះ។

- គំរូវិក្កយបត្រទី១ និងទី២ ប្រើសម្រាប់ការសរសេរវិក្កយបត្រដោយដៃ ឬបោះពុម្ពដោយប្រព័ន្ធកុំព្យូទ័រ។ គំរូវិក្កយបត្រ ទី៣ និងទី៤ គឺប្រើសម្រាប់ការចេញវិក្កយបត្រដោយម៉ាស៊ីនគិតលុយ (POS) ឬម៉ាស៊ីនគិតលុយតាមប្រព័ន្ធកុំព្យូទ័រ។
- គំរូវិក្កយបត្រទី១ និងទី៣ ប្រើសម្រាប់បុគ្គលជាប់អាករលើតម្លៃបន្ថែម (អ.ត.ប) ចេញឱ្យអតិថិជនរបស់ខ្លួនដែលជាបុគ្គលជាប់អាករលើតម្លៃបន្ថែម។ វិក្កយបត្រគំរូទី១ និងទី៣ នេះ នឹងត្រូវប្រើប្រាស់សម្រាប់ស្នើសុំឥណទានអាករលើតម្លៃបន្ថែម និងសម្រាប់ជាកម្មវត្ថុនៃការកាត់កងចំណាយសម្រាប់គណនាពន្ធលើប្រាក់ចំណេញ។
- គំរូវិក្កយបត្រទី២ និងទី៤ ប្រើសម្រាប់អតិថិជនដែលមិនមែនជាបុគ្គលជាប់ អ.ត.ប ពោលគឺសម្រាប់អ្នកប្រើប្រាស់ចុងក្រោយ។ គំរូវិក្កយបត្រនេះ មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ស្នើសុំឥណទានអាករលើតម្លៃបន្ថែម ឡើយ។

ឆ- អំពីទោសទណ្ឌ

ការមិនចេញវិក្កយបត្រ ឬបានចេញវិក្កយបត្រមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាអំពើរំលងក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់ស្តីពីសារពើពន្ធ និងត្រូវរងនូវទោសទណ្ឌដូចមានចែងក្នុងមាត្រា១៣៣ និងមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ មានជាអាទិ៍ ការបិទអាជីវកម្មក្នុងមួយរយៈពេលដែលកំណត់ដោយច្បាប់, ការធ្វើការកំណត់ពន្ធឡើងវិញ ឬការប្តឹងចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារដែលត្រូវទទួលរងការផ្តន្ទាទោសជាកពិន័យជាប្រាក់ដល់ ១០ ០០០ ០០០រៀល ឬជាប់ពន្ធនាគាររហូតដល់១ឆ្នាំ ឬទោសទាំងពីរនេះ។

ក្នុងការអនុវត្តច្បាប់ អគ្គនាយកដ្ឋានពន្ធដារនឹងចាត់មន្ត្រីពន្ធដារចុះដល់ទីតាំងរបស់សហគ្រាសតាមការជាក់ស្តែង ឬធ្វើការផ្ទៀងផ្ទាត់ (Cross Check) វិក្កយបត្រដែលចេញដោយសហគ្រាសផ្គត់ផ្គង់ទំនិញ ឬសេវា ដើម្បីពិនិត្យភាពត្រឹមត្រូវនៃការប្រើប្រាស់វិក្កយបត្ររបស់សហគ្រាស ដូចបានជម្រាបជូនខាងលើ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រីជាម្ចាស់ និងជាបណ្ណាធិការនៃសហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ បានយ៉ាងខ្ជាប់ខ្ជួន ប្រកបដោយតម្លាភាព និងស្មារតីទទួលខុសត្រូវ ព្រមទាំងកិច្ចសហការខ្ពស់។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

<u>កន្លែងទទួល៖</u>

- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពពន្ធដារពាក់ព័ន្ធ "ដើម្បីមុខការ"
- គ្រប់សហគ្រាសជាប់ពន្ធទាំងអស់ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

របសញ្ញាសម្គាល់ក្រុមហ៊ុន
LOGO

# ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ
## COMPANY NAME

លេខអត្តសញ្ញាណកម្ម អតប (VATTIN) □□□□-□□□□□□□□□

អាសយដ្ឋាន៖ ផ្ទះលេខ Address Nº | ផ្លូវ Street | ឃុំ/សង្កាត់ Commune/Sangkat

ក្រុង/ស្រុក/ខណ្ឌ Town/District/Khan | ខេត្ត/រាជធានី Province/City | ទូរស័ព្ទលេខ Telephone Nº

1

# វិក្កយបត្រអាករ
## TAX INVOICE

3

**អតិថិជន / Customer :**

ឈ្មោះក្រុមហ៊ុន ឬអតិថិជន
Company name / Customer ................................

ទូរស័ព្ទលេខ
Telephone Nº ................................

**លេខអត្តសញ្ញាណកម្ម អតប (VATTIN)** □□□□-□□□□□□□□□ (ប្រសិនជាមាន / If any)

2

លេខរៀងវិក្កយបត្រ
Invoice Nº ................................

កាលបរិច្ឆេទ
Date □□ □□ □□□□

4

| ល.រ Nº | បរិយាយមុខទំនិញ Description | បរិមាណ Quantity | ថ្លៃឯកតា Unit Price | ថ្លៃទំនិញ Amount |
|---|---|---|---|---|
| 1 | | | | |
| 2 | | | | |
| 3 | | | | |
| 4 | | | | |
| 5 | | | | |
| 6 | | | | |
| 7 | | | | |
| 8 | | | | |
| 9 | | | | |
| 10 | | | | |
| 11 | | | | |
| 12 | | | | |
| 13 | | | | |
| 14 | | | | |
| 15 | | | | |

| | |
|---|---|
| សរុប Sub Total | |
| អាករលើតម្លៃបន្ថែម ១០% VAT (10%) | |
| សរុបរួម Grand Total | |

5

គំរូ Sample only

ហត្ថលេខា និងឈ្មោះអ្នកទិញ
**Customer's Signature & Name**

ហត្ថលេខា និងឈ្មោះអ្នកលក់
**Seller's Signature & Name**

**សម្គាល់៖** ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់
**Note:** Original invoice for customer , copied invoice for seller

ប្រសញ្ញាបស់ក្រុមហ៊ុន
LOGO

# ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ
## COMPANY NAME

លេខអត្តសញ្ញាណកម្ម អតប (VATTIN) ☐☐☐☐ - ☐☐☐☐☐☐☐☐☐

អាសយដ្ឋាន៖ ផ្ទះលេខ Address N° ផ្លូវ Street ឃុំ/សង្កាត់ Commune/Sangkat

ក្រុង/ស្រុក/ខណ្ឌ Town/District/Khan ខេត្ត/រាជធានី Province/City ទូរស័ព្ទលេខ Telephone N°

(1)

# វិក្កយបត្រ
# INVOICE

(3)

**អតិថិជន** / Customer :

ឈ្មោះក្រុមហ៊ុន ឬអតិថិជន Company name / Customer ..........

ទូរស័ព្ទលេខ Telephone N° ..........

(2)

លេខរៀងវិក្កយបត្រ៖ Invoice N° ..........

កាលបរិច្ឆេទ៖ Date ☐☐ ☐☐ ☐☐☐☐

(4)

| ល.រ N° | បរិយាយមុខទំនិញ Description | បរិមាណ Quantity | ថ្លៃឯកតា Unit Price | ថ្លៃទំនិញ Amount |
|---|---|---|---|---|
| 1 | | | | |
| 2 | | | | |
| 3 | | | | |
| 4 | | | | |
| 5 | | | | |
| 6 | | | | |
| 7 | | | | |
| 8 | | | | |
| 9 | | | | |
| 10 | | | | |
| 11 | | | | |
| 12 | | | | |
| 13 | | | | |
| 14 | | | | |
| 15 | | | | |
| | | សរុប (ប្រូកបញ្ចូលទាំងអាករ) Total (VAT included) | | |

(5)

គំរូ 2 Sample only

ហត្ថលេខា និងឈ្មោះអ្នកទិញ
Customer's Signature & Name

ហត្ថលេខា និងឈ្មោះអ្នកលក់
Seller's Signature & Name

**សម្គាល់៖** ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់
**Note:** Original invoice for customer , copied invoice for seller





ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ

COMPANY NAME

(VATTIN) □□□□-□□□□□□□□□

Address N° Street Commune/Sangkat Town/District/Khan Province/City Telephone N°

វិក្កយបត្រ

INVOICE

Customer :

Company name / Customer

Tel N°

Invoice N°

Date □□ □□ □□□□

| N° | Description | Quantity | Unit Price | Amount |
| --- | --- | --- | --- | --- |

គំរូ 4

Sample only

Total (VAT included)

Customer's Signature & Name

Seller's Signature & Name

Note: Original invoice for customer , copied invoice for seller

1 2 3 4 5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៥៩៧ អពដ

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៧

## សេចក្តីជូនដំណឹង
## ស្តីពីការដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ២០១៧

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ និងប្រកាសលេខ ១៨២១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនដំណឹងដល់សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ មេត្តាជ្រាបអំពីកាតព្វកិច្ចនៃការដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់សម្រាប់ឆ្នាំ២០១៧ ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធទាំងអស់ រួមទាំងអ្នកជាប់ពន្ធដែលមិនទាន់បានធ្វើបច្ចុប្បន្នភាព និងអ្នកជាប់ពន្ធដែលបានធ្វើបច្ចុប្បន្នភាពរួចរាល់ហើយ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧។

២- អ្នកជាប់ពន្ធធំអាចទៅបង់ពន្ធប៉ាតង់នៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធតូចអាចទៅបង់ពន្ធប៉ាតង់នៅតាមសាខាពន្ធដារខេត្ត/ខណ្ឌ ដែលសហគ្រាសស្ថិតនៅ ឬនៅតាមសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ឬសាខាធនាគារកាណាឌីយ៉ា ក.អ ទូទាំងប្រទេស។

៣- ចំពោះអ្នកជាប់ពន្ធដែលបានធ្វើបច្ចុប្បន្នភាព ដែលមានប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ រួចហើយមិនតម្រូវឱ្យបំពេញលិខិតប្រកាសស្នើសុំបង់ពន្ធប៉ាតង់ទៀតទេ។ ប័ណ្ណប៉ាតង់ឆ្នាំ២០១៧នឹងត្រូវបានបោះពុម្ពជូនអ្នកជាប់ពន្ធភ្លាមៗ ដោយមិនយកកម្រៃសេវា ប្រសិនបើអ្នកជាប់ពន្ធទៅបោះពុម្ពនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារខេត្ត/ខណ្ឌ ដែលសហគ្រាសស្ថិតនៅ។ ក្នុងករណីអ្នកជាប់ពន្ធជ្រើសរើសការបោះពុម្ពនៅសាខាធនាគារកាណាឌីយ៉ា ក.អ ឬនៅសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ត្រូវបង់កម្រៃសេវាជូនធនាគារចំនួន ៤ ០០០ រៀល/ប័ណ្ណ។

៤- អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយនៅក្នុងរាជធានី-ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។ អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្ម នៅក្នុងរាជធានី-ខេត្ត ផ្សេងគ្នា អាចបង់ពន្ធប៉ាតង់រួមគ្នានៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារខេត្ត/ខណ្ឌ ឬសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ឬសាខាធនាគារកាណាឌីយ៉ា ក.អ ប៉ុន្តែត្រូវញែកប្រាក់ពន្ធទៅតាមគណនីរបស់សាខាពន្ធដារខេត្ត/ខណ្ឌ ឬនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ដែលអាជីវកម្មនោះស្ថិតនៅ។ ក្នុងករណីអ្នកជាប់ពន្ធជ្រើសរើសការបោះពុម្ពប័ណ្ណប៉ាតង់សាខា ឃ្លាំង រោងចក្រ រោងជាង នៅសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ឬសាខាធនាគារកាណាឌីយ៉ា ក.អ ត្រូវបង់កម្រៃសេវាជូនធនាគារដូចបានកំណត់នៅចំណុចទី៣ខាងលើ។

៥- ចំពោះអ្នកជាប់ពន្ធដែលមិនទាន់ធ្វើបច្ចុប្បន្នភាពការចុះបញ្ជីពន្ធដារឬមិនទាន់ចុះបញ្ជីពន្ធដារ ត្រូវបំពេញលិខិតប្រកាសស្នើសុំបង់ពន្ធប៉ាតង់តាមទម្រង់ បព ០០៨/ Form PR 008 បន្ទាប់មកត្រូវទៅធ្វើបច្ចុប្បន្នភាពឬ ចុះបញ្ជីពន្ធដារនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខេត្ត/ខណ្ឌ ឬក្រុមការងារចុះបញ្ជីពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ នៅជាន់ទី០៦នៃអគារសាលាជាតិពន្ធដារ ទើបអាចទទួលបានប័ណ្ណប៉ាតង់ឆ្នាំ២០១៧នេះ។

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

៦- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើនប្រភេទ ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។ សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។

៧- ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចតទៅ÷

ក- <u>អ្នកជាប់ពន្ធធំ</u> ដែលមាននៅក្នុងបញ្ជីពន្ធដារបច្ចុប្បន្នដែលមាន÷

- ផលរបរ ១០ ០០០ ០០០ ០០០ រៀល ឬតិចជាង ត្រូវបង់ពន្ធប៉ាតង់ចំនួន ៣ ០០០ ០០០ រៀល
- ផលរបរលើសពី ១០ ០០០ ០០០ ០០០ រៀល ត្រូវបង់ពន្ធប៉ាតង់ចំនួន ៥ ០០០ ០០០ រៀល។

អ្នកជាប់ពន្ធធំដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយ ដែលស្ថិតនៅតាមរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ចំនួន ៣ ០០០ ០០០ រៀល។

ខ- <u>អ្នកជាប់ពន្ធមធ្យម</u> ដែលមានក្នុងបញ្ជីពន្ធដារបច្ចុប្បន្នត្រូវបង់ពន្ធប៉ាតង់ចំនួន ១ ២០០ ០០០ រៀល។

គ- <u>អ្នកជាប់ពន្ធតូច</u> ត្រូវបង់ពន្ធប៉ាតង់ចំនួន ៤០០ ០០០ រៀល។

៨- អ្នកជាប់ពន្ធត្រូវដាក់តាំងបង្ហាញប័ណ្ណប៉ាតង់ដែលមានសុពលភាព នៅទីតាំងប្រកបអាជីវកម្មរបស់ខ្លួន ហើយប័ណ្ណប៉ាតង់មានតម្លៃតែចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់តែប៉ុណ្ណោះ។ អគ្គនាយកដ្ឋានពន្ធដារមានវិធីគ្រប់គ្រងនិងបោះពុម្ពប័ណ្ណប៉ាតង់តាមប្រព័ន្ធអេឡិកត្រូនិក ដែលមិនអាចក្លែងបន្លំបានឡើយ។

៩- អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់ប្រាក់ពន្ធឱ្យបានត្រឹមត្រូវទៅតាមពេលវេលា ដែលច្បាប់បានកំណត់។ ក្នុងករណីមានការយឺតយ៉ាវមិនបានបង់ពន្ធឱ្យទាន់ពេលវេលា ឬព្យាយាមបន្លំផលរបរ ដើម្បីគេចវេះពីការបង់ប្រាក់ពន្ធប៉ាតង់ ឬមានការក្លែងបន្លំប័ណ្ណប៉ាតង់ នឹងត្រូវទទួលរងនូវទោសទណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹម និងជឿជាក់ថា សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ជាក់ជាពុំខាន។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ ៤២២៧ អពដ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិនា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអនុវត្តការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក

ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ អនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើមុខទំនិញមួយចំនួន សេចក្តីជូនដំណឹងលេខ ០១៥ សហវ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក និងសេចក្តីជូនដំណឹងលេខ ០០៥ សហវ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដំណឹងដល់សហគ្រាសផលិតផលិតផលជាប់អាករពិសេសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ តទៅ អត្រាអាករពិសេសលើមុខទំនិញដែលផលិតនិងផ្គត់ផ្គង់ក្នុងស្រុកត្រូវបានកែសម្រួល និងកំណត់ដូចខាងក្រោម÷

១) ៣០ ភាគរយ លើមុខទំនិញស្រាបៀរគ្រប់ប្រភេទ

២) ៣៥ ភាគរយ លើមុខទំនិញសុរា (ស្រា) គ្រប់ប្រភេទ

៣) ២០ ភាគរយ លើមុខទំនិញបារីគ្រប់ប្រភេទ។

ដោយឡែក មូលដ្ឋានគិតអាករពិសេសត្រូវអនុវត្តដដែល តាមសេចក្តីជូនដំណឹងលេខ ០១៥ សហវ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក និងសេចក្តីជូនដំណឹងលេខ ០០៥ សហវ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីជានាយក បណ្ណាធិការ និងម្ចាស់សហគ្រាសផលិតផលិតផលជាប់អាករពិសេស ទាំងអស់មេត្តាជ្រាប និងអនុវត្តឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

# ទម្រង់បង់ប្រាក់ពន្ធ P 101

ប្រកាសប្រចាំខែ Month ______ ឆ្នាំ Year ______

លេខ Nº ______

កាលបរិច្ឆេទ Date ថ្ងៃ ______ ខែ ______ ឆ្នាំ ______

សម្រាប់បិទបាកូដ
Stick bar code here!

☐ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
Department of Large Taxpayer

☐ សាខាពន្ធដារ
Tax Branch ______

ឈ្មោះសហគ្រាស
Name of company ______

ឈ្មោះសហគ្រាសជាអក្សរឡាតាំង
Name of company in Latin ______

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number (TIN) ☐☐☐☐ - ☐☐☐☐☐☐☐☐☐☐☐

| ល.រ Nº | ប្រភេទពន្ធ Taxes type | | ប្រាក់ពន្ធ Tax Amount | លេខគណនី Account No | ពន្ធបន្ថែម Additional Tax | ការប្រាក់ Interest | គណនីពន្ធបន្ថែម Additional Acc | ប្រាក់សរុប Total Amount |
|---|---|---|---|---|---|---|---|---|
| 1 | ពន្ធប៉ាតង់ | ☐ | | | | | | 0 R |
| 2 | ពន្ធប្រថាប់ត្រាលើលក្ខន្តិកៈក្រុមហ៊ុន | ☐ | | | | | | 0 R |
| 3 | ពន្ធប្រថាប់ត្រាបិទក្រុមហ៊ុន | ☐ | | | | | | 0 R |
| 4 | ពន្ធប្រថាប់ត្រាលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា | ☐ | | | | | | 0 R |
| 5 | ពន្ធប្រថាប់ត្រាផ្ទេរភាគហ៊ុនអត្រា 0.១% | ☐ | | | | | | 0 R |
| 6 | ពន្ធប្រថាប់ត្រាលើលទ្ធកម្មសាធារណៈអត្រា0.១% | ☐ | | | | | | 0 R |
| 7 | ប្រាក់ពិន័យ និងការប្រាក់ | ☐ | | | | | | 0 R |
| 8 | កម្រៃសេវាចុះបញ្ជី ឬធ្វើបច្ចុប្បន្នភាព | ☐ | | | | | | 0 R |
| 9 | កម្រៃសេវាពន្ធប្រថាប់ត្រា | ☐ | | | | | | 0 R |
| 10 | ពន្ធលើប្រាក់បៀវត្ស | ☐ | | | | | | 0 R |
| 11 | ពន្ធលើអត្ថប្រយោជន៍បន្ថែម | ☐ | | | | | | 0 R |
| 12 | ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ | ☐ | | | | | | 0 R |
| 13 | ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ☐ | | | | | | 0 R |
| 14 | ពន្ធលើប្រាក់ចំណេញបន្ថែមលើភាគលាភ | ☐ | | | | | | 0 R |
| 15 | ពន្ធអប្បបរមា | ☐ | | | | | | 0 R |
| 16 | ពន្ធកាត់ទុកលើសេវាកម្ម ១៥% | ☐ | | | | | | 0 R |
| 17 | ពន្ធកាត់ទុកលើការប្រាក់ ១៥% | ☐ | | | | | | 0 R |
| 18 | ពន្ធកាត់ទុកលើការប្រាក់ ៦% | ☐ | | | | | | 0 R |
| 19 | ពន្ធកាត់ទុកលើការប្រាក់ ៤% | ☐ | | | | | | 0 R |
| 20 | ពន្ធកាត់ទុកលើអនិវាសនជន (ការប្រាក់) | ☐ | | | | | | 0 R |
| 21 | ពន្ធកាត់ទុកលើអនិវាសនជន (សួយសារថ្លៃឈ្នួល) | ☐ | | | | | | 0 R |
| 22 | ពន្ធកាត់ទុកលើអនិវាសនជន (សេវាគ្រប់គ្រងបច្ចេកទេស) | ☐ | | | | | | 0 R |
| 23 | ពន្ធកាត់ទុកលើអនិវាសនជន (ភាគលាភ) | ☐ | | | | | | 0 R |
| 24 | ពន្ធកាត់ទុកលើថ្លៃឈ្នួល (រូបវន្តបុគ្គល) | ☐ | | | | | | 0 R |
| 25 | ពន្ធកាត់ទុកលើថ្លៃឈ្នួល (នីតិបុគ្គល) | ☐ | | | | | | 0 R |
| 26 | អាករលើតម្លៃបន្ថែម | ☐ | | | | | | 0 R |
| 27 | អាករពិសេសលើទំនិញមួយចំនួន | ☐ | | | | | | 0 R |
| 28 | អាករពិសេសលើសេវាមួយចំនួន | ☐ | | | | | | 0 R |
| 29 | ពន្ធបន្ថែមចំពោះការរាំងស្ទះ | ☐ | | | | | | 0 R |
| 30 | ចំណូលពីការលក់ឯកសារបោះពុម្ព | ☐ | | | | | | 0 R |
| 31 | អាករសម្រាប់បំភ្លឺសាធារណៈ | ☐ | | | | | | 0 R |
| 32 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | ☐ | | | | | | 0 R |
| 33 | អាករលើការស្នាក់នៅ | ☐ | | | | | | 0 R |
| 34 | ពន្ធសត្តឃាត | ☐ | | | | | | 0 R |
| 35 | ពន្ធតែមប្រ៊ី - ផ្លាកយីហោ | ☐ | | | | | | 0 R |
| 36 | ពន្ធតែមប្រ៊ីសារពើពន្ធលើផ្ទាំងផ្សាយពាណិជ្ជកម្ម | ☐ | | | | | | 0 R |
| 37 | កម្រៃសេវាភ្នាក់ងារពន្ធដារ | ☐ | | | | | | 0 R |

សរុប Total: 0 R

ហត្ថលេខា និងឈ្មោះ
Signature and name

ហត្ថលេខា និង ឈ្មោះ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
